ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# ភាសាខ្មែរ



៥

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

# ភាសាខ្មែរ

## ថ្នាក់ទី ៥

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

| | | |
|---|---|---|
| **គណៈកម្មការនិពន្ធ** | លោកស្រី ឈិន ស៊ីវឡេង | លោក យ៉ង់ កំស៊ាន |
| | លោកស្រី ស៊ុន សូម៉ាណា | លោកស្រី ជា ចាន់នារី |
| **អ្នកខាយអត្ថបទ** | លោក អ៊ុំ បុប្ផា | |
| **វិចិត្រករ** | លោក សឿម កក្កដា | |
| **អ្នករៀបរៀង** | លោកជំទាវ ទន់ សាអ៊ីម | |
| **អ្នករចនាទំព័រ** | លោក ខែម ម៉ារី | |
| **គណៈកម្មការពិនិត្យ** | លោក យិន ធី | លោកស្រី សរ សារាបូណ៍ |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ១២២ អយក.ប្រក. ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១១ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។


ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**



បោះពុម្ពឆ្នាំ២០១៦

ISBN 9-789-995-001-315

# អារម្ភកថា

ប្អូនៗកុមារា កុមារី ជាទីស្នេហា !

សៀវភៅភាសាខ្មែរថ្នាក់ទី៥ថ្មីនេះ ត្រូវបាននិពន្ធតាមកម្មវិធីសិក្សាថ្មី ។ សៀវភៅនេះនឹងជួយប្អូនៗក្នុងការអភិវឌ្ឍចំណេះដឹងគ្រឹះផ្នែកភាសាខ្មែរដូចជាបំណិនអាន សរសេរ ស្ដាប់ និងនិយាយ ។ សៀវភៅនេះ បង្ហាញពីខ្លឹមសារទាក់ទងនឹងប្រធានបទល្អ ៗដូចជា ជនគំរូពីអតីតកាល និងបច្ចុប្បន្នកាលព្រមទាំងចំណេះដឹងសំខាន់ៗជាច្រើនទៀតដែលមានប្រយោជន៍សម្រាប់អ្នក ។

តាមរយៈសៀវភៅនេះ ប្អូនៗសិក្សាកំណាព្យ រឿងនិទាន អត្ថបទសន្ទនា លំហាត់អាន និងលំហាត់សរសេរងាយៗដែលប្អូនអាចយល់ និងអាចធ្វើបានគ្រប់មេរៀន ។

នៅចុងបញ្ចប់នៃមេរៀន ប្អូនៗនឹងបានធ្វើតេសដោយខ្លួនឯងលើសមត្ថភាពអាន ដើម្បីវាយតម្លៃលើការសិក្សាកន្លងមក ។ នៅផ្នែកខាងក្រោយនៃសៀវភៅ មានបទានុក្រមដែលនឹងជួយឱ្យប្អូនៗអាចស្វែងយល់ន័យរបស់ពាក្យពិបាក ដែលមាននៅក្នុងមេរៀននីមួយៗនៃសៀវភៅនេះ ព្រមទាំងហាត់អានពាក្យមុននឹងរៀនជាមួយលោកគ្រូ ឬអ្នកគ្រូ ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅភាសាខ្មែរថ្នាក់ទី៥ថ្មីនេះ អាចផ្ដល់ចំណេះដឹងល្អៗ ដើម្បីពង្រឹងសមត្ថភាពផ្នែកភាសាខ្មែរ និងជួយឱ្យសតិបញ្ញាស្មារតីចម្រើនលូតលាស់ឆាប់រហ័សស្របតាមការអភិវឌ្ឍរបស់សង្គមជាតិ ។

សូមឱ្យប្អូនៗទទួលបានជោគជ័យក្នុងការសិក្សា ។

គណៈកម្មការនិពន្ធ

# បញ្ជីអត្ថបទ


ទំព័រ

មេរៀនទី ១ : វីរជននារី ........................ ១

មេរៀនទី ២ : សម្បត្តិអក្សរសិល្ប៍ ........................ ១៧

មេរៀនទី ៣ : កំណាព្យខ្មែរ ........................ ៣១

មេរៀនទី ៤ : ប្រយោជន៍នៃសារព័ត៌មាន ........................ ៤៥

មេរៀនទី ៥ : ស្មារតីទទួលខុសត្រូវ ........................ ៦១

មេរៀនទី ៦ : អតីតកាលរបស់យើង ........................ ៧៩

មេរៀនទី ៧ : ទូរគមនាគមន៍នៅកម្ពុជា ........................ ៩៣

មេរៀនទី ៨ : ផលិតផលខ្មែរ ........................ ១០៩

មេរៀនទី ៩ : ពេលវេលាជាមាសប្រាក់ ........................ ១២៣

មេរៀនទី ១០ : ប្រយោជន៍នៃវិទ្យាសាស្ត្រ ........................ ១៣៥

តែសអំណាន : ........................ ១៤៥

បទានុក្រម : ........................ ១៤៨

មេរៀនទី

# ១ វីរជនឆ្នើម



ព្រះនាងឥន្ទ្រទេវី



សម្តេចព្រះសង្ឃរាជ ជួន ណាត





តាំងពីបុរាណកាលរហូតដល់បច្ចុប្បន្នកាល ខ្មែរយើងមានវីរជនឆ្នើមជាច្រើនរូប ក្នុងនោះមានយុទ្ធជន វីរជនស្នេហាជាតិ អ្នកដឹកនាំមួយចំនួន និងប្រជាជន ។ លោកទាំងនោះបានបន្សល់ទុកស្នាដៃល្អៗ ដែលសង្គមជាតិយើងស្ញើចសរសើរ និងទុកជាគំរូសម្រាប់មនុស្សជំនាន់ក្រោយ ។ តើនៅសហគមន៍អ្នកមានវីរជនឆ្នើមដែរ ឬទេ ?

## ការប្រៀបធៀបតួអង្គ

រឿងនីមួយៗ តែងមានតួអង្គតិច ឬច្រើន ។ តួអង្គនីមួយៗ មានលក្ខណៈដោយឡែកៗពីគ្នា ។ ចូរអានរឿងខាងក្រោម រួចធ្វើការប្រៀបធៀបតួអង្គទាំងនោះ ។

### រឿង កល្យាណមិត្ត

សុខុមនិងសាវន់ ជាកល្យាណមិត្តរៀនថ្នាក់ជាមួយគ្នា ។ សុខុមជាកូនអ្នកមានកេរមរតកដីស្រែច្រើន ឯសាវន់ជាកូនកសិករមានវង្សត្រកូលល្អ ។ ថ្ងៃមួយ គ្រួសារសុខុមបានលក់ដីស្រែមួយចំនួន បានប្រាក់យ៉ាងច្រើនក្លាយជាអ្នកមាន ។ តាំងពីពេលនោះមក សុខុមមិនសូវនិយាយស្ដីរាប់រកសាវន់ដូចមុនឡើយ ។ សាវន់ឃើញបែបនេះ ក៏មិនប្រកាន់ខឹងនឹងសុខុមដែរ ។ សាវន់នៅតែខិតខំប្រឹងប្រែងរៀនសូត្រជាធម្មតា ។ ចំណែកសុខុមវិញតែងដើរលេង ស៊ីចាយ សប្បាយហ៊ឺហា គេចវេះសាលារៀនជាញឹកញាប់ ។

គ្រួសារសុខុមលក់ដីស្រែជាបន្តបន្ទាប់ រហូតដល់អស់កេរមរតកពីដូនតា ។ មិនយូរប៉ុន្មាន ប្រាក់ក៏អស់ ដីក៏អស់ឥតមានអ្វីទីពឹងទៀតឡើយ ។ សុខុមឈប់ចូលសាលារៀន ហើយធ្លាក់ខ្លួនជាក្មេងប្រព្រឹត្តអំពើផ្ដេសផ្ដាសដែលសង្គមស្អប់ខ្ពើម ។

ថ្ងៃមួយ សាវន់បានជួបនឹងសុខុមដោយចៃដន្យ ។ សាវន់ភ្ញាក់ព្រើត ព្រោះនឹកស្មានមិនដល់ថា សុខុមមានសក់កន្ទ្រើង សម្លៀកបំពាក់រយីករយាកដើរតាមចិញ្ចើមផ្លូវ ។ សាវន់ដើរទៅចាប់ដៃសុខុម ហើយសួរនាំពីមូលហេតុដែលនាំឱ្យគេធ្លាក់ខ្លួនបែបនេះ តែសុខុមព្យាយាមគេចពីសាវន់ ។ សាវន់ព្យាយាមនិយាយណែនាំមិត្តឱ្យចូលសាលារៀន ហើយកែខ្លួនមកប្រព្រឹត្តអំពើល្អវិញ ។ សុខុមមានចិត្តរីករាយ ដោយសាវន់មិនប្រកាន់ខឹងនឹងខ្លួន ហើយក៏យល់ព្រមធ្វើតាមសាវន់ដែលជាកល្យាណមិត្ត ។

តាមសាច់រឿងនេះ យើងអាចប្រៀបធៀបតួអង្គសាវន់ និងសុខុមបានដូចខាងក្រោម ៖

**ក. តួអង្គសាវន់** ៖ ជាមនុស្សមានចរិតលក្ខណៈល្អ យកចិត្តទុកដាក់នឹងការសិក្សា ចេះយោគយល់អធ្យាស្រ័យ មានចិត្តទូលាយ ចេះដាស់តឿនមិត្តភក្ដិឱ្យប្រព្រឹត្តអំពើល្អ ។

**ខ. តួអង្គសុខុម** ៖ ជាមនុស្សមានចរិតភ្លើតភ្លើន ឆាប់ឈ្លក់វង្វេងនឹងទ្រព្យសម្បត្តិ ចូលចិត្តសប្បាយហ៊ឺហា ភ្លេចមិត្តភក្តិដែលធ្លាប់កម្សត់កម្រនឹងគ្នា តែជាមនុស្សអាចអប់រំណែនាំបាន ។

ការប្រៀបធៀបតួអង្គ គឺជាការបង្ហាញលក្ខណៈ ល្អ អាក្រក់ កាច ស្លូតដោយផ្តោតទៅលើរូបសម្បត្តិ ចរិតលក្ខណៈ សកម្មភាព របស់តួអង្គ ។

## លំហាត់

ចូរអានរឿង“ ក្មេងកំព្រា” រួចធ្វើការប្រៀបធៀបតួអង្គនិននិងគំនិត ។

## រឿង ក្មេងកំព្រា

មានបុរសពោះម៉ាយម្នាក់ប្រកបរបរជ្រលក់អំបោះ ។ បុរសនោះ រស់នៅជាមួយកូនប្រុសម្នាក់ និងក្មួយកំព្រាម្នាក់ ។ កូនប្រុសរបស់គាត់ឈ្មោះនិន ឯក្មួយប្រុសឈ្មោះគំនិត ។ រាល់ពេលបុរសនោះលាយល័ខជ្រលក់អំបោះ គាត់តែងហៅនិន និងគំនិតមកក្បែរដើម្បីជួយហុចនេះ ហុចនោះឱ្យគាត់ ។ ជារឿយៗ និនតែងដោះសាថា រវល់រៀនសូត្រ ឬធ្វើនេះធ្វើនោះជានិច្ច ប៉ុន្តែគេគេចទៅដើរលេងជាមួយមិត្តភក្តិទៅវិញ ។ ឪពុកនិនឮថាកូនជាប់រវល់ក៏មិនសូវហៅរកទេ ។ ឯគំនិតវិញ ឆ្លៀតពេលទំនេរពីការសិក្សា គេតែងជួយឪពុកមា ហើយបានយល់ច្បាស់ពីរូបមន្តក្នុងការលាយល័ខ និងរបៀបជ្រលក់អំបោះ ។

ថ្ងៃមួយ បុរសនោះមានជំងឺធ្ងន់ ហើយលាចាកលោកទៅចោលក្មេងទាំងពីរឱ្យនៅកំព្រា ដោយបន្សល់ទុកប្រាក់កាសតែបន្តិចបន្តួចប៉ុណ្ណោះ ។ គំនិតប្រាប់និនថា យើងមានប្រាក់សល់តិចតួចណាស់ យើងគួរប្រកបរបរជ្រលក់អំបោះនេះបន្តទៅទៀត ទើបអាចចិញ្ចឹមជីវិតបាន ។ និនប្រកែកថា ធ្វើមិនកើតទេព្រោះគេមិនចេះសោះ ។ ពេលនោះគំនិតប្រាប់និនថា ខ្លួនគេចេះចាំនិងអាចធ្វើកិច្ចការទាំងអស់នោះបាន គ្រាន់តែមិនទាន់ប្រសប់ប៉ុណ្ណោះ ។ និនក៏យល់ព្រម ហើយប្រឹងប្រែងធ្វើការងារតាំងពីពេលនោះមករហូតដល់បានសម្រេច ។

# រឿង អ្នកតាឃ្លាំងមឿង



ក្នុងរាជ្យព្រះចន្ទរាជា(គ. ស. ១៥០២) ប្រទេសខ្មែរស្ថិតនៅចំណុះប្រទេសសៀម ។ ពេលនោះ ស្តេចសៀមបានបញ្ជូនបុត្រាមួយអង្គមកត្រួតត្រានគរខ្មែរ ។ ដោយឈឺចាប់នឹងការជិះជាន់ឈ្លានពានរបស់សៀម ព្រះចន្ទរាជាក៏សម្លាប់បុត្រានោះទៅ ។ ព្រះចៅសៀមក្រោធយ៉ាងខ្លាំង ក៏លើកទ័ពមកវាយក្រុងលង្វែក ។ ទ័ពសៀមបានកៀរប្រជាជនខ្មែរជាច្រើននាក់យកទៅស្រុកសៀម ក្នុងនោះមានអ្នកម្នាងប៉ែន និងមេដំរីឈ្មោះជំទាវប៉ាល់ប៉ៃផងដែរ ។ ក្រោយមក អ្នកម្នាងប្រសូតបានបុត្រមួយអង្គមាននាមថា ឧទេន ។ រីឯមេដំរីក៏កើតបានកូនមួយដែរ ។ ថ្ងៃមួយ ឧទេនបានសុំហ្មដំរីបោសរោងដំរី ដើម្បីរៀនវិជ្ជាខាងហ្មដំរី ។ ស្តេចសៀមឃើញឧទេនឧស្សាហ៍ ក៏ប្រទានងារជាអ្នកត្រួតត្រាភ្នាក់ងារខាងដំរី ។

ពេលធំឡើង កូនមេដំរីប៉ាល់ប៉ៃបានធ្វើជាទីនាំងព្រះចៅសៀម ។ ថ្ងៃមួយ ស្រាប់តែវាចុះប្រេង ព្រេចហ្មស្លាប់ ។ ឧទេន តាមចាប់ដំរីនោះបាន ។ តាំងពីពេលនោះមក ព្រះចៅសៀមបានប្រទានងារឧទេនថា “ជ័យអស្ចារ្យ” ។ អាយុបាន១៦ឆ្នាំ ជ័យអស្ចារ្យបានប្រើឧបាយកលត្រឡប់មកសោយរាជ្យស្រុកខ្មែរវិញ ។ លុះមកដល់ស្រុកបាត់ដំបង អ្នកស្រុក

និងសេនាចាស់ម្នាក់ឈ្មោះមឿង ព្រមទាំងកូន៤នាក់បានចូលមកថ្វាយខ្លួនជាសេនា ។ ស្តេចសៀមដឹង ក៏លើកទ័ពដេញតាម ។ ដោយពុំមានអាវុធបរិបូណ៌ សេនាមឿងបានធានាថា ខ្លួនតតាំងនឹងសៀមដោយប្រើឧបាយកលចម្លែកមួយ គឺហ៊ានប្តូរជីវិតដើម្បីទៅកេណ្ឌពលខ្មោចមកច្បាំងនឹងសៀម ។ លោកបានបង្គាប់ឱ្យជីករណ្តៅ រួចដាក់ចម្រូង ។ លោកលោតចុះទៅក្នុងរណ្តៅនោះ រីឯប្រពន្ធ និងកូនពីរនាក់ទៀតក៏លោតចុះតាមដែរ ។ លុះថ្ងៃពេញបូណ៌មី គេឮសន្ធឹកកក្រើកមេឃ កក្រើកដីដូចបណ្តាំសេនាមឿងមែន ។ ទ័ពខ្មោចបានដង្ហែជ័យអស្ចារ្យលើកទ័ពទៅឡោមព័ទ្ធបន្ទាយសត្រូវ ។ ទ័ពសៀមភ័យរន្ធត់នាំគ្នារត់ប្រាសអាយុ ។ ទ័ពសៀមបាក់បបខ្លបខ្លាចទ័ពជ័យអស្ចារ្យ ក៏វិលត្រឡប់ទៅស្រុកវិញអស់ ។ ជ័យអស្ចារ្យឡើងគ្រងរាជ្យបន្តពីព្រះបិតា និងទទួលព្រះនាមថា“ ព្រះជ័យចេស្តា” ។

(ដកស្រង់និងកែសម្រួលពីសៀវភៅ ប្រជុំរឿងព្រេងខ្មែរ ភាគទី៨ ទំព័រទី៨)

## សំណួរ

១. តើរឿងនេះមានតួអង្គណាខ្លះ ? តើតួអង្គនីមួយៗធ្វើសកម្មភាពអ្វីខ្លះ ?
២. តើរឿងនេះកើតឡើងនៅពេលណា? នៅកន្លែងណាខ្លះ ?
៣. តើជ័យអស្ចារ្យទទួលបានជ័យជម្នះលើទ័ពសៀមដោយរបៀបណា ?
៤. តើព្រះចន្ទរាជាមានឥរិយាបថដូចម្តេច ចំពោះទង្វើរបស់សៀមនៅក្នុងសាច់រឿងនេះ ?
៥. តើតួអង្គណាខ្លះដែលអាចចាត់ទុកជាវីរជន? ចូរបញ្ជាក់ពីសកម្មភាពរបស់វីរជនទាំងនោះ ?
៦. តើអ្នកតាឃ្លាំងមឿងមានពិត ឬទេ ? បើមាន តើមាននៅខេត្តណា?

## លំហាត់

ចូរជ្រើសរើសចម្លើយណាដែលជាព្រឹត្តិការណ៍នៃរឿង រួចរៀបព្រឹត្តិការណ៍ទាំងអស់តាមលំដាប់លំដោយដំណើររឿងឱ្យបានត្រឹមត្រូវ ។

១. ជ័យអស្ការ្យច្បាំងឈ្នះសៀម ហើយបានឡើងសោយរាជ្យ ។

២. នគរខ្មែរត្រួតត្រាលើនគរសៀម ។

៣. សេនាមឿងលោតចូលរណ្ដៅ ទៅកេណ្ឌទ័ពខ្មោចមកច្បាំងនឹងទ័ពសៀម ។

៤. ព្រះចន្ទរាជាសម្លាប់បុត្រាស្ដេចសៀម ។

៥. ព្រះចៅសៀមបានលើកទ័ពមកវាយក្រុងលង្វែក និងបានកៀរប្រជាជនខ្មែរទៅស្រុកសៀម ។

៦. ស្ដេចសៀមសោយទិវង្គត ពេលច្បាំងជាមួយជ័យអស្ការ្យ ។

៧. ស្ដេចសៀមចងសម្ព័ន្ធមិត្តជាមួយព្រះជ័យចេស្ដា ។

## ការបំពេញកថាខណ្ឌ

ក. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ដើម្បីបំពេញកថាខណ្ឌខាងក្រោមឱ្យបានត្រឹមត្រូវ ។

| ទូលាយ | ធំធាត់ | ក្លាហាន | ស្លូតបូត | គំរូ |
| --- | --- | --- | --- | --- |

លោកវីរៈ ជានាយទាហាន មានវ័យក្មេងជាងគេនៅក្នុងកងពលលេខ១ ។ គាត់ជាយុទ្ធជន....ហ៊ានប្រយុទ្ធឥតរាថយដើម្បីការពារទឹកដី ។ គាត់ជាមនុស្ស.....តែម៉ឺងម៉ាត់ ។ គាត់ស្មោះត្រង់ និងមានសាមគ្គីភាព...........មិនប្រកាន់ឋានៈ ឬតួនាទីឡើយ ។ នៅពេលទំនេរ គាត់នាំពលទាហានដាំដំណាំ និងមើលថែទាំសត្វចិញ្ចឹមឱ្យបាន............ ។ មិនតែប៉ុណ្ណោះ គាត់នាំពលទាហានទៅជួយស្ទូង ច្រូតស្រូវ ឬជីកប្រឡាយជូនប្រជាជនទៀតផង ។ ប្រជាជន និងអ្នកក្រោមឱវាទស្រឡាញ់ គោរព និងចាត់ទុកគាត់ជាជន.......... ......ម្នាក់ដែលគួរយកតម្រាប់តាម ។

ខ. ចូរបំពេញល្បះខាងក្រោម ឱ្យបានសមស្រប ។

១. សេនាមឿងសុខចិត្តស្លាប់ដើម្បី.......................... ។

២. ស្ដេចសៀមបានលើកទ័ពមកវាយ....................... ។

៣. វីរជនខ្មែរតស៊ូដើម្បីការពារ............................ ។

៤. ប្រជាជនខ្មែរ សុទ្ធតែជាអ្នក.............ជាតិ និងទឹកដី ។

# រឿង ចចកនិងកំពីស




## សំណួរ

១. តើរឿងនេះមានតួអង្គណាខ្លះ? តើតួអង្គនីមួយៗធ្វើសកម្មភាពអ្វីខ្លះ?

២. តើរឿងនេះកើតឡើងនៅកន្លែងណាខ្លះ? នៅពេលណា?

៣. តើនឹងមានរឿងអ្វីកើតឡើង នៅពេលទន្សាយបន្លំអានសំបុត្ររបស់ព្រះឥន្ទ្រ ?

## លំហាត់

ក. ចូរធ្វើការប្រៀបធៀបតួអង្គចចក និងកំពីស ។

ខ. ចូរគូសសញ្ញា ✓ នៅមុខចម្លើយមួយដែលបង្ហាញចរិតលក្ខណៈរបស់តួអង្គត្រីក្រាញ់ ។

☐ ១. ខិលខូច ☐ ២. ក្លាហាន ☐ ៣. ឧស្សាហ៍ ។

គ. ចូរគូសសញ្ញា ✓ នៅមុខចម្លើយមួយ ដែលបង្ហាញចរិតលក្ខណៈរបស់តួអង្គចចក ។

☐ ១. កាចសាហាវ ☐ ២. ចង្អៀតចង្អល់ ☐ ៣. ឆ្លាតវាងវៃ ។

# គុណនាម

គុណនាម គឺជាសម្ដីសម្ដែងលក្ខណៈរបស់នាម ។ គុណនាមមានពីរប្រភេទគឺ គុណនាមប្រក្រតី និងគុណនាមកំណត់ ។

## ក. គុណនាមប្រក្រតី

ចូរអានឧទាហរណ៍ខាងក្រោម ដោយពិនិត្យពាក្យមានគំនូសពីក្រោម ។

១. ធីតាមានមុខមូល ភ្នែកធំ សក់វែង ។

២. ពូគុណជាយុទ្ធជនអង់អាចក្លាហានម្នាក់ ។

៣. មីងសម្បត្តិបានទទួលងារជានារីឆ្នើម ក្នុងការដឹកនាំនារីក្នុងភូមិ ។

ឧទាហរណ៍ទី ១៖ ពាក្យ "មូល" បញ្ជាក់លក្ខណៈរបស់នាម "មុខ" ពាក្យ"វែង" បញ្ជាក់លក្ខណៈរបស់នាម "សក់" ពាក្យ"ធំ"បញ្ជាក់លក្ខណៈរបស់នាម"ភ្នែក" ។

ឧទាហរណ៍ទី ២៖ ពាក្យ" អង់អាចក្លាហាន" បញ្ជាក់លក្ខណៈរបស់នាម"យុទ្ធជន" ។

ឧទាហរណ៍ទី ៣៖ ពាក្យ"ឆ្នើម"បញ្ជាក់លក្ខណៈរបស់នាម"នារី" ។ ដូច្នេះ ពាក្យ " មូល វែង ធំ អង់អាចក្លាហាន ឆ្នើម "បញ្ជាក់លក្ខណៈធម្មតារបស់នាមដែលនៅខាងឆ្វេងវា ។ ពាក្យទាំងនេះ ជាគុណនាមប្រក្រតី ។

> គុណនាមប្រក្រតី ប្រាប់លក្ខណៈធម្មតារបស់នាម ។

## ខ. គុណនាមកំណត់

ចូរអានឧទាហរណ៍ខាងក្រោម ដោយពិនិត្យពាក្យមានគំនូសពីក្រោម ។

១. មនុស្សនេះ ល្បីល្បាញណាស់ ។

២. ផ្ទះខ្ញុំ ស្ថិតនៅក្បែរផ្ទះគាត់ ។

៣. តើគាត់ធ្វើការងារអ្វី ?

៤. នៅជាប់នឹងផ្លូវទី ១ មានដើមឈើពីរដើម ។

៥. គ្មានមនុស្សណា ពូកែដូចគាត់ទេ ។

ឧទាហរណ៍ទី ១ ៖ ពាក្យ“ នេះ” បង្ហាញឋានភាពនៃទីកន្លែង(មនុស្សនៅជិត) ។

ឧទាហរណ៍ទី ២ ៖ ពាក្យ“ ខ្ញុំ គាត់” បង្ហាញម្ចាស់នៃវត្ថុ (ផ្ទះ) ។

ឧទាហរណ៍ទី ៣ ៖ ពាក្យ“អ្វី” សម្រាប់សួរ ។

ឧទាហរណ៍ទី ៤ ៖ ពាក្យ“ ទី១ ” បង្ហាញចំនួនរៀប និងពាក្យ “ពីរ” បង្ហាញចំនួនរាប់ ។

ឧទាហរណ៍ទី ៥ ៖ ពាក្យ “គ្មាន... ណា” បញ្ជាក់លក្ខណៈមិនច្បាស់លាស់របស់មនុស្ស ។ ពាក្យ “ នេះ ខ្ញុំ គាត់ អ្វី ទី១ ពីរ គ្មាន ណា” ជាគុណនាមកំណត់ ។

គុណនាមកំណត់សម្រាប់ប្រាប់ចំនួន លំដាប់ទី ប្រាប់ម្ចាស់កម្មសិទ្ធិសម្រាប់សួរ ឬចង្អុលប្រាប់ឋានភាពនៃទីកន្លែង ឬពេលវេលា ។

## លំហាត់

ក. ចូរស្រង់គុណនាមប្រក្រតី និងគុណនាមកំណត់ក្នុងល្បះខាងក្រោម ។

១. សុខាជាសិស្សពូកែ ។ នាងតែងទទួលបាននិទ្ទេសល្អ ។

២. រូបចម្លាក់នោះ គឺជាព្រះនាងឥន្ទ្រទេវី ។

៣. ជីតាខ្ញុំ ជាជនគំរូនៅក្នុងភូមិនេះ ។

៤. តើគាត់ធ្វើការងារល្អដែរ ឬទេ ?

៥. គាត់ជាស្ត្រីដំបូង ដែលមានឈ្មោះល្បីនៅក្នុងប្រវត្តិសាស្ត្រ ។

ខ. ចូរតែងល្បះដោយប្រើគុណនាមប្រក្រតី ឬគុណនាមកំណត់ក្នុងប្រអប់ខាងក្រោម ក្នុងមួយពាក្យឱ្យបានមួយល្បះ ។

| | | | | | |
|---|---|---|---|---|---|
| បី | នេះ | ខ្ញុំ | វែង | ទាប | ក្រ |

# សម្តេចព្រះសង្ឃរាជ ជួន ណាត




កាលណាគេនិយាយអំពីអក្សរសាស្ត្រខ្មែរ គេតែងនិយាយពីមនុស្សម្នាក់ដែលមានឈ្មោះល្បីជាងគេនៅក្នុងប្រទេសកម្ពុជា ។ នោះគឺ សម្តេចព្រះសង្ឃរាជ ជួន ណាត ។ សម្តេចព្រះសង្ឃរាជជួន ណាត ប្រសូតនៅថ្ងៃ១១រោច ខែផល្គុន ឆ្នាំវក ឆស័ក ពុទ្ធសករាជ ២៤២៧ ត្រូវនឹងថ្ងៃទី១១ ខែមីនា ឆ្នាំ ១៨៨៣ នៅភូមិកំរៀង ឃុំរកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ ញោមប្រុសនាម ព្រហ្ម ជួន និងញោមស្រីនាម យក់ ។

កាលពីកុមារភាព លោកបានទៅស្នាក់នៅ និងរៀនសូត្រជាមួយលោកគ្រូសូត្រស្តាំ ព្រះនាម ម៉ម នៅវត្តពោល្យំ ឃុំរលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ លុះចម្រើនវ័យ ១៤ឆ្នាំ លោកបានបួស រហូតដល់ឆ្នាំ ១៨៩៩ លោកបាននិមន្តមកកាន់វស្សានៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ ។ លោកបានរៀនភាសាបាលី សំស្ក្រឹត ចេះចាំយ៉ាងស្ទាត់ជំនាញ ។ រីឯភាសាបរទេសវិញ លោកចេះភាសាបារាំង អង់គ្លេស សៀម លាវ និងវៀតណាមបានល្អបង្គួរ ។

លោកមានស្នាព្រះហស្តធំៗជាច្រើន ទាំងផ្លូវលោក ទាំងផ្លូវធម៌ ។ លោកបានចូលរួមកសាងសាលារៀន មន្ទីរពេទ្យ ស្ពានថ្នល់ ទំនប់ទឹក វចនានុក្រមខ្មែរ ចម្រៀងបទនគររាជ(ចម្រៀងគោរពទង់ជាតិសព្វថ្ងៃ) ។ ខាងផ្លូវធម៌ លោកបាននិពន្ធសៀវភៅធម៌នានា ប្រែគម្ពីរព្រះត្រៃបិដក កសាងវត្តអារាម ។ល ។ លើសពីនេះទៀត លោកបាននិមន្តដឹកនាំ

គណៈប្រតិភូទៅប្រជុំផ្នែកពុទ្ធសាសនានៅប្រទេសបារាំង ឥណ្ឌូនេស៊ី ភូមា ស្រីលង្កា ជាដើម ។ ជាមួយសកម្មភាពនេះដែរ សម្ដេចបាននាំគណៈប្រតិភូទៅធ្វើទស្សនកិច្ចនៅកម្ពុជាក្រោម ដើម្បីផ្ដល់គំនិតរៀបចំវត្តអារាមជាច្រើន សម្រាប់ជនជាតិខ្មែរយើងនៅទីនោះធ្វើបុណ្យទាន និងជាមណ្ឌលជួបជុំទាក់ទងគ្នា ពិសេសរៀនអក្សរខ្មែរ ។

នៅគ.ស. ១៩៦៣ ប្រជាជនខ្មែរទាំងមូល បានថ្វាយឋានៈព្រះអង្គថា "សម្ដេចសង្ឃរាជថ្នាក់ទី ១" ហើយជាបណ្ឌិតអក្សរសាស្ត្រទី ១ នៅគ.ស. ១៩៦៤ ។ សម្ដេចចូលទិវង្គតនៅគ.ស. ១៩៦៩ ក្នុងព្រះជន្មាយុ ៨៦ព្រះវស្សា នាវត្តឧណ្ណាលោម រាជធានីភ្នំពេញ ។ ប្រជាជនខ្មែរទាំងអស់សុទ្ធតែគោរព កោតសរសើរ ចងចាំ និងប្រើប្រាស់ស្នាព្រះហស្តដ៏ថ្លៃថ្លារបស់លោករហូតដល់សព្វថ្ងៃនេះ ។

(ដកស្រង់ពី ព្រះរាជជីវប្រវត្តិសម្ដេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោថ្នាក់ទី១ គណៈមហានិកាយ)

## សំណួរ

១. តើសម្ដេចព្រះសង្ឃរាជ ជួន ណាត មានស្នាព្រះហស្តអ្វីខ្លះ?

២. តើស្នាព្រះហស្តមួយណាដែលល្បីល្បាញជាងគេ ?

៣. តើសម្ដេចព្រះសង្ឃរាជ ជួន ណាត មានទឹកចិត្តដូចម្ដេច ចំពោះប្រទេសជាតិ ?

៤. ក្នុងនាមជាអ្នកសិក្សា តើអ្នកត្រូវរៀនសូត្រអ្វីខ្លះពីព្រះអង្គ ?

## លំហាត់

ចូរស្រង់គុណនាមប្រក្រតី និងគុណនាមកំណត់ពីក្នុងអត្ថបទដាក់តាមខ្ទង់ក្នុងតារាងខាងក្រោមឱ្យបានត្រឹមត្រូវ ។

| គុណនាមប្រក្រតី | គុណនាមកំណត់ |
|---|---|
| | |

# ការតែងល្បះ

ក. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ដើម្បីបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| រៀនសូត្រ | ផ្សែងបារី | គោរព | ធម្មជាតិ |
| --- | --- | --- | --- |
| គ្រឿងញៀន | អាណាព្យាបាល | បច្ចេកទេស | |

១. កសិករគំរូ ជួយណែនាំញាតិមិត្តឱ្យធ្វើកសិកម្មតាម.................ទំនើប ។
២. សិស្សត្រូវចេះ.............វិន័យសាលា និងព្យាយាម............. ។
៣. ...............ត្រូវនាំកុមារទៅចាក់ថ្នាំបង្ការជំងឺឱ្យបានគ្រប់ចំនួនកំណត់ ។
៤. យុវជនគ្រប់រូប ត្រូវចៀសឱ្យផុតពី............................... ។
៥. សហគមន៍ល្អ មិនត្រូវមាន............................ឡើយ ។
៦. ការប្រើប្រាស់ផលិតផល...............មិនធ្វើឱ្យប៉ះពាល់សុខភាព ។

ខ. ចូរតែងល្បះដែលទាក់ទងនឹងរូបភាពខាងក្រោមឱ្យបាន៥ ល្បះ ។



# ការពណ៌នាអំពីជនគំរូ

ថ្ងៃមួយ កែវ បានទៅលេងផ្ទះ កន ដែលជាមិត្តរួមថ្នាក់ រស់នៅក្នុងភូមិផ្សេងគ្នា ។ កែវចាប់អារម្មណ៍នឹងភូមិរបស់កន ដែលមានការអភិវឌ្ឍច្រើនជាងពេលមុន ។

ចូរអានការសន្ទនារវាង កែវនិងកន ខាងក្រោម ៖

**កែវ :** កន! ឥឡូវនេះ ខ្ញុំឃើញភូមិឯងមានការរីកចម្រើនប្លែកពីពេលមុនឆ្ងាយណាស់ តើមកពីហេតុអ្វីទៅ ?

**កន :** កែវឯង មិនដឹងទេ ឬ? ភូមិខ្ញុំបានរីកចម្រើន គឺមកពីឥឡូវនេះ មេភូមិខ្ញុំបានរៀនសូត្របទពិសោធន៍ល្អ និងមានផែនការអភិវឌ្ឍភូមិច្បាស់លាស់ ។

**កែវ :** អ៊ីចឹងប្រធានភូមិឯង ពិតជាបានខិតខំប្រឹងប្រែងធ្វើឱ្យភូមិគាត់ចម្រើនលូតលាស់ដូចភូមិខ្ញុំដែរ ។

**កន :** មីងសុភាព ជាស្ត្រីមេភូមិម្នាក់ដែលមានភាពឈ្លាសវៃណាស់ ។ គាត់ឆាប់យល់ការងារ ចេះរៀបចំផែនការដើម្បីអភិវឌ្ឍភូមិ ។ គាត់ចេះធ្វើឱ្យប្រជាជនជឿជាក់ និងចូលរួមសហការ ព្រោះគាត់ស្មោះត្រង់ មិនកេងប្រវ័ញ្ចផលប្រយោជន៍ប្រជាជន ។ ម្យ៉ាងទៀត គាត់លះបង់ពេលវេលា និងកម្លាំងកាយចិត្ត ដើម្បីជួយប្រជាជនទាន់ពេលវេលា ។

**កែវ :** អូ! គាត់ពិតជាជនគួរឱ្យគោរពមែន!

## លំហាត់

ចូររៀបគ្នាជាក្រុមតូចៗ រួចរៀបរាប់ពីជនគំរូណាម្នាក់ ដែលអ្នកបានស្គាល់ច្បាស់ប្រាប់សមាជិកក្រុមរបស់អ្នក ។

# វីរបុរសក្រឡាហោមគង់



ក្រឡាហោមគង់ ជាមន្ត្រីខ្មែរស្នេហាជាតិមួយរូប ដែលបានតស៊ូប្រឆាំងនឹងការគាបសង្កត់របស់អាណានិគមនិយមបារាំង ។ លោកបានធ្វើពលិកម្មយ៉ាងធំធេង ដើម្បីរើបម្រះចេញពីនឹមត្រួតត្រារបស់បារាំង ។ លោកមានទឹកចិត្តអង់អាចក្លាហាន តស៊ូប្រឆាំងនឹងបរទេសឈ្លានពាន ។ បារាំងដឹងពីគោលជំហរ និងគំនិតរបស់លោក ក៏បានរកមធ្យោបាយចាប់លោក ។ លោកត្រូវពួកអាណានិគមបារាំងចាប់បាន និងយកទៅធ្វើ ទារុណកម្មដោយសម្ងាត់ ។

ព្រះទិនករលិចស្រឹមបាត់ទៅ ពេលព្រលប់ក៏ខិតចូលមកដល់ធ្វើឱ្យស្រអាប់គ្រប់ទិសទី ។ កប៉ាល់បារាំងបាននាំលោកឃ្លាតចេញពីវត្តឧណ្ណាលោម ឆ្ពោះទៅកាន់ទិសឧត្តរ ។ នៅលើនាវា ដៃទាំងពីររបស់លោកត្រូវជាប់ខ្នោះ ខ្លួនលោកត្រូវគេចងផ្អោបនឹងបំពង់ផ្សែង ។ ក្រឡាហោមគង់ត្រមង់ត្រមោចម្នាក់ឯង ទឹកមុខក្រៀមក្រំជាពន្លឹក ។ ប៉ុន្តែស្មារតីស្នេហាជាតិមាតុភូមិ ពុំបានធ្វើឱ្យលោកតក់ស្លុតឡើយ ទោះបីជាលោកបានដឹងខ្លួនច្បាស់ថា ត្រូវទទួលមរណភាពដោយសារដៃឃាតករបារាំងក៏ដោយ ។ នៅដង្ហើមចុងក្រោយលោកនឹកដល់គុណឪពុកម្តាយ ព្រះសង្ឃ ប្រជាជនខ្មែរ និងនឹកដល់កម្ពុជាមាតុភូមិជាទីស្នេហារបស់លោក ។

ការបាត់បង់វីរជនស្នេហាជាតិរូបនេះ ធ្វើឱ្យយើងសោកស្តាយ អាណិតអាសូរក្រៃលែង ។ ក្រឡាហោមគង់បានបាត់បង់ជីវិតចាកឆ្ងាយពីយើងពិតមែន ប៉ុន្តែកិត្តិនាម និងវីរភាពរបស់លោកបានមកសណ្ឋិតនៅជាប់នឹងដួងព្រលឹងកូនខ្មែរជានិច្ច ។

(ដកស្រង់និងកែសម្រួលពីសៀវភៅភាសាខ្មែរថ្នាក់ទី៥ ឆ្នាំ១៩៩៣ដោយគ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ)

## សំណួរ

១. តើក្រឡាហោមគង់បានធ្វើអ្វីខ្លះ ដើម្បីប្រទេសជាតិ ?

២. ហេតុអ្វីបានជាក្រឡាហោមគង់ប្រឆាំងនឹងអាណានិគមនិយមបារាំង ?

៣. តើក្រឡាហោមគង់មានទឹកចិត្តដូចម្ដេច ចំពោះប្រទេសជាតិ ?

៤. តើអ្នកមានទឹកចិត្តដូចម្ដេច ចំពោះវីរជនក្រឡាហោមគង់ ?

៥. តើអ្នកមានទឹកចិត្តដូចម្ដេច ចំពោះជាតិយើង ?

## ការពណ៌នាអំពីតួអង្គ

ចូរអានអត្ថបទខាងក្រោម ។ តើគេពណ៌នាអំពីតួអង្គដូចម្ដេចខ្លះ ?

សេនាមឿង ជាវីរជនដ៏អង់អាចក្លាហាន ។ លោកបានធ្វើពលិកម្មដ៏ធំធេងដើម្បីជាតិមាតុភូមិ ។

នៅក្នុងគ្រាដែលនគរខ្មែរកើតចម្បាំងជាមួយពួកសៀមឈ្លានពាន សេនាមឿងសុខចិត្តបូជាជីវិតទាំងខ្លួនលោក ប្រពន្ធ និងកូនពីរនាក់ទៀត ។ បេសកកម្មនេះ បង្ហាញពីវីរភាពដ៏មោះមុត ព្រោះលោកហ៊ានលោតចូលទៅក្នុងរណ្ដៅដែលមានសុទ្ធតែចម្រូងដើម្បីទៅកេណ្ឌទ័ពខ្មោចមកច្បាំងជាមួយទ័ពសៀម ។ ការលះបង់របស់សេនាមឿងបង្ហាញពីទឹកចិត្តស្នេហាជាតិមាតុភូមិយ៉ាងមុតមាំ ។ បេសកកម្មរបស់សេនាមឿង ប្រពន្ធកូន ពិតជាបាននាំមកនូវជោគជ័យជូននគរខ្មែរ ពោលគឺធ្វើឱ្យខ្មែររំដោះប្រទេសជាតិរួចផុតពីការត្រួតត្រារបស់ពួកសៀម ។ វីរភាពនេះ ធ្វើឱ្យកូនខ្មែរគ្រប់រូបនៅចងចាំជានិច្ច តាំងពីអតីតកាលរហូតដល់បច្ចុប្បន្ន ។

ដើម្បីសម្ដែងនូវការដឹងគុណ និងការគោរពចំពោះសេនាមឿង គេបានកសាងរូបសំណាកនិងកន្លែងសម្រាប់ធ្វើសក្ការបូជាចំពោះលោក ។ ហើយបានប្រសិទ្ធនាមថា“ អ្នកតាឃ្លាំងមឿង” ដែលមានទីតាំងនៅក្នុងខេត្តពោធិ៍សាត់ ។ បច្ចុប្បន្ន ប្រជាជនទូទៅតែងនាំគ្នាធ្វើការបួងសួង និងទៅគោរពបូជានៅទីនោះតាមទម្លាប់មិនដែលអាក់ខានឡើយ ។

## លំហាត់

ចូរសរសេរអត្ថបទខ្លីមួយពណ៌នាអំពីវីរភាពរបស់តួអង្គត្រីក្រាញ់នៅក្នុងរឿង " ចចកនិងកំពឹស" ដែលអ្នកបានរៀនរួច ឬរៀបរាប់ពីតួអង្គណាមួយនៅក្នុងរឿងដែលអ្នកធ្លាប់បានចេះចាំ ។

ដើម្បីពណ៌នាតួអង្គគេត្រូវរៀបរាប់តាមគម្រោងខាងក្រោម ៖

**គម្រោងតែង**

១. សេចក្ដីផ្ដើម

ឈ្មោះតួអង្គនិងឈ្មោះរឿង

២. តួសេចក្ដី

- រូបសម្បត្តិ ៖ រូបរាង សម្បុរ មុខរបរ (ប្រសិនបើមាន)
- ចរិយាសម្បត្តិ ៖ ស្លូត កាច ព្យាយាម ...(តាមសាច់រឿងបញ្ជាក់)
- សកម្មភាព (តាមសាច់រឿងបញ្ជាក់)

៣. សេចក្ដីបញ្ចប់

ចំណាប់អារម្មណ៍របស់អ្នកសរសេរ

មេរៀនទី

# ២ សម្បត្តិអក្សរសិល្ប៍




ខ្មែរជាជាតិសាសន៍មួយដែលមានវប្បធម៌ អរិយធម៌រុងរឿងតាំងពីសម័យបុរាណ ។ បុព្វបុរសយើង បានបន្សល់ទុកមរតកអក្សរសិល្ប៍យ៉ាងច្រើនសន្ធឹកសន្ធាប់ ។ រឿងខ្លះត្រូវបានកត់ត្រាក្នុងសាស្ត្រាស្លឹករឹត រឿងខ្លះទៀតត្រូវបានចងក្រងជាសៀវភៅ ។ ប្រជាជនខ្មែរភាគច្រើន បានលើកយករឿងមួយចំនួនមកនិទានឱ្យកូនចៅស្តាប់ នៅពេលទំនេរពីការងារ ។ ចូរអ្នកមើលរូបភាពខាងលើ តើអ្នកស្គាល់អ្វីខ្លះ ?

## ការឆ្លើយនឹងសំណួរដោយផ្អែកលើអំណះអំណាង

ដើម្បីឆ្លើយនឹងសំណួរ ឬពន្យល់គំនិតអ្វីមួយឱ្យកាន់តែច្បាស់លាស់ គេតែងលើកយកអំណះអំណាង ឬភ័ស្តុតាងជាក់ស្តែងដែលធ្លាប់ជួបប្រទះ ឬដកស្រង់ចេញពីក្នុងរឿងណាមួយមកបញ្ជាក់ ។

ចូរអានរឿងខាងក្រោម និងឆ្លើយនឹងសំណួរដោយស្រង់អំណះអំណាងពីរឿងមកបង្ហាញ ។

### រឿង ចាបស្រុកនិងចាបព្រៃ

កាលពីព្រេងនាយ មានចាបស្រុក និងចាបព្រៃដើររកស៊ីដោយពួកជារៀងរាល់ថ្ងៃ ។ ខាងចាបស្រុកមានមេប្រដៅថា បើរកស៊ីកុំជជែកឈ្លោះគ្នាឱ្យព្រានឮមាត់ ឱ្យប្រយ័ត្នខ្លួន បើព្រានវាយលប់ត្រូវ ឱ្យបប្ចួលគ្នាខំហើរទូលលប់ឱ្យរបើក ដើម្បីឱ្យរស់រួចជីវិត ។ ពួកចាបស្រុកធ្វើតាមដំបូន្មាន បានរួចជីវិតតែរៀងៗមក ។ មានកាលថ្ងៃមួយ ចាបព្រៃនិងចាបស្រុកហើរចេញទៅរកស៊ី ក៏ជួបប្រទះហ្វូងគ្នានៅលើដើមត្រែងមួយគុម្ព ។ ពួកចាបព្រៃទំនៅខាងក្រោម ពួកចាបស្រុកទំនៅខាងលើក៏បាក់មែកត្រែងពីលើមកត្រូវក្បាលចាបព្រៃ ។ ចាបព្រៃនិយាយប្រកាន់ថា ពួកចាបស្រុកកាច់មែកត្រែងទម្លាក់មកឱ្យត្រូវក្បាលពួកខ្លួន ។ ចាបស្រុកបានប្រាប់ថា ពួកខ្លួនមិនបានកាច់មែកត្រែងឱ្យបាក់ទេ គឺមែកត្រែងវាបាក់ធ្លាក់ខ្លួនឯងទេ ។ ពួកចាបព្រៃមិនពិចារណាក៏បប្ចួលគ្នាបង្កើតជម្លោះនឹងពួកចាបស្រុក រហូតឮមាត់គឹកកងរំពងឡើង ។ ព្រានឮមាត់ចាប ក៏យកលប់ទៅវាយត្រូវទាំងអស់គ្នា ។ ចាបទាំងពីរពួកនៅតែឈ្លោះប្រកែកគ្នា ទាល់តែព្រានចាប់បានពិឃាតក្ស័យអស់ទៅ ។

(ដកស្រង់និងសម្រួលពីប្រជុំរឿងព្រេងខ្មែរភាគទី ២)

**សំណួរ ៖** ហេតុអ្វីបានជាព្រានសម្លាប់ពួកចាបទាំងពីរពួកបាន ?

**ចម្លើយ ៖** បានជាព្រានសម្លាប់ពួកចាបទាំងពីរពួកបាន ពីព្រោះពួកចាបទាំងពីរពួកមិនមូលកម្លាំងគ្នារកវិធីដោះខ្លួនចេញពីលប់ទេ ដោយរវល់តែឈ្លោះប្រកែកគ្នា ។ ជាពិសេស ចាបស្រុកភ្លេចដំបូន្មានមេបា ។

**អំណះអំណាង** ៖ តាមសាច់រឿងបានបញ្ជាក់ថា ពីមុនមកពួកចាបស្រុកធ្វើតាមដំបូន្មានមេបា គឺរកស៊ីមិនដណ្ដើមគ្នាឱ្យឮមាត់ទេ ហើយពេលណាព្រានវាយលប់ត្រូវ ពួកវាតែងនាំគ្នាហើរទូលលប់បានរួចជីវិតរហូតមក ។ ប៉ុន្តែនៅពេលនេះ ចាបស្រុកមិនអាចអនុវត្តដំបូន្មានមេបាបានទេ ដោយសារតែជាប់ដៃក្នុងជម្លោះជាមួយពួកចាបព្រៃ ធ្វើឱ្យឮសំឡេងដល់ព្រាន ទើបត្រូវព្រានសម្លាប់បាន ។ ម្យ៉ាងទៀត ពួកចាបទាំងពីរពួកមិនមូលកម្លាំងគ្នា ខ្វះការសាមគ្គីគ្នានៅគ្រាមានអាសន្ន ។

## លំហាត់

### រឿង មេអំបៅនិងដង្កូវ

មានមេអំបៅមួយទើបនឹងហើរចេញពីសម្បុក ។ វាហើរលេងយ៉ាងសប្បាយរីករាយពីទីកន្លែងមួយទៅទីកន្លែងមួយ ។ លុះវាហើរទៅជិតផ្ការំយោលមួយ ហើយបម្រុងនឹងទំ វាបានឃើញដង្កូវមួយ មានរូបរាងអាក្រក់គួរឱ្យខ្ពើម ។ មេអំបៅនិយាយទៅកាន់ដង្កូវ ៖

- យី! សត្វនេះអីក៏អាក្រក់ម្ល៉េះ! នរណាឱ្យឯងមកលេងលើផ្កានេះ ហើយធ្វើឱ្យផ្កាប្រឡាក់ប្រឡូសយ៉ាងនេះ ។ ចូរឯងដើរចេញទៅ!

ដង្កូវឆ្លើយតបវិញ ៖

- ឯងថានេះ មិនពិតទេ! ផ្កានេះមិនមែនជារបស់ឯងតែម្នាក់ទេ តែវាជារបស់យើងដែរ ។ ឯងភ្លេចហើយ ឬ ? កាលពីព្រឹកមិញ ឯងនៅជាដង្កូវនៅឡើយ ហើយមានសភាពដូចខ្ញុំអ៊ីចឹងដែរ ។ ម្ដេចឯងឆាប់ភ្លេចម្ល៉េះ? ដូច្នេះ ផ្កានេះជាកម្មសិទ្ធិរបស់យើងទាំងពីរនាក់ ។

កូនមេអំបៅឮហើយអៀនខ្លួន ក៏ហើរគេចបាត់ទៅ ។

## សំណួរ

តើកូនមេអំបៅជាកូនសត្វដូចម្ដេច ? ចូរឆ្លើយនឹងសំណួរនេះ ដោយលើកយកអំណះអំណាងពីក្នុងរឿងមកបញ្ជាក់ ។

# រឿង ភ្នំប្រុស ភ្នំស្រី

កាលពីព្រេងនាយ មានស្តេចស្រីមួយអង្គ ព្រះនាមស្រីអយុធ្យា ។ រជ្ជកាលស្តេចអង្គនេះ ពួកស្រីៗត្រូវទៅដណ្តឹងប្រុសធ្វើជាប្តី ។ ស្រីៗមានរូបឆោមពុំស្អាតពិបាករកប្តីណាស់ ព្រោះពួកប្រុសៗពុំយកធ្វើជាប្រពន្ធ ។ លុះមកដល់រាជ្យស្តេចក្រោយៗ ពួកស្រីៗមានគំនិតរើបម្រះពីប្រពៃណីស្រីដណ្តឹងប្រុស ។ ពួកស្រីៗ បានជំនុំគ្នាដើម្បីរកវិធីដោះស្រាយ ៖ “ពួកយើងជាស្រី យើងដណ្តឹងប្រុសដូចជាមិនសមសោះ យើងគួរតែបបួលប្រុសៗភ្នាល់គ្នា ដោយលើកដីពូនជាភ្នំ ។ បើពួកស្រីៗឈ្នះ ឱ្យពួកប្រុសៗមកដណ្តឹងស្រីវិញម្តង” ។ គិតហើយ ពួកស្រីៗក៏ទៅនិយាយបបួលពួកប្រុសៗភ្នាល់ ៖“យើងភ្នាល់គ្នាពូនភ្នំ ដោយលើកដីពូនតាំងពីព្រលប់រហូតដល់ផ្កាយព្រឹករះ សឹមយើងឈប់” ។ ពួកប្រុសៗ ក៏យល់ព្រមតាមខសន្យានេះ ។ ទាំងខាងស្រី ទាំងខាងប្រុស ក៏ចាត់មេកំណែនឱ្យដើរកែនគ្រប់ចំនួនខាងប្រុសនិងខាងស្រី រួចវែកទូលតាមសមត្ថភាពរៀងៗខ្លួន ។ លុះធ្វើការបានប្រហែលជា ៤ ឬ៥ ម៉ោង ពួកស្រីៗមានឧបាយកល ក៏នាំគ្នាបង្ហូតគោមមួយយ៉ាងខ្ពស់នៅជ្រុងឦសានភ្នំ ។ ពួកប្រុសៗមើលទៅលើឃើញគោមស្រីៗបង្ហូត ស្មានថាផ្កាយព្រឹករះ ក៏បបួលគ្នាឈប់ធ្វើការនាំគ្នានិទ្រាលក់គ្មានសល់ម្នាក់ ។ ឯពួកស្រីៗ ក៏នាំគ្នាលើកដីពូនភ្នំដរាបដល់ផ្កាយព្រឹកមែនទែនរះទើបឈប់ ។

លុះដល់មាន់រងាវ ពួកប្រុសៗភ្ញាក់ឡើងស្រាប់តែឃើញផ្កាយព្រឹកមែនទែនទើបនឹងរះ ។ ពួកប្រុសៗ លាន់មាត់៖“យើងទាំងអស់គ្នាខុសហើយ! ផ្កាយព្រឹកមែនទែនទើបតែរះសោះ” ។ ពួកប្រុសៗនាំគ្នាក្រឡេកទៅមើលភ្នំពួកស្រីៗ មានទំហំធំហើយខ្ពស់ជាងភ្នំរបស់ខ្លួន ក៏មានសេចក្តីអៀនអន់ក្នុងចិត្ត ព្រោះចាញ់កលស្រីៗ ។ តាំងពីពេលនោះមក ពួកប្រុសៗក៏ទៅដណ្តឹងស្រីៗធ្វើជាភរិយា រហូតដល់សព្វថ្ងៃ ។

(សម្រួលពីប្រជុំរឿងព្រេងខ្មែរភាគទី៥)

## សំណួរ

១. តើក្នុងរជ្ជកាលស្តេចស្រីអង្គណា ដែលស្រីៗទៅដណ្តឹងប្រុសធ្វើប្តី ?
២. ហេតុអ្វីបានជាស្រីៗមានគំនិតរើបម្រះ ?
៣. តើស្រីៗរើបម្រះតាមវិធីណា ?
៤. ហេតុអ្វីបានជាពួកស្រីៗភ្នាល់ឈ្នះប្រុសៗ ?
៥. តើដំណើររឿងភ្នាល់គ្នាពូនភ្នំកើតឡើងនៅកន្លែងណា ? នៅពេលណា ?
៦. តើរឿងនេះមានព្រឹត្តិការណ៍អ្វីខ្លះ ?
៧. តើស្រីៗឈ្នះប្រុសៗ ដោយវិធីណា ? ចូរលើកយកអំណះអំណាងនៅក្នុងរឿងមកបញ្ជាក់ ។

## លំហាត់

ក. តើរឿងខាងលើមានគំនិតអប់រំដូចម្តេច ? ចូរគូសសញ្ញា ✓ នៅក្នុងប្រអប់ចម្លើយត្រឹមត្រូវមួយ ។

☐ ១. ត្រូវចេះគោរពសិទ្ធិគ្នាទៅវិញទៅមក ។
☐ ២. ត្រូវចេះប្រើប្រាជ្ញារួមផ្សំ ទើបទទួលបានជោគជ័យ ។
☐ ៣. ត្រូវរកគេមកជួយ ទើបទទួលបានជោគជ័យ ។

ខ. ចូរបង្ហាញអារម្មណ៍របស់ពួកប្រុសៗ នៅពេលចាញ់កលល្បិចពួកស្រីៗ ដោយជ្រើសរើសចម្លើយត្រឹមត្រូវមួយ ។

☐ ១. ប្រុសៗសប្បាយចិត្ត ព្រោះបានប្រកួតជាមួយស្រីៗ ។
☐ ២. ប្រុសៗខ្វល់ខ្វាយ ព្រោះចង់ឈ្នះស្រីៗ ។
☐ ៣. ប្រុសៗខកចិត្តនិងខ្មាសអៀន ព្រោះចាញ់កលស្រីៗ ។

# រឿង ក្រពើនិងអ្នកបររទេះ

ក្រោយពីស្តាប់រឿងនិទានរួច ចូរឆ្លើយនឹងសំណួរ ។




## សំណួរ

១. តើក្រពើរស់នៅទីណា?

២. ហេតុអ្វីបានជាក្រពើសុំដោយសាររទេះតា ?

៣. តើក្រពើចង់បានអ្វីពីតា  នៅពេលទៅដល់បឹងមានទឹក ?

៤. តើតាយល់ព្រមតាមសំណើរបស់ក្រពើដែរ ឬទេ ? ព្រោះអ្វី ?

៥. ហេតុអ្វីបានជាទន្សាយព្រមជួយតា ?

៦. តើសត្វរមិលគុណនេះទទួលលទ្ធផលដូចម្តេច ?

# លំហាត់

ក. តើតាមានអារម្មណ៍យ៉ាងណានៅពេលក្រពើចង់ស៊ីគាត់ ? ចូរគូសសញ្ញា✓ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវមួយ ។

☐ ១. តាភិតភ័យព្រោះខ្លាចក្រពើស៊ី ។

☐ ២. តាខឹងនឹងសត្វក្រពើ ។

☐ ៣. តាមានចិត្តអាណិតសត្វក្រពើ ។

ខ. តើរឿងនេះ កើតឡើងនៅកន្លែងណា ? ចូរគូសសញ្ញា✓ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវមួយ ។

☐ ១. ផ្ទះតាបររទេះ ។

☐ ២. បឹងដែលរីងទឹកអស់ ។

☐ ៣. ក្បែរបឹងមានទឹកច្រើន ។

☐ ៤. លើទូករទេះ ។

គ. តើរឿងនេះកើតឡើងនៅពេលណា ? ចូរគូសសញ្ញា✓ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវមួយ ។

☐ ១. នៅរដូវភ្លៀង ។

☐ ២. នៅរដូវប្រាំង ។

☐ ៣. នៅរដូវចម្រូត ។

ឃ. តើរឿងនេះចង់អប់រំដូចម្ដេច ? ចូរគូសសញ្ញា✓ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវមួយ ។

☐ ១. ត្រូវដឹងគុណអ្នកដែលបានជួយយើង ។

☐ ២. មិនត្រូវតបគុណអ្នកដែលបានជួយយើង ។

☐ ៣. ត្រូវស៊ូទ្រាំនៅពេលគេធ្វើបាបយើង ។

## គុណនាមប្រក្រតី

ចូរអានឧទាហរណ៍ខាងក្រោម ៖

១. ជូនតាយើងបន្សល់ទុករឿងនិទានពីរោះៗច្រើនណាស់ ។

២. រឿងទាំងនោះបង្កប់ការអប់រំល្អៗ ។

៣. ខ្ញុំចូលចិត្តអានរឿងខ្លីៗពីសម័យមុន ។

ពាក្យ"ពីរោះ"បញ្ជាក់លក្ខណៈរបស់នាម"រឿងនិទាន" ។

ពាក្យ"ល្អ "បញ្ជាក់លក្ខណៈរបស់នាម"ការអប់រំ" ។

ពាក្យ"ខ្លី"បញ្ជាក់លក្ខណៈរបស់នាម"រឿង" ។

ពាក្យ ពីរោះ ល្អ ខ្លី ជា" គុណនាមប្រក្រតី" ។

តាមឧទាហរណ៍ខាងលើ យើងឃើញថាគុណនាមមានតួនាទីបញ្ជាក់លក្ខណៈរបស់នាម ។ វាស្ថិតនៅខាងស្តាំនាម ។

គុណនាមប្រក្រតីបញ្ជាក់លក្ខណៈរបស់នាម ។

គុណនាមប្រក្រតីមាន : ខ្ពស់ ទាប កាច ស្លូត ប្រៃ សាប ស្រួច ទាល ឧស្សាហ៍ ខ្ជិល ស្អាត កខ្វក់ ខ្លាំង ខ្សោយ... ។

### លំហាត់

ក. ចូរស្រង់គុណនាមប្រក្រតីក្នុងល្បះខាងក្រោម ៖

១. សុខពាក់អាវស ស្ពាយកាបូបខ្មៅទៅសាលារៀន ។

២. ធីតាស្លៀកសំពត់ខ្លី ពាក់អាវដៃវែង យួរត្រកតូចទៅផ្សារ ។

ខ. ចូរបង្ហាញពាក្យនាមនិងគុណនាមក្នុងអត្ថបទខាងក្រោម ។

រាល់ពេលទំនេរ ជីដូនខ្ញុំនិទានរឿងប្លែកៗដែលមានការអប់រំល្អៗឱ្យចៅស្តាប់ ។ រឿងខ្លះមានតួអង្គតិច តែរឿងខ្លះមានតួអង្គច្រើន ។ តួអង្គល្អច្រើនបានទទួលជោគជ័យនៅចុងបញ្ចប់នៃរឿង ឯតួអង្គអាក្រក់ច្រើនទទួលបរាជ័យ ឬស្លាប់ ។

# ពាក្យសូរដូច

ពាក្យខ្លះមានសូរដូចគ្នា តែសំណេរនិងន័យពុំដូចគ្នាទេ ។

ចូរអានឧទាហរណ៍ខាងក្រោម ។ តើពាក្យណាខ្លះមានសូរដូចគ្នា ?

១. ខ្ញុំទុកអីវ៉ាន់នៅលើរថយន្ត ហើយខ្ញុំដើរកម្សាន្តតាមមាត់សមុទ្រ ដើម្បីបំបាត់ទុក្ខ ។

ពាក្យ"ទុក" និង"ទុក្ខ"មានសូរដូចគ្នា ប៉ុន្តែន័យរបស់វាខុសគ្នា ។

ទុក (កិ) ដាក់អ្វីៗនៅទីណាមួយឱ្យបានគង់នៅ ។

ទុក្ខ (គុ) សេចក្ដីព្រួយ សេចក្ដីលំបាក ។

២. ប្រាសាទនាគព័ន្ធ មានរូបចម្លាក់នាគពីរព័ន្ធកន្ទុយគ្នា តែមិនមែននាគចំនួនពីរពាន់ទេ ។

ពាក្យ"ព័ន្ធ" និង"ពាន់" មានសូរដូចគ្នា ប៉ុន្តែន័យរបស់វាខុសគ្នា ។

ព័ន្ធ (កិ) ទាក់ទាក់ព័ន្ធលើគ្នា ។

ពាន់ (គុ ចំនួន) ចំនួន១០០ដប់ដង (១០០ × ១០)

ពាក្យ"ទុកនិងទុក្ខ"ជាពាក្យសូរដូច ។

ពាក្យ"ព័ន្ធនិងពាន់"ក៏ជាពាក្យសូរដូចដែរ ។

ពាក្យសូរដូច ជាពាក្យពីរ ឬច្រើនដែលមានសូរដូចគ្នាតែសំណេរនិងន័យខុសគ្នា ។

## លំហាត់

ក. ចូររកពាក្យសូរដូច ក្នុងល្បះខាងក្រោម រួចពន្យល់ន័យនៃពាក្យទាំងនោះ ។

១. ប្រាសាទអង្គរវត្ត មានកេរ្តិ៍ឈ្មោះល្បីគ្រប់ទិសទី ។ ប្រាសាទនេះជាកេរដំណែលរបស់បុព្វបុរសយើង ។

២. ថ្ងៃអាទិត្យមុន ខ្ញុំទៅលេងខេត្តរតនគិរី ។ ខ្ញុំចេញដំណើរពីភ្នំពេញនៅម៉ោង ៦ ព្រឹក ។ ខ្ញុំបានស្នាក់នៅទីនោះចំនួនពីរថ្ងៃ ។

ខ. ចូររកពាក្យសូរដូចនឹងពាក្យ ដុះ សប់ បត់ ។

# ស្នាដៃកវីនិងអ្នកនិពន្ធខ្មែរ



កវី អ្នកនិពន្ធខ្មែរសម័យបុរាណ បានបន្សល់ទុកស្នាដៃអក្សរសិល្ប៍ជាច្រើនដល់កុលបុត្រ កុលធីតាជំនាន់ក្រោយ សម្រាប់អានកម្សាន្តនិងអប់រំ ។ រឿងខ្លះ ជារឿងបែបប្រលោមលោកបុរាណសរសេរជាពាក្យកាព្យដូចជារឿង កាកី ទុំទាវ... ។ រឿងខ្លះទៀតជារឿងបែបប្រលោមលោកសម័យ សរសេរជាពាក្យរាយដូចជា រឿងផ្កាស្រពោន កុលាបប៉ៃលិន ... ។ កវី និពន្ធតាក់តែងឃ្លាឃ្លោងពីរោះរណ្ដំធ្វើឱ្យអ្នកអាន អ្នកស្ដាប់ជក់ចិត្តតាមដំណើររឿង ។ ជួនកាលធ្វើឱ្យពួកគាត់ខឹងនឹងតួអង្គកាច ស្រឡាញ់ អាណិតតួអង្គស្លូត ។ រឿងខ្លះ មានដំណើររឿងវែង តែស្ដាប់ទៅជក់ចិត្ត អាចបំបាត់ការអផ្សុកបាន ។ រឿងខ្លះកំប្លែងខ្លីតែមានន័យអប់រំល្អ ធ្វើឱ្យអ្នកស្ដាប់ អ្នកអានផ្ទុះសំណើច រសាយទុក្ខព្រួយបានមួយដងមួយគ្រា ។

ក្រៅពីស្នាដៃដែលមានឈ្មោះអ្នកនិពន្ធ និងកាលបរិច្ឆេទរឿងត្រឹមត្រូវ ក៏នៅមានរឿងខ្លះទៀត ដែលគេចេះចាំតៗគ្នា ពុំមានឈ្មោះអ្នកនិពន្ធ និងកាលបរិច្ឆេទត្រឹមត្រូវឡើយ ។ យើងតែងហៅថា អក្សរសិល្ប៍ប្រជាប្រិយ ។ អក្សរសិល្ប៍ប្រជាប្រិយ ជាអត្ថបទរឿងខ្លីនិយាយទាក់ទងនឹងប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ ប្រពៃណី ជីវភាពប្រជាជន ហើយអប់រំប្រជាពលរដ្ឋយើងកុំឱ្យប្រព្រឹត្តអំពើអាក្រក់ កុំឱ្យមានចិត្តនិន្ទាឈ្នានីស ចេះស្រឡាញ់រួមកម្លាំងគ្នាកសាងគ្រួសារ និងសង្គមជាតិឱ្យរីកចម្រើនជានិច្ច ។

## សំណួរ

១. តើកវី អ្នកនិពន្ធតាក់តែងរឿងដើម្បីអ្វី ?

២. តើអ្នកចូលចិត្តអានអត្ថបទរឿងបុរាណ ដែលសរសេរជាពាក្យកាព្យដែរ ឬទេ? ពីព្រោះអ្វី ?

៣. ក្នុងអត្ថបទខាងលើ តើអត្ថបទអក្សរសិល្ប៍មានប៉ុន្មានប្រភេទ ? មានប្រភេទអ្វីខ្លះ ?

៤. ក្នុងចំណោមអត្ថបទអក្សរសិល្ប៍ទាំងនោះ តើអ្នកចូលចិត្តអត្ថបទប្រភេទណា ? ព្រោះអ្វី ?

## លំហាត់

ចូរអ្នកស្រង់ពាក្យដែលជាគុណនាមប្រក្រតីពីពាក្យមួយចំនួនខាងក្រោម ។

កុលបុត្រកុលធីតាជំនាន់ក្រោយ តួអង្គកាច តួអង្គស្លូត ដំណើររឿងវែង ប្រព្រឹត្តអំពើអាក្រក់ កុំឱ្យមានចិត្តឈ្នានីស ។

# ការនិទានរឿងឡើងវិញ

អ្នកធ្លាប់បានអាន និងស្ដាប់រឿងជាច្រើនមកហើយ ជួនកាលអ្នកបាននិទានរឿងទាំងនោះឱ្យមិត្តភក្ដិ ឬបងប្អូនអ្នកស្ដាប់ផងដែរ ។

ការនិទានរឿងឡើងវិញ គឺជាការនិយាយឡើងវិញតាមលំដាប់លំដោយព្រឹត្តិការណ៍ក្នុងរឿងដោយសម្ដីខ្លួនផ្ទាល់ ។ ក្នុងការនិទាន អ្នកត្រូវរក្សាទុកតួអង្គ កាលអាកាសរឿង ចំណុចសំខាន់ៗ ឬព្រឹត្តិការណ៍សំខាន់ៗ ហើយអាចកាត់ចោលផ្នែកមិនចាំបាច់ ។

ចូរអានអត្ថបទអំណានរឿង “ភ្នំប្រុស ភ្នំស្រី” រួចនិទានរឿងនេះឡើងវិញដោយផ្អែកលើតួអង្គ និងកាលអាកាសខាងក្រោម ៖

១. តួអង្គ ៖ ពួកប្រុសៗ ពួកស្រីៗ ស្ដេចស្រីអយុធ្យា

២. កាលអាកាស (ពេលវេលា និងទីកន្លែងរឿង) ៖

- កាលពីព្រេងនាយ ក្នុងរជ្ជកាលស្ដេចស្រីអយុធ្យានិងស្ដេចក្រោយៗ តាំងពីព្រលប់រហូតដល់ផ្កាយព្រឹករះ
- ជ្រុងឦសានភ្នំ

៣. ព្រឹត្តិការណ៍ ៖

- ក្នុងរជ្ជកាលស្ដេចស្រីអយុធ្យា ស្រីៗដណ្ដឹងប្រុសធ្វើប្ដី ។
- លុះដល់រជ្ជកាលស្ដេចក្រោយៗ ស្រីៗមានគំនិតរើបម្រះពីប្រពៃណីស្រីដណ្ដឹងប្រុស ។
- ស្រីៗបបួលប្រុសៗភ្នាល់លើកដីពូនភ្នំ ។
- ស្រីៗប្រើឧបាយកលបង្ហូតគោម នៅជ្រុងឦសានភ្នំបន្លំជាផ្កាយព្រឹករះ ។
- ប្រុសៗចាញ់ក៏សុខចិត្តស្ដីដណ្ដឹងស្រីៗ ធ្វើជាភរិយារហូតដល់សព្វថ្ងៃ ។

ក្រោយពីអ្នកបាននិទានរឿងឡើងវិញឱ្យមិត្តអ្នកស្ដាប់រួចហើយ ចូរអ្នកឆ្លើយនឹងសំណួរខាងក្រោម ៖

១. តើរវាងរឿងដែលអ្នកបានអាន និងរឿងដែលអ្នកនិទានឡើងវិញ មានភាពខុសគ្នាដូចម្ដេច ?

២. តើរឿងដែលអ្នកនិទានឡើងវិញ បានរក្សាខ្លឹមសារដើមគ្រប់គ្រាន់ដែរ ឬទេ ?

# ការតាក់តែងរឿងខ្លី

ចូរអានរឿងខ្លីខាងក្រោម ៖

## រឿង កសិករភ្ញាក់ខ្លួន

ពូព្រឹងជាកសិករក្រីក្រម្នាក់ នៅក្នុងភូមិដាច់ស្រយាលមួយ ។ គាត់ជាបុរសពោះម៉ាយ មានកូនពីរនាក់ ។ ថ្ងៃមួយគាត់បានឃើញមេសារិកាកែវមួយ កំពុងបញ្ចុកចំណីកូននៅលើដើមឈើ ក្បែរស្រែរបស់គាត់ ។ ដោយចង់ឱ្យកូនគាត់បានបរិភោគសាច់សត្វ គាត់បានយកចម្ពាមកៅស៊ូមកបាញ់មេសារិកានោះស្លាប់ទៅ ។ គាត់យកសត្វនោះ ទៅធ្វើម្ហូបឱ្យកូនទទួលទាន ។

ក្រោយមក កូនសារិកាយំសោករកមេឥតឈប់ឈរ ។ ពូព្រឹងអាណិតកូនសត្វខ្លាំងណាស់ ។ គាត់គិតថា គាត់មិនគួរសម្លាប់មេសារិកានោះសោះ ។ គាត់និងកូនបានឆ្ងាញ់មួយពេល ធ្វើឱ្យកូនសត្វព្រាត់ប្រាសមេ កំព្រាអស់មួយជីវិត ។ តាំងពីពេលនោះមក ពូព្រឹងលែងហ៊ានបៀតបៀនជីវិតសត្វតទៅទៀត ។

រឿងខាងលើនេះមាន ៖

១. តួអង្គ ៖ ពូព្រឹង  កូនពូព្រឹង  មេសារិកា  និងកូនសារិកា

២. កាលអាកាសរឿង ៖ ភូមិដាច់ស្រយាលមួយ លើដើមឈើ ថ្ងៃមួយ

៣. ព្រឹត្តិការណ៍ ៖

- ពូព្រឹងបាញ់សម្លាប់មេសារិកា ។
- កូនសារិកាយំរកមេ ។

## លំហាត់

ផ្អែកតាមគំរូខាងលើ ចូរអ្នករៀបចំសរសេររឿងខ្លីមួយ ដោយបង្កើតខ្លឹមសាររឿងខ្លួនឯង ។

មុននឹងសរសេរអ្នកត្រូវកំណត់ ៖

១. តួអង្គ

២. កាលអាកាសរឿង (ទីកន្លែង និងពេលវេលាដែលរឿងបានកើតឡើង)

៣. ព្រឹត្តិការណ៍ (តួអង្គបានធ្វើអ្វី ឬជួបហេតុការណ៍អ្វីខ្លះ )

៤. បង្កប់គំនិតអប់រំ (មានបំណងឱ្យអ្នកអានកែប្រែទម្លាប់ ឬធ្វើអំពើល្អអ្វីខ្លះ)

មេរៀនទី ៣

# កំណាព្យខ្មែរ




កំណាព្យ ជាអត្ថបទមួយបែបដែលមានតាំងពីយូរលង់ណាស់មកហើយ ។ កំណាព្យខ្មែរមានច្រើនបទ ហើយត្រូវបានគេប្រើប្រាស់ក្នុងគោលបំណងផ្សេងៗគ្នា ។ បទជាមូលដ្ឋានរបស់កំណាព្យខ្មែរយើងមាន បទកាកគតិ បទព្រហ្មគីតិ បទពំនោល បទពាក្យប្រាំពីរ ។ បទនីមួយៗសុទ្ធតែពីរោះរណ្ដំណែងណង ប្លែកៗគ្នាគួរឱ្យចូលចិត្ត ។

## ពាក្យចួន

កាលណាគេនិយាយពីកំណាព្យ គេតែងផ្តោតអារម្មណ៍ទៅលើចំណាប់ចួន ឬពាក្យចួន ។

ចូរសូត្រកំណាព្យខាងក្រោម រួចកត់សម្គាល់ពាក្យមានអក្សរដិត ។

**បទកាកគតិ**

| | | |
|---|---|---|
| ឃើញគេឬកល្អ | ទោះបីមានក្រ | យកគេជាញាតិ |
| គួររាប់អ្នកក្រៅ | ដៅអ្នកឯទៀត | រាប់រើសមារយាទ |
| | សុចរិតត្រឹមត្រូវ ។ | |
| រៀនបទរៀនបាទ | កុំកោងហួសខ្នាត | កុំភ្លាត់ហួសផ្លូវ |
| កុំភ្លើនភ្លេចម៉ែ | កុំប្រែហួសឪ | ឃើញចាស់សក់ស្កូវ |
| | កុំសូវមើលងាយ ។ | |

(ដកស្រង់ចេញពីច្បាប់ក្រមង៉ុយទំព័រទី២)

ក្នុងវគ្គទី ១ ៖ ពាក្យ "ល្អ" និងពាក្យ "ក្រ" មានសូរស្រៈ [អ] ដូចគ្នា ។ ពាក្យ"ញាតិ"ពាក្យ"ទៀត"និង"យាទ" មានសូរស្រៈ[អ៊ា] ប្រកបនឹង[ត]ដូចគ្នា ។

ក្នុងវគ្គទី ២ ៖ ពាក្យ"បាទ" និងពាក្យ"ខ្នាត" មានសូរស្រៈ[អា]ប្រកបនឹង[ត] ដូចគ្នា ។ ពាក្យ"ផ្លូវ" ពាក្យ "ឪ"និងពាក្យ"ស្កូវ" មានសូរស្រៈ[អូ]ប្រកបនឹង[វ] ដូចគ្នា ។ ពាក្យ"ត្រូវ" ក្នុងវគ្គទី១ និងពាក្យ"ផ្លូវ" ក្នុងវគ្គទី២មានសូរស្រៈ[អូ]ប្រកបនឹង[វ]ដូចគ្នា ។

ពាក្យទាំងអស់នេះជាពាក្យចួន ។

ពាក្យចួន គឺជាពាក្យទាំងឡាយណាដែលមានសូរស្រៈដូចគ្នា ឬមានសូរស្រៈប្រកបនឹងព្យញ្ជនៈដូចគ្នា ឬស្រដៀងគ្នា ។

## លំហាត់

ចូរអ្នកសូត្រកំណាព្យខាងក្រោម រួចរកពាក្យចួនក្នុងវគ្គ និងពាក្យចួនឆ្លងវគ្គ ។

### ច្បាប់ល្បើកថ្មី

(បទកាកគតិ)

កូនអើយកុំនោត បើចង់បានត្នោត ដាំដោយកៀនកោះ
ដីទួលចម្ការ ឯណាចន្លោះ ដាំជារបោះ
ជាយជួររបង ។

របៀបចម្ការ ថែទាំរក្សា យូរៗស្រាស់ម្តង
ស្រាស់ឱ្យត្រូវជួរ មើលគួរសមផង កុំបើកមុជឆ្លង
ទៅស្រាស់ខាងក្រៅ ។

(ដកស្រង់ចេញពីសៀវភៅច្បាប់ក្រមង៉ុយទំព័រទី១២)

## លម្អបីប្រការ



(បទពាក្យប្រាំពីរ)

យើងកើតជាមនុស្សប្រសើរក្តាត់
លើសអស់សព្វសត្វលើផែនដី
មានរូប មានរាងល្អប្រពៃ
ប្រាជ្ញាកែច្នៃរិតតែល្អ ។
ប្រាជ្ញាជាគ្រឿងដុសខាត់យើង
ឱ្យបានរុងរឿងថ្កើងបវរ
ប្រកបបួកពាចរិយាធម៌
ផ្សំនឹងលម្អនៃអង្គប្រាណ ។
សមរូប ល្អបួក ល្អចរិយា
គ្មានទើសនេត្រានោះទើបបាន
ឈ្មោះថាល្អពិតគួរប្រមាណ
រករៀនឱ្យបានសព្វវិជ្ជា ។
រូបល្អហើយតែខ្វះចរិយា
ជាអលង្ការនោះមុខជា
មិនបានគាប់ភ្នែកជនគ្រប់គ្នា
ព្រោះមានបួកពាច្រឡើសបើស ។
សម្ដីសម្ដែងមិនសមរម្យ
បួកមិនរម្យទមឃើញទាក់ទើស
ទោះទៅទីណាគ្មានគេរើស
ពុំមានគេជ្រើសធ្វើជាមិត្ត ។

(ដកស្រង់ពីសៀវភៅរៀនអក្សរថ្នាក់ទី៥ ភាគ២)

## សំណួរ

១. តើមនុស្សល្អត្រូវមានអ្វីខ្លះ ?
២. តើក្នុងកំណាព្យនេះ គេប្រៀបធៀប “ ចរិយា” ទៅនឹងអ្វី ?
៣. តើបួកពាបែបណា ដែលគេចាត់ទុកថាជាបួកពាសមរម្យ ?
៤. តើបួកពាបែបណា ដែលគេចាត់ទុកថាជាបួកពាច្រឡើសបើស ?

## លំហាត់

**ក. ចូរគូសសញ្ញា ✓ក្នុងប្រអប់ចម្លើយណា ដែលជាគំនិតសំខាន់នៃអត្ថបទកំណាព្យ ។**

☐ ១. មនុស្សត្រូវមានរូបសម្បត្តិ និងចរិយាសម្បត្តិទើបប្រពៃ ។
☐ ២. មនុស្សត្រូវមានរូបសម្បត្តិ ចរិយាសម្បត្តិ និងចំណេះវិជ្ជាទើបប្រពៃ ។
☐ ៣. មនុស្សត្រូវមានរូបសម្បត្តិ និងចំណេះវិជ្ជាទើបប្រពៃ ។

**ខ. ចូររកពាក្យសូរដូចនឹងពាក្យ “ដុស គួរ សព្វ” ព្រមទាំងប្រាប់អត្ថន័យនៃពាក្យនីមួយៗផង ។**

## ការបំពេញឃ្លានៃកំណាព្យ

ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញកំណាព្យខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| វា | លោក | ធីតា | ពុះពារ | ពន់ | សិក្សា |

### គុណមាតាបិតា

(បទពាក្យប្រាំពីរ)

មាតាបិតាមានគុណធ្ងន់ លើសលប់ពេក.......... ឥតឧបមា
ចិញ្ចឹមទូន្មានបុត្រ........ ឱ្យខំ............. គ្រប់វិជ្ជា ។
កូនត្រូវគោរពតបគុណ........ អំពើស្មោកគ្រោកត្រូវចៀស..........
ខំប្រឹងខំត្រាប់ច្បាប់នានា តស៊ូ............. កសាងខ្លួន ។

## អក្សរជាតិយើង

### សំណួរ

១. តើព្យញ្ជនៈខ្មែរមានប៉ុន្មានតួ ? គឺអ្វីខ្លះ ?

២. តើអ្នកស្គាល់វណ្ណយុត្តិខ្មែរ ឬ សញ្ញាពិសេសអ្វីខ្លះ?

៣. តើអ្នកមានគំនិតដូចម្តេច ចំពោះអក្សរជាតិយើង ?

៤. តើកំណាព្យនេះជាបទអ្វី ?



## លំហាត់

ក. តើកំណាព្យនេះនិយាយអំពីអ្វី ? ចូរគូសសញ្ញា✓នៅមុខចម្លើយសមស្របមួយ ។

☐ ១. អក្សរជាតិយើងមានលក្ខណៈសម្បូរបែប ។

☐ ២. អក្សរជាតិយើងពិបាករៀនខ្លាំងណាស់ ។

☐ ៣. ការរៀនអក្សរជាតិនាំឱ្យខាតពេល ។

ខ. ចូរប្រាប់ពាក្យចួនក្នុងវគ្គ និងឆ្លងវគ្គក្នុងកំណាព្យដែលអ្នកបានស្តាប់ ។

អក្សរជាច្បាប់សម្រាប់ជាតិ ប្រឹងកុំរវាតរៀនគ្រប់ប្រាណ
ឱ្យចេះសរសេរហើយចេះអាន រៀនឱ្យចំណានចំណេះកើន ។
អ្នកចេះអក្សរផ្ញើដំណឹង ឱ្យញាតិមិត្តដឹងសុខចម្រើន
ទុក្ខព្រួយនានាតិចឬច្រើន គួរខំក្រវើនកុំបីព្រួយ ។

## គុណនាមកម្មសិទ្ធិ

នៅក្នុងមេរៀនទី១ អ្នកបានស្គាល់គុណនាមកំណត់ខ្លះៗហើយ ។ គុណនាមកំណត់មាន គុណនាមកម្មសិទ្ធិ គុណនាមចំនួន គុណនាមចង្អុល គុណនាមសំណួរ និងគុណនាមមិនច្បាស់ ។ នៅក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីគុណនាមកម្មសិទ្ធិ ។

ចូរអានឧទាហរណ៍ខាងក្រោមនេះ ។ តើពាក្យណាខ្លះជាគុណនាមកម្មសិទ្ធិ ?

១. ជីតាខ្ញុំសូត្រកម្រងអត្ថបទកាព្យពីរោះណាស់ ។

២. ផ្ទះវានៅឆ្ងាយជាងផ្ទះគាត់ ។

៣. តើសៀវភៅកំណាព្យឯងមានបទអ្វីខ្លះ ?

៤. កំណាព្យ គឺជាមរតកអក្សរសាស្ត្រជាតិយើង ។

ពាក្យ “ ខ្ញុំ វា គាត់ ឯង នាង យើង” មានទីតាំងនៅជាប់ខាងស្តាំនាម ។ វាជាគុណនាមកម្មសិទ្ធិ ។

> គុណនាមកម្មសិទ្ធិ ជាពាក្យបង្ហាញម្ចាស់នៃវត្ថុ ឬមនុស្ស សត្វ ។

## លំហាត់

ក. ចូរស្រង់គុណនាមកម្មសិទ្ធិចេញពីល្បះនីមួយៗខាងក្រោម ។

១. ថ្ងៃនេះ សុខាទៅទស្សនាភាពយន្តជាមួយបងប្រុសនាង ។

២. នៅសាលារៀនខ្ញុំ មានការប្រឡងសូត្រកំណាព្យ រៀងរាល់ឆ្នាំ ។

៣. ខ្មៅដៃខ្ញុំ នៅវែងជាងខ្មៅដៃឯង ។

៤. បងស្រីខ្ញុំខំរៀនតែងកំណាព្យ ។

៥. ថ្នាក់រៀនយើងនៅជិតផ្ទះអ្នកគ្រូ ។

ខ. ចូរតែងល្បះដោយប្រើគុណនាមកម្មសិទ្ធិក្នុងប្រអប់ខាងក្រោម ក្នុងមួយពាក្យឱ្យបានមួយល្បះ ។

| | | | | | | |
|---|---|---|---|---|---|---|
| វា | គាត់ | យើង | នាង | ខ្ញុំ | គេ | ឯង |

## គំនិតសំខាន់របស់អត្ថបទ

ក្នុងអត្ថបទនីមួយៗ តែងបង្កប់នូវគំនិតជាច្រើន ។ គំនិតទាំងនោះ ផ្ដោតទៅលើបញ្ហាសំខាន់អ្វីមួយដែលហៅថា គំនិតសំខាន់របស់អត្ថបទ ។ គំនិតសំខាន់ខ្លះ បានបង្ហាញត្រង់តាមល្បះណាមួយនៅក្នុងអត្ថបទ ប៉ុន្តែអត្ថបទខ្លះតម្រូវឱ្យមានការសំយោគសេចក្ដីលម្អិត ឬគំនិតតូចៗនៅក្នុងអត្ថបទ ទើបរកគំនិតសំខាន់នៃអត្ថបទនោះឃើញ ។

ចូរអានអត្ថបទខាងក្រោម ។ តើអត្ថបទនេះនិយាយអំពីអ្វី ?

### ប្រយោជន៍នៃវិជ្ជា

អ្នកមានចំណេះវិជ្ជាអាចជួយខ្លួនឯង និងសង្គមបានល្អប្រសើរ ។ អ្នកចេះដឹងអាចមើលឃើញបញ្ហាក្នុងសង្គម និងចេះដោះស្រាយបញ្ហាបានល្អត្រឹមត្រូវ ។ អ្នកមានចំណេះវិជ្ជាពិតប្រាកដ អាចយកចំណេះវិជ្ជានោះទៅប្រកបរបរចិញ្ចឹមជីវិតបានសមរម្យ ។ គេអាចដឹកនាំជីវិតបានល្អ ព្រោះមានសមត្ថភាព និងមានទំនុកចិត្តលើខ្លួនឯង ។ ជាពិសេស

អ្នកចេះដឹងត្រូវអ្នកផងគោរព និងស្រឡាញ់រាប់អាននៅគ្រប់ទីកន្លែង ហើយចាត់ទុកជាទីប្រឹក្សាដ៏ល្អ ។

គំនិតសំខាន់របស់អត្ថបទនេះគឺ“អ្នកមានចំណេះវិជ្ជា អាចជួយខ្លួនឯងនិងសង្គមបានល្អប្រសើរ” ។ ឯល្បះផ្សេងទៀតនៃអត្ថបទ ជួយបំភ្លឺ ឬបកស្រាយអត្ថន័យគំនិតសំខាន់ ឱ្យកាន់តែច្បាស់លាស់ថែមទៀត ។

គំនិតសំខាន់របស់អត្ថបទ បង្ហាញអត្ថន័យរួមរបស់អត្ថបទ ។

## លំហាត់

ចូរអ្នកអានអត្ថបទខាងក្រោម រួចប្រាប់ពីគំនិតសំខាន់របស់អត្ថបទ ។

### បឹងទន្លេសាប

បឹងទន្លេសាបមានទំហំធំល្វឹងល្វើយ ប្រៀបបាននឹងកូនសមុទ្រ ។ គ្រាន់តែឮឈ្មោះភ្លាម ប្រជាជនយើងគ្រប់រូបតែងនឹកស្រមៃទៅដល់ផលត្រីដ៏សម្បូរ ។ គេចាត់ទុកទន្លេសាប ជាជង្រុកត្រីនៃកម្ពុជា ។ ជលផលបឹងទន្លេសាប ជាប់ចំណាត់ថ្នាក់លេខមួយនៅលើសកលលោក ។ នៅរដូវទឹកដំឡើង បឹងនេះបានហូរនាំដីល្បាប់ដ៏មានជីជាតិមកស្រោចស្រពស្រែចម្ការ យ៉ាងច្រើនសន្ធឹក ។ ដូច្នេះ យើងទាំងអស់គ្នាត្រូវថែរក្សាការពារជលផលធម្មជាតិនេះឱ្យបានគង់វង្ស ។

## កំណាព្យខ្មែរ

កំណាព្យ គឺជាអត្ថបទពាក្យចួនដែលខ្មែរយើងមានតាំងពីយូរលង់ណាស់មកហើយ ។ ជាសក្ខីភាព យើងឃើញមានបុព្វកវីខ្មែរជាច្រើនដូចជាបណ្ឌិតជ័យនន្ទ សុត្តន្តប្រីយជាឥន្ទ្រ ក្រមង៉ុយ ព្រះរាជសម្ភារ នូកន ភិក្ខុសោម សន្ធរម៉ុក ជាដើមសុទ្ធតែជាអ្នកមានស្នាដៃល្បីល្បាញខាងតាក់តែងកំណាព្យ ។ កវីខ្លះ និយមតាក់តែងរឿងដោយប្រើកំណាព្យបទផ្សេងៗដូចជា រឿងរាមកេរ្តិ៍ ទុំទាវ និងល្បើករឿងផ្សេងៗមាន ច្បាប់ល្បើកថ្មី

ល្បើកអក ល្បើកជុចនិងត្រី ... ។ នេះសបញ្ជាក់ឱ្យឃើញថាតាំងពីបុរាណមក ខ្មែរយើងនិយមចូលចិត្តកំណាព្យណាស់ ។

កំណាព្យខ្មែរមានច្រើនបទ ហើយត្រូវបានគេប្រើប្រាស់ក្នុងគោលបំណងផ្សេងៗគ្នា ។ បទទាំងនោះមាន បទកាកគតិ បទព្រហ្មគីតិ បទពំនោល បទភុជង្គលីលា បទពាក្យប្រាំពីរ បទពាក្យប្រាំបី បទពាក្យប្រាំបួន បទទ្វេមាត្រជាដើម ។ បទនីមួយៗ សុទ្ធតែពីរោះរណ្តំណែងណង ប្លែកៗគ្នាគួរឱ្យចូលចិត្ត ។




ដូច្នេះ យើងជាសិស្សត្រូវយកចិត្តទុកដាក់រៀនសូត្រកំណាព្យខ្មែរឱ្យចេះចាំគ្រប់ៗគ្នា ។ ជាងនេះទៀត ត្រូវចេះលើកតម្កើង និងថែរក្សាកេរមរតកនេះឱ្យបានគង់វង្ស ។

## សំណួរ

១. តើកវីខ្មែរមានឈ្មោះអ្វីខ្លះ នៅក្នុងអត្ថបទនេះ ?

២. តើកំណាព្យខ្មែរយើងមានបទអ្វីខ្លះ ?

៣. តើអ្នកមានចំណាប់អារម្មណ៍ដូចម្តេច ចំពោះកំណាព្យខ្មែរយើង ?

## លំហាត់

ក. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយណាមួយ ដែលជាគំនិតសំខាន់របស់អត្ថបទ ។

☐ ១. ខ្មែរយើងនិយមប្រើប្រាស់កំណាព្យដើម្បីទាក់ទងគ្នា ។

☐ ២. ខ្មែរយើងមានកវីល្បីល្បាញ និងមរតកកំណាព្យបទផ្សេងៗជាច្រើន ។

☐ ៣. ខ្មែរយើងតាក់តែងរឿងដោយប្រើកំណាព្យ ។

ខ. ចូររកពាក្យសូរដូចនឹងពាក្យ " បទ ចិត្ត " ព្រមទាំងប្រាប់អត្ថន័យ និងរកឧទាហរណ៍សម្រាប់ពាក្យនីមួយៗផង ។

## ការបំពេញឃ្លានៃកំណាព្យ

ចូរបំពេញកំណាព្យបទពាក្យប្រាំពីរ ខាងក្រោមឱ្យបានត្រឹមត្រូវ ។

### ត្រូវស្រឡាញ់បងប្អូន

(បទពាក្យប្រាំពីរ)

បងប្អូនប្រុសស្រីស្រឡាញ់........ គ្រប់ពេល............. ផ្តមប្រណី
បងត្រូវចេះប្រើពាក្យ............ ល្ងួងលោមផ្តម.......... ថែទាំប្អូន ។
បងមានគំនិតប្រព្រឹត្តល្អ គំរូបវរឥតសាប................
ប្អូនត្រូវទុកខ្លួនដូចជាកូន ត្រងត្រាប់ដំបូន្មានគ្រប់គ្រា ។

## ការពណ៌នាអំពីអ្នកមានស្នាដៃ

ថ្ងៃមួយ តុលាសូត្រកំណាព្យជូនជីតាស្តាប់ ។ គេបានសួរជីតា អំពីអ្នកតែងកំណាព្យនោះ ។

ចូរអានការសន្ទនារវាងតុលា និងជីតារបស់គេ ។

**តុលា** : សូមទោសលោកតា ! តើអ្នកណាជាអ្នកនិពន្ធកំណាព្យនេះ ?

**លោកតា:** នេះជាស្នាដៃរបស់កវីក្រម ង៉ុយ ណ៎ាចៅ ។

**តុលា** : តើលោកតាស្គាល់កវីក្រម ង៉ុយដែរ ឬទេ ?

**លោកតា:** អូ! តាស្គាល់គាត់ច្បាស់ណាស់ចៅ ។ គាត់មានស្រុកកំណើតនៅឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល ។ ក្រមង៉ុយមានងារជា អ្នកព្រះភិរម្យភាសា អ៊ូឬភិរម្យង៉ុយ ។ ចៅដឹងទេ គាត់ជាមនុស្សពូកែខាងតែងកំណាព្យនិងមាន មានវោហារប៉ិនប្រសប់ណាស់ ។ គាត់ក្លាយជាអ្នកចម្រៀងសាដៀវមួយ រូបដ៏ល្បី នៅស្រុកខ្មែរយើង ។ កវីក្រមង៉ុយកើតនៅឆ្នាំ ១៨៦៥ ។ គាត់ បានថែកឋាននៅឆ្នាំ ១៩៣៦ ។

តុលា : លោកតា! តើគាត់មានស្នាដៃធំៗអ្វីខ្លះខាងកំណាព្យ ?

លោកតា: កំណាព្យរបស់គាត់មានដូចជាច្បាប់ល្បើកថ្មី សេចក្តីរំឭកដាស់តឿន ច្បាប់កេរកាលថ្មី និងច្បាប់ប្រដៅជនប្រុសស្រី ណា៎ចៅ!

តុលា : យី៎លោកតា! លោកកវីក្រម ង៉ុយ ជាមនុស្សគួរឱ្យកោតសរសើរណាស់ ។ ខ្ញុំនឹងខិតខំរៀនសូត្រពីស្នាដៃរបស់គាត់ ។

## សំណួរ

១. តើលោកតាក្រមង៉ុយកើតនៅឯណា ?

២. តើគាត់កើតនិងស្លាប់នៅឆ្នាំណា ?

៣. តើលោកតាក្រមង៉ុយល្បីល្បាញដោយសារអ្វី ?

៤. តើគាត់មានស្នាដៃអ្វីខ្លះ ?

## លំហាត់

ចូររៀបជាក្រុមតូចៗ រួចរៀបរាប់ពីអ្នកមានស្នាដៃណាម្នាក់ ដែលអ្នកបានស្គាល់ប្រាប់សមាជិកក្រុមរបស់អ្នកដោយប្រាប់ ៖

- ឈ្មោះ ភេទ អាយុ
- ទីកន្លែងកំណើត
- ស្នាដៃ ។

# ឆ្កួតបីប្រការ



(បទកាកគតិ)

លោកថាឆ្កួតបី
ឆ្កួតមួយនឹងល្បែង
ឆ្កួតមួយនឹងស្រី
អំពើពាលា
ឆ្កួតក្រែកន្លង ។
ឆ្កួតមួយនឹងស្រា
ឆ្កួតនេះហៅមហា

ឆ្កួតស្រីឆ្កួតស្រា
លោកពុំឱ្យសេព
ឆ្កួតល្បែងពាលា
ឱ្យវៀរជាម្តង
ភ្លេចភ្លាំងស្មារតី ។
អំពើសឹងឆ្គង
វាតែងឱ្យហ្មង

ឱ្យភ្លេចក្តីគាប់
ភ្លេចសីលភ្លេចទាន
ភ្លេចទាំងខ្លួនស្លាប់
ភ្លេចញាណវុឌ្ឍិ
ឆ្កួតបីប្រការ ។
ភ្លេចសាស្ត្រសួស្តី
ភ្លេចច្បាប់ប្រក្រតី

(ដកស្រង់ចេញពីច្បាប់កូនចៅ)

## សំណួរ

១. តើកំណាព្យនេះជាបទអ្វី ? មានប៉ុន្មានវគ្គ ? មួយវគ្គមានប៉ុន្មានឃ្លា ? មួយឃ្លាមានប៉ុន្មានព្យាង្គ ?

២. នៅក្នុងកំណាព្យខាងលើ តើគេចាត់ទុកអំពើផ្តួតជាប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ?

៣. ហេតុអ្វីបានជាគេចាត់ទុកអំពើទាំងនេះថាជាអំពើផ្តួត ?

៤. តើអំពើទាំងនេះ ផ្តល់ផលវិបាកអ្វីខ្លះដល់ខ្លួនឯង គ្រួសារ និងសង្គមជាតិ ?

៥. តើអ្នកមានគំនិតដូចម្តេចចំពោះអំពើផ្តួតទាំងនេះ ?

## លំហាត់

ក. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយណាដែលជាពាក្យផ្ទុយនឹងពាក្យខាងដើម ។

១. គាប់ ៖

☐ ក. ត្រូវ ☐ ខ. ខុស ☐ គ. ល្អ

២. ឆ្គង ៖

☐ ក. ស្អាត ☐ ខ. ល្អ ☐ គ. សមរម្យ ។

ខ. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយណាដែលជាគំនិតសំខាន់នៃអត្ថបទកំណាព្យ ។

☐ ១. ត្រូវវៀរចាកល្បែងស៊ីសង ព្រោះវានាំឱ្យខាតបង់ទ្រព្យ ។

☐ ២. ត្រូវវៀរចាក ស្រា និងល្បែងស៊ីសង ព្រោះវានាំឱ្យភ្លេចស្មារតី ។

☐ ៣. ត្រូវវៀរចាកអំពើផ្តួតទាំងបីមាន ស្រី ស្រា និងល្បែងស៊ីសង ។

គ. ចូរស្រង់ពាក្យចួននៅក្នុងមេសូត្រខាងលើ ។

វគ្គទី ១ ៖ តើពាក្យ“ បី” ចួននឹងពាក្យអ្វី ? ពាក្យ “ ស្រា ” ចួននឹងពាក្យអ្វីខ្លះ ?

វគ្គទី ២ ៖ តើពាក្យ “ស្រា ” ចួននឹងពាក្យអ្វី ? ពាក្យ “ ឆ្គង” ចួននឹងពាក្យអ្វីខ្លះ ?

វគ្គទី ៣ ៖ តើពាក្យ “គាប់” ចួននឹងពាក្យអ្វី ? ពាក្យ “ សួស្តី” ចួននឹងពាក្យអ្វីខ្លះ ?

ឃ. ចូររកពាក្យសូរដូចនឹងពាក្យ “ នឹង វៀរ ” ។

# ការតែងកំណាព្យខ្លីៗ

ក. ចូរបំពេញកំណាព្យបទពាក្យប្រាំពីរ ខាងក្រោមដោយខ្លួនឯងឱ្យបានត្រឹមត្រូវ ។

ខ្យល់បក់វូៗពីឧត្តរ មេឃស្រឡះ........ខៀវស្រងាត់
បក្សាបក្សីហើរ.......... វេរាឆ្វែងឆ្វាត់ស្រូវផ្តើមទុំ ។
វាលស្រែស្លឹងល្វើយលាតសន្ធឹង ក្ដួរស្រូវប្រៀបនឹងកម្រាល........
ស្រូវយើងក្ដួរវែងគុម្ពធំៗ ក្លិនប្រហើរ.........សព្វទិសទី ។
ទេសភាពត្រកាលស្រូវពណ៌....... ល្អល្អះឱភាសសមសោភី
កសិករជួបជុំគ្នាមូល.......... ច្រូតកាត់វក់.........ទុកជាស្បៀង ។

ខ. ចូរអានកំណាព្យខាងក្រោម ដោយកត់សម្គាល់ពាក្យចួនឱ្យបានច្បាស់លាស់ ។

## តន្ត្រីខ្មែរ (បទពាក្យប្រាំពីរ)

ព្យាង្គចួនគ្នា

វគ្គទី១ សូរសព្ទតន្ត្រីលាន់រងំ សម្ភោរស្គរធំខ្លុយចាប៉ី
រនាតតាខេឃឹមទ្រថ្មី សាដៀវដងខ្លីស្រឡៃមួយ ។

វគ្គទី២ ស្ដាប់ទៅពីរោះរំភើយចិត្ត ភ្លេងបុរាណស្និទ្ធបាត់ទុក្ខព្រួយ
ផ្សំចង្វាក់ឈិងនិងគងជួយ ភ្លេងខ្មែរលើកស្ទួយជួយលម្អ ។

## សំណួរ

១. តើកំណាព្យបទពាក្យប្រាំពីរក្នុងមួយវគ្គមានប៉ុន្មានឃ្លា ? តើក្នុងមួយឃ្លាមានប៉ុន្មានព្យាង្គ ?

២. ចូរប្រាប់ពាក្យចួនក្នុងវគ្គនិងពាក្យចួនឆ្លងវគ្គនៃកំណាព្យខាងលើ ។

## លំហាត់

ចូរតែងកំណាព្យបទពាក្យប្រាំពីរចំនួនពីរវគ្គ និយាយអំពីប្រធានបទអ្វីមួយដែលអ្នកចូលចិត្ត ។

មេរៀនទី

# ៤ ប្រយោជន៍នៃសារព័ត៌មាន



កាលណាគេចង់ដឹងព្រឹត្តិការណ៍ ឬព័ត៌មានផ្សេងៗ គេតែងតែស្តាប់វិទ្យុ មើលទូរទស្សន៍ ឬអានសារព័ត៌មាន ។ សារព័ត៌មាន ជាប្រភពព័ត៌មានមួយដែលផ្តល់ព័ត៌មានក្នុងប្រទេស និងព័ត៌មាននៅលើពិភពលោក ។ តាមរយៈសារព័ត៌មាន គេអាចដឹងពីព្រឹត្តិការណ៍ជាតិ ព្រឹត្តិការណ៍អន្តរជាតិ ព័ត៌មានវិទ្យាសាស្ត្រ ការប្រកួតកីឡា ការផ្សាយពាណិជ្ជកម្ម សេចក្តីជូនដំណឹង និងព័ត៌មានផ្សេងៗទៀត ។

## អត្ថបទសារព័ត៌មាន

ជាទូទៅអត្ថបទ ឬព័ត៌មាននៅក្នុងសារព័ត៌មាន ឬកាសែតតែងតែមានចំណងជើង ហើយចំណងជើងព័ត៌មានទាំងនោះភាគច្រើន ត្រូវបានបោះពុម្ពជាអក្សរដិតហើយធំៗ ។ នៅក្នុងអត្ថបទសារព័ត៌មានមួយចំនួន មានការដកស្រង់សម្ដីរបស់បុគ្គលខ្លះ យកមកចុះផ្សាយ ដើម្បីបញ្ជាក់បន្ថែមឱ្យកាន់តែច្បាស់ថែមទៀតផង ។

ចូរអានអត្ថបទសារព័ត៌មានខាងក្រោម ហើយប្រាប់ចំណងជើងអត្ថបទនិងសេចក្ដីដកស្រង់សម្ដី ។

### មន្ត្រីកាំកុងត្រូលត្រួតពិនិត្យទំនិញខូចគុណភាពក្នុងផ្សារគគីរ

**ខេត្តកណ្ដាល :** កាលពីថ្ងៃទី៩ ខែមេសា ឆ្នាំ២០១០ ប្រតិភូកាំកុងត្រូលដឹកនាំដោយលោកអគ្គនាយកនៃអគ្គនាយកដ្ឋានកាំកុងត្រូល បានចុះធ្វើការត្រួតពិនិត្យគ្រឿងឧបភោគ បរិភោគ ដែលកំពុងតាំងលក់នៅក្នុងផ្សារគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

លោកអគ្គនាយកបានធ្វើការពន្យល់ណែនាំដល់អាជីវករ ឱ្យយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យមុខទំនិញឱ្យបានច្បាស់លាស់ មុននឹងយកមកដាក់តាំងលក់ គឺត្រូវពិនិត្យស្លាកសញ្ញាសម្គាល់របស់ក្រុមហ៊ុន និងថ្ងៃ ខែ ឆ្នាំផុតកំណត់ប្រើប្រាស់ ដើម្បីចៀសវាងនូវការនាំយកមុខទំនិញក្លែងក្លាយ និងខូចគុណភាពមកលក់ ដែលនាំឱ្យប៉ះពាល់សុខភាពរបស់ប្រជាពលរដ្ឋទូទៅ និងជាប្រការល្មើសនឹងច្បាប់ ។

លោកអគ្គនាយកមានប្រសាសន៍ថា ដើម្បីទប់ស្កាត់នូវសកម្មភាពអសកម្មទាំងនេះ ប្រជាពលរដ្ឋ ឬអ្នកលក់ ត្រូវតែចូលរួមសហការជាមួយមន្ត្រីកាំកុងត្រូល ហើយត្រូវរាយការណ៍ជាបន្ទាន់ដល់សមត្ថកិច្ចមូលដ្ឋាន ឬផ្នែកជំនាញនៅពេលទទួលបានព័ត៌មានស្ដីពីមុខទំនិញក្លែងក្លាយ ឬខូចគុណភាព ដែលបាននាំចូលមកលក់នៅលើទីផ្សារ ។

នាឱកាសនោះ មន្ត្រីកាំកុងត្រូលទាំងនោះ បានទិញទំនិញមួយចំនួន សំខាន់គឺម្ហូបអាហារ គ្រឿងកំប៉ុងដែលមានការសង្ស័យ សម្រាប់យកទៅពិនិត្យតាមលក្ខណៈបច្ចេកទេស ដើម្បីបញ្ជាក់ថា តើមុខទំនិញទាំងនោះមានគុណភាព ឬក្លែងក្លាយ ទើបអនុញ្ញាត ឬមិនអនុញ្ញាតឱ្យអាជីវករបន្តលក់ដូរនៅលើទីផ្សារ ។

(ដកស្រង់និងសម្រួលពីកាសែតកោះសន្តិភាពលេខ ៦៨៣២ ថ្ងៃចន្ទ ទី១២ ខែមេសា ឆ្នាំ២០១០)

- អត្ថបទសារព័ត៌មានខាងលើមានចំណងជើងថា ៖

  មន្ត្រីកាំកុងត្រូលត្រួតពិនិត្យទំនិញខូចគុណភាព ក្នុងផ្សារគគីរ

- សេចក្តីដកស្រង់សម្តីក្នុងអត្ថបទខាងលើ ៖

  លោកអគ្គនាយកមានប្រសាសន៍ថា ដើម្បីទប់ស្កាត់នូវសកម្មភាពអសកម្មទាំងនេះ ប្រជាពលរដ្ឋ ឬអ្នកលក់ត្រូវតែចូលរួមសហការជាមួយមន្ត្រីកាំកុងត្រូល ហើយត្រូវរាយការណ៍ជាបន្ទាន់ដល់សមត្ថកិច្ចមូលដ្ឋាន ឬផ្នែកជំនាញនៅពេលទទួលបានព័ត៌មានស្តីពីមុខទំនិញក្លែងក្លាយ ឬខូចគុណភាពដែលបាននាំចូលមកលក់នៅលើទីផ្សារ ។

## លំហាត់

ចូរអ្នកអានសារព័ត៌មានខាងក្រោម រួចប្រាប់ចំណងជើង និងសេចក្តីដកស្រង់សម្តីនៅក្នុងអត្ថបទនេះ ។ តើជាសម្តីរបស់អ្នកណា ?

### មន្ត្រីជលផលកំពង់ឆ្នាំងចុះបោះស្លាកការពារព្រៃលិចទឹក

**កំពង់ឆ្នាំង :** ក្រុមការងាររបស់ខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំង ដឹកនាំដោយលោកនាយករងខណ្ឌរដ្ឋបាល កាលពីថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១០ បានចុះពិនិត្យ និងបោះស្លាកការពារព្រៃលិចទឹកនៅក្នុងភូមិសាស្ត្រ ឃុំត្រណូក ស្រុកកំពង់លែង ។

លោកនាយករងខណ្ឌរដ្ឋបាល បានមានប្រសាសន៍ឱ្យដឹងថា បច្ចុប្បន្ននេះ ក្រុមការងាររបស់លោកបានសម្រេចបោះស្លាកការពារព្រៃលិចទឹក បានចំនួន៨ ស្លាក និងបានបង្កើតក្រុមល្បាតការពារទប់ស្កាត់ការកាប់រុករាន និងដុតបំផ្លាញព្រៃលិចទឹកបានចំនួន៤៩ ក្រុមល្បាត នៅក្នុងស្រុកពីរ គឺស្រុកកំពង់លែង និងស្រុកបរិបូណ៌ ។

លោកនាយករងបានបញ្ជាក់ឱ្យដឹងទៀតថា នៅចំពោះមុខនេះ ក្រុមការងាររបស់ខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំងនឹងបន្តចុះបោះស្លាកការពារព្រៃលិចទឹក នៅតាមតំបន់សំខាន់ៗមួយចំនួនទៀត និងទៅធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីជលផល ដល់ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ព្រៃលិចទឹក និងតាមដងទន្លេសាប ដើម្បីឱ្យពួកគាត់កាន់តែយល់បន្ថែមទៀត និងចូលរួមជួយថែរក្សាការពារធនធានធម្មជាតិព្រៃលិចទឹក ។

(ដកស្រង់ពីកាសែតរស្មីកម្ពុជា លេខ៥១៨៨ ថ្ងៃអង្គារ ទី០៤ ខែឧសភា ឆ្នាំ២០១០)

## ការផ្តល់វ៉ាក់សាំង ការពារជំងឺផ្តាសាយប្រភេទថ្មី A/H1N1

**ភ្នំពេញ :** ប្រទេសកម្ពុជាបានបើកយុទ្ធនាការផ្តល់វ៉ាក់សាំងការពារជំងឺផ្តាសាយប្រភេទថ្មី A/H1N1 កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០នៅមន្ទីរពេទ្យបង្អែកចំការមន រាជធានីភ្នំពេញ ។ ពិធីបើកនោះ មានការចូលរួមពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងលោកអភិបាលរាជធានីភ្នំពេញ ។

លោកសាស្ត្រាចារ្យ អគ្គនាយករងបច្ចេកទេស ក្រសួងសុខាភិបាល បាននិយាយកាលពីរសៀលថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១០នេះ ឱ្យដឹងថា ការផ្តល់វ៉ាក់សាំងការពារជំងឺផ្តាសាយប្រភេទថ្មី A/H1N1 ដំណាក់កាលទី១ ទទួលបានជោគជ័យដោយមានប្រជាពលរដ្ឋជាង២សែននាក់ទទួលបានវ៉ាក់សាំងនេះ ។ លោកបានបញ្ជាក់ថា ក្រុមដែលទទួលបានវ៉ាក់សាំងនេះ រួមមានកុមារអាយុពី ៦ ខែដល់ ២ឆ្នាំ ស្ត្រីមានផ្ទៃពោះ អ្នកជំងឺសួតរ៉ាំរ៉ៃ និងបុគ្គលិកសុខាភិបាលតាមមន្ទីរពេទ្យទូទាំងប្រទេស ។

(សង្ខេបពីកាសែតកម្ពុជាថ្មី លេខ២២៣៩ ថ្ងៃអង្គារ ទី០៤ ខែឧសភា ឆ្នាំ២០១០)

# ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល

ចូរអានសេចក្តីរាយការណ៍សារព័ត៌មានមួយដូចខាងក្រោមនេះ ។




សៀមរាប : ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័លឆ្នាំ ២០១០នេះ បានប្រារព្ធឡើង កាលពីថ្ងៃទី២ ខែឧសភា នៅទីលានជល់ដំរី ខេត្តសៀមរាប ។ ពិធីនេះ ត្រូវបានប្រព្រឹត្តធ្វើឡើងយ៉ាងគគ្រឹកគគ្រេងជាទីបំផុត ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងមានការចូលរួមផងដែរ ពីសំណាក់ឥស្សរជនជាន់ខ្ពស់ ថ្នាក់ដឹកនាំព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ព្រមទាំងប្រជាពលរដ្ឋ សិស្សានុសិស្ស និងមន្ត្រីរាជការមកពីគ្រប់ទិសទីយ៉ាងច្រើនកុះករ ។

ព្រះរាជពិធី បានចាប់ផ្តើមនៅវេលាម៉ោងប្រមាណជា៨និង៣០នាទីព្រឹក ដោយមានព្រះអង្គម្ចាស់ស៊ីសុវត្ថិវិជ្ជរាវុធទ្រង់ជាស្តេចមាឃ យាងច្រត់ព្រះនង្គ័ល ភ្ជួរព្រះស្រែ និងអ្នកអង្គម្ចាស់ក្សត្រីនរោត្តមរស្មីពនីតាទ្រង់ជាព្រះមេហួ ។ ព្រះរាជពិធីនេះ បានប្រព្រឹត្តទៅចំនួនបីជុំនៃវាលព្រះស្រែ ។ បន្ទាប់មក ក្រុមបាគូបានដឹកគោឧសភរាជទៅកាន់ថាសមាសដែលមានអាហារ និងទឹកចំនួនប្រាំពីរថាស ពោលគឺស្រូវមួយថាស ពោតមួយថាស ល្ងមួយថាស សណ្តែកមួយថាស ស្មៅមួយថាស ទឹកមួយថាស និងស្រាមួយថាសផងដែរ ។ជាលទ្ធផល គោឧសភរាជបានទទួលទានគ្រាប់ពោតច្រើនជាងគេ បន្ទាប់មកគឺសណ្តែកដែលជាប្រផ្នូលទាយថា ការបង្កបង្កើនផលឆ្នាំនេះ ពោតទទួលបានផលល្អ និងសណ្តែកទទួលបានផលល្អបង្គួរ ។

ពិធីនេះ ត្រូវបានប្រារព្ធឡើងរៀងរាល់ឆ្នាំ នៅពេលរដូវវស្សាចាប់ផ្ដើម ហើយក្រុមព្រះបរោហិតអះអាងថា ការផ្សងប្រផ្នូលតាមរយៈគោឧសភរាជនៅក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័លនេះ មានតាំងពីបុរាណកាលមក ។

(ដកស្រង់ពីកាសែតរស្មីកម្ពុជាលេខ៥១៨៨ថ្ងៃអង្គារ ទី០៤ ខែឧសភា ឆ្នាំ២០១០)

## សំណួរ

១. តើព្រះរាជពិធីច្រត់ព្រះនង្គ័លឆ្នាំ២០១០នេះ ប្រារព្ធធ្វើនៅឯណា ? តើអ្នកណាខ្លះចូលរួម ?

២. តើគេបានធ្វើសកម្មភាពអ្វីខ្លះ នៅក្នុងព្រះរាជពិធីបុណ្យនេះ ?

៣. តើមានទឹកនិងអាហារអ្វីខ្លះ សម្រាប់ផ្សងគោឧសភរាជ ?

៤. តើគោឧសភរាជបរិភោគអ្វី ?

៥. តើគេផ្សងគោឧសភរាជដើម្បីអ្វី ?

៦. តើអត្ថបទនេះនិយាយអំពីអ្វី ?

## លំហាត់

ក. ចូរបំពេញល្បះខាងក្រោមឱ្យបានសមស្រប ។

១. រៀងរាល់ឆ្នាំ ព្រះរាជពិធីច្រត់ព្រះនង្គ័លបានប្រារព្ធនៅ................ ។

២. នៅពេលបញ្ចប់ពិធីភ្ជួរព្រះស្រែ មានពិធីផ្សង....................... ។

៣. អាហារសម្រាប់ផ្សងគោឧសភរាជមាន.............មុខគឺ............ ។

៤. អាហារទាំងនេះ គេដាក់នៅក្នុង................................... ។

៥. ព្រះរាជពិធីនេះ ប្រារព្ធនៅរដូវ....................................... ។

ខ. ចូរចម្លងសេចក្ដីដកស្រង់សម្ដី ដែលមាននៅក្នុងអត្ថបទសារព័ត៌មានខាងលើ ។

# ការពិតនិងមតិ

ពេលនិយាយ ឬសរសេរ គេតែងប្រាប់អ្វីដែលជាហេតុការណ៍ពិត ឬសម្ដែងគំនិត (មតិយោបល់) តាមការយល់ឃើញរបស់ខ្លួន ។

ចូរអ្នកអាន កថាខណ្ឌខាងក្រោម ។ តើល្បះណាជាការពិត ? ល្បះណាជាមតិ ?



(១) សាលាក្ដីខ្មែរក្រហម កំពុងបន្តការកាត់ក្ដីកាំងហ្គេច អ៊ាវ ហៅឌុច អតីតមេគុកទួលស្លែង និងឃុំខ្លួនជនជាប់ចោទបួនរូបទៀត ដែលជាមេដឹកនាំជាន់ខ្ពស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺ ខៀវ សំផន អៀង សារី អៀង ធារិទ្ធ និងនួន ជា ។

(២) ប្រជាជនខ្មែរមួយចំនួនយល់ថា សាលាក្ដីខ្មែរក្រហមនេះនឹងផ្ដល់យុត្តិធម៌ដល់ជនរងគ្រោះក្នុងរបបប្រល័យពូជសាសន៍ជាមិនខាន ។

- ល្បះទី១ ចាប់ពី " សាលាក្ដី....... នួនជា" ប្រាប់អំពីព្រឹត្តិការណ៍ពិត ។
- ល្បះទី២ ចាប់ពី " ប្រជាជនខ្មែរ........ ជាមិនខាន" ប្រាប់អំពីមតិ ឬការយល់ឃើញរបស់ប្រជាជនខ្មែរមួយចំនួនទៅលើការកាត់ក្ដីនេះ ។

ការពិត គឺជាហេតុការណ៍ដែលកើតឡើងពិតប្រាកដ អាចបញ្ជាក់ទីកន្លែង ពេលវេលាបាន ។ មតិ ជាការយល់ឃើញរបស់អ្នកណាម្នាក់ ឬមនុស្សមួយក្រុម ដោយផ្អែកលើការវិនិច្ឆ័យផ្ទាល់ខ្លួន ។ មតិពុំអាចបញ្ជាក់ថា ជាការពិត ឬមិនពិតបានឡើយ ។

## លំហាត់

ចូរអានកថាខណ្ឌខាងក្រោម ។ តើល្បះណាជាព្រឹត្តិការណ៍ ល្បះណាជាមតិ ?

ក. ក្រសួងមហាផ្ទៃប្រគល់ ឧបករណ៍វាស់ល្បឿនដល់ស្នងការនគរបាលរាជធានី ខេត្ត

កាលពីល្ងាចថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១០ តំណាងក្រសួងមហាផ្ទៃបានប្រគល់ឧបករណ៍វាស់ល្បឿន សម្រាប់ត្រួតពិនិត្យ និងទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ ដែលបង្កឡើងដោយការបើកបរហួសល្បឿនកំណត់ ដល់ស្នងការនគរបាលរាជធានី និងខេត្តចំនួន ៧ មានស្នងការនគរបាលរាជធានីភ្នំពេញ ខេត្តកណ្ដាល បាត់ដំបង កំពង់ចាម បន្ទាយមានជ័យ សៀមរាប និងខេត្តព្រះសីហនុ ។ ក្រសួងយល់ឃើញថា ក្រោយពេលដែលខេត្ត និងរាជធានីបានទទួលឧបករណ៍វាស់ល្បឿននេះ គ្រោះថ្នាក់ចរាចរណ៍បាននឹងកាត់បន្ថយមួយផ្នែក ធំ ដោយអ្នកបើកបរមិនអាចបើកបរហួសល្បឿនកំណត់បានឡើយ ។

(ដកស្រង់និងសម្រួលពីកាសែតកោះសន្តិភាពលេខ៦៨៩៦ ថ្ងៃចន្ទទី៣ ខែសីហា ឆ្នាំ២០១០)

ខ. ការឈ្លានពាន ៤ លើករបស់ថៃមកលើកម្ពុជា

ព្រំដែនប្រាសាទព្រះវិហារ : ការវាយប្រហារលើកទី៤របស់កងទ័ពសៀមមកលើកម្ពុជា កាលពីព្រឹកថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០១១ បានបញ្ចប់ក្នុងរង្វង់ប្រមាណ ២០ នាទី ដោយធ្វើឱ្យទាហានសៀម ៤នាក់បានស្លាប់ ។ ចំណែកការវាយប្រហារធំកាលពីយប់ថ្ងៃទី ៦ កុម្ភៈ ត្រូវបានកាសែតពីររបស់សៀមនិយាយថា កងទ័ពកម្ពុជាបាញ់ត្រូវចំណុចសំខាន់ៗជាច្រើន រហូតដល់បង្ខំឱ្យមេទ័ពសៀមបញ្ជាឱ្យបិទច្រកទ្វារព្រំដែនមួយចំនួន ខ្លាចក្រែងអ្នកស៊ើបការណ៍កម្ពុជាចូលដល់ ។

ប្រជាជនកម្ពុជាភាគច្រើនយល់ថា ទោះបីកងទ័ពថៃមានចំនួនច្រើន ហើយមានអាវុធទំនើបជាងកងទ័ពកម្ពុជាក៏ដោយ ក៏មិនអាចវាយឈ្នះកងទ័ពកម្ពុជាបានដែរ ព្រោះកងទ័ពកម្ពុជាមានទឹកចិត្តក្លាហានមោះមុត និងមានបទពិសោធន៍ជាងកងទ័ពថៃឈ្លានពាន ។

(ដកស្រង់និងសម្រួលពីកាសែតរស្មីកម្ពុជាលេខ៥៤២៤ ថ្ងៃអង្គារទី ៨ ខែកុម្ភៈ ឆ្នាំ២០១១)

# ១ បទសម្ភាស

ចូរស្តាប់បទសម្ភាសរវាងអ្នកកាសែតជាមួយមីងចន្ថាអំពីគ្រោះថ្នាក់ចរាចរណ៍ ។



## សំណួរ

១. តើអ្នកកាសែតសម្ភាសនរណា ?

២. ហេតុអ្វីបានជាអ្នកកាសែតសម្ភាសគាត់ ?

៣. តើអ្នកកាសែតសួរអ្នកមីងអំពីអ្វីខ្លះ ?

៤. តើមុននឹងសួរព័ត៌មាន អ្នកកាសែតនិយាយដូចម្តេចខ្លះ ?

៥. តើនៅពេលបញ្ចប់កិច្ចសម្ភាស អ្នកសម្ភាស(អ្នកកាសែត)និយាយដូចម្តេច?

# ប្រភេទនៃសព្វនាម

សព្វនាមមានច្រើនប្រភេទ គឺសព្វនាមបុរិសៈ សព្វនាមចង្អុល សព្វនាមសំណួរ សព្វនាមឈ្នាប់ និងសព្វនាមមិនច្បាស់ ។

ចូរអានឧទាហរណ៍ខាងក្រោមនេះ ។ តើពាក្យណាខ្លះជាសព្វនាម ?

១. ឯងចូលចិត្តស្តាប់ និងអានព័ត៌មានដូចខ្ញុំដែរ ។

២. លោកស្រីធានី ជាចាងហ្វាងកាសែត ។ គាត់ជាមនុស្សក្លាហានណាស់ ។

៣. នេះជាអ្នកយកព័ត៌មានដ៏ក្មេងខ្ចីម្នាក់ ។

៤. មានបន្ទាត់ពីរនៅលើតុ ។ អានេះជារបស់ខ្ញុំ ។

៥. តើអ្នកណាជាមិត្តជិតស្និទ្ធរបស់អ្នក ?

៦. តើអ្វីខ្លះជារបស់ឯង ?

៧. សិស្សដែលខំរៀន ប្រាកដជាប្រឡងជាប់ ។

៨. សារព័ត៌មានដែលល្អផ្សាយតែព័ត៌មានពិត ។

៩. គ្មាននរណាម្នាក់ចូលចិត្តអំពើហិង្សាឡើយ ។

១០. ខ្ញុំមិនត្រូវការអ្វីទាំងអស់ ។

ពាក្យ“ ឯង ខ្ញុំ គាត់” នៅក្នុងឧទាហរណ៍ទី១ ទី ២ ជា“សព្វនាមបុរិសៈ” ។

ពាក្យ“ នេះ អានេះ ” នៅក្នុងឧទាហរណ៍ទី ៣ ទី៤ ជា“សព្វនាមចង្អុល” ។

ពាក្យ“ អ្នកណា អ្វីខ្លះ” នៅក្នុងឧទាហរណ៍ទី ៥ ទី៦ ជា“សព្វនាមសំណួរ” ។

ពាក្យ“ ដែល” នៅក្នុងឧទាហរណ៍ ទី ៧ ទី៨ ជា“សព្វនាមឈ្នាប់” ។

ពាក្យ“ គ្មាននរណាម្នាក់ អ្វី ” នៅក្នុងឧទាហរណ៍ទី ៩ ទី១០ជា“ សព្វនាមមិនច្បាស់” ។

សព្វនាម ជាពាក្យសម្រាប់ជំនួសកន្សោមនាម និងបង្ហាញបុគ្គលចូលរួមក្នុងការប្រាស្រ័យទាក់ទងគ្នា ។

សព្វនាមបុរិសៈមាន ខ្ញុំ ឯង យើង វា គាត់ គេ អ្នក លោក ពួកគេ ពួកគាត់ ពួកវា ពួកអ្នក ពួកយើង... ។

សព្វនាមចង្អុលមាន នេះ អានេះ អ្នកនេះ នោះ អានោះ អ្នកនោះ... ។

សព្វនាមសំណួរមាន អ្នកណា នរណា អ្នកណាមួយ នរណាមួយ អ្នកណាខ្លះ នរណាខ្លះ ស្អី ស្អីខ្លះ អ្វី អ្វីមួយ អ្វីខ្លះ អី... ។

សព្វនាមឈ្នាប់មាន ដែល

សព្វនាមមិនច្បាស់មាន ម្នាក់ នរណាមួយ អ្នកណាមួយ នរណាក៏ដោយ អ្នកណាក៏ដោយ អ្វីមួយ ស្អីមួយ ច្រើនគ្នា ច្រើននាក់ ពីរបីនាក់ ខ្លះ ស្អីខ្លះ គ្មាននរណាម្នាក់ ម្នាក់ៗ នីមួយៗ ទាំងអស់ ទាំងមូល ខ្លះទៀត... ។

## លំហាត់

ក. ចូរស្រង់សព្វនាមនៅក្នុងកថាខណ្ឌខាងក្រោម និងប្រាប់ប្រភេទរបស់វា ។

ពូស្លេះ ជាអ្នកលក់កាសែត ។ រាល់ព្រឹក គាត់តែងយកកាសែតមកឱ្យខ្ញុំ ។ ថ្ងៃនេះគ្មាននរណាម្នាក់អានកាសែតគាត់ទេ ព្រោះម្នាក់ៗរវល់ ។ ដូច្នេះ អ្នកដែលអានកាសែតឱ្យគេស្ដាប់គឺខ្ញុំ ។ តើខ្ញុំត្រូវអានអ្វីខ្លះ ?

ខ. ចូរស្រង់សព្វនាមពីក្នុងល្បះខាងក្រោម ៖

១. ជីតាខ្ញុំ ចូលចិត្តឱ្យខ្ញុំអានកាសែតឱ្យគាត់ស្ដាប់ ។

២. លោកសុផល ជាអ្នកយកព័ត៌មានដែលល្បីជាងគេ ។

៣. តើអ្នកណាខ្លះ ទៅចូលរួមក្នុងពិធីបុណ្យថ្ងៃស្អែក ?

៤. នេះ ជាកាសែតចេញថ្មី ។

៥. តើគាត់ត្រូវការអ្វីខ្លះ ?

# បំណងរបស់ខ្ញុំ



មនុស្សគ្រប់រូប តែងតែមានបំណងប្រាថ្នាផ្សេងៗគ្នា ក្នុងការជ្រើសរើសមុខរបរ ។ អ្នកខ្លះចង់ធ្វើមន្ត្រីរាជការក្នុងក្រសួងនានា អ្នកខ្លះចង់ក្លាយជាពាណិជ្ជករ ដឹកចេញ នាំចូលផលិតផលផ្សេងៗ អ្នកខ្លះទៀតចង់គ្រប់គ្រងកសិដ្ឋានធំៗ ដាំដំណាំឧស្សាហកម្មដើម្បីបម្រើរោងចក្រឱ្យមានដំណើរការ ។ ចំណែកខ្ញុំ ចាប់ពីធំដឹងក្ដីមក ខ្ញុំចង់ក្លាយជាអ្នកសរសេរសារព័ត៌មានមួយរូបដ៏ល្បី និងមានប្រយោជន៍សម្រាប់ប្រទេសជាតិខ្ញុំ ។

ដើម្បីសម្រេចបំណងនេះ នៅពេលខ្ញុំក្លាយជាអ្នកយកព័ត៌មាន ខ្ញុំនឹងត្រាច់ចរគ្រប់ច្រកល្ហក ធ្វើដំណើរគ្រប់តំបន់ ទោះបីជួបការលំបាក ឬប្រឈមនឹងគ្រោះថ្នាក់ក៏ដោយ ។ ខ្ញុំនឹងឈ្មុសឈ្មុលតាមគ្រប់មធ្យោបាយ ដើម្បីពិនិត្យសង្កេតហេតុការណ៍ដល់ទីកន្លែងកើតហេតុ ដើម្បីយកព័ត៌មានមកចុះផ្សាយក្នុងទំព័រសារព័ត៌មានជូនមហាជន ប្រជាជន ឱ្យទាន់ពេលវេលា ។ ពេលខ្លះ ខ្ញុំត្រូវចូលរួមក្នុងអង្គប្រជុំ សន្និសីទ ស្នងការនគរបាល ឬតុលាការពេលកាត់ទោស ។ ខ្ញុំនឹងតស៊ូអត់ធ្មត់ទោះយប់ក្ដី ថ្ងៃក្ដី ពិនិត្យ និងថតយករូបភាពច្បាស់លាស់ ដើម្បីឱ្យសាធារណជនចាប់អារម្មណ៍ចំពោះដំណឹងថ្មីទាន់ហេតុការណ៍ ។ ខ្ញុំនឹងសរសេរតែព័ត៌មាន ពិតប្រាកដកើតមានជាក់ស្ដែង ដោយមិនបំភ្លៃការពិត មិនលម្អៀងនិងមានអំណះអំណាងច្បាស់លាស់ ។ ខ្ញុំនឹងខិតខំគោរពក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មានឱ្យបានត្រឹមត្រូវ និងខ្ជាប់ខ្ជួនជានិច្ច ។

ពេលនោះ ខ្ញុំសង្ឃឹមថា ខ្ញុំនឹងក្លាយជាអ្នកសារព័ត៌មានដែលមានឈ្មោះល្បីម្នាក់និងជាទីពេញនិយមរបស់អ្នកអាន ។

## សំណួរ

១. តើនៅពេលធំឡើងគេមានបំណងធ្វើអ្វី ?

២. ដើម្បីសម្រេចបំណង តើគេនឹងធ្វើអ្វីខ្លះ ?

## លំហាត់

ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយណា ដែលមានន័យត្រូវនឹងពាក្យខាងដើម ។

ក. ពាណិជ្ជករ

☐ ១. អ្នកដំណើរ

☐ ២. អ្នកជំនួញ

☐ ៣. អ្នកផលិត ។

ខ. បំភ្លៃ

☐ ១. បញ្ឆោត

☐ ២. បញ្ចូលថែម

☐ ៣. បំភិតបំភ័យ ។

## ការបំពេញកថាខណ្ឌ

ចូរសរសេរបំពេញកថាខណ្ឌខាងក្រោម ឱ្យបានសមស្រប ។

ឪពុកមាខ្ញុំ ជាអ្នកយកព័ត៌មាន ។ ទីណាមានព្រឹត្តិការណ៍ប្លែក គាត់តែងទៅយក..... ....................នៅទីនោះ ។ គាត់មិនដែលមានពេល..........................ឡើយ ។ រាល់....................គាត់ខំធ្វើការណាស់ ។ ពេលខ្លះគាត់ចូលស្ដាប់........................ ............គាត់ក្ដី ។ ជួនកាល គាត់ធ្វើការក្នុងប្រទេស ហើយជួនកាល គាត់ចេញទៅក្រៅ ............................ ដើម្បីប្រជុំជាមួយអ្នកកាសែតបរទេស ។

## ការសម្ភាស

ខាងក្រោមនេះ ជាសេចក្ដីដកស្រង់អត្ថបទនៅក្នុងកាសែត ។ ចូរអានអត្ថបទនេះជាមួយដៃគូ ដោយយកចិត្តទុកដាក់ ដើម្បីស្វែងយល់ខ្លឹមសារអត្ថបទ ។

### អង្គការអាដ្រាអប់រំការប៉ះពាល់នៃថ្នាំជក់ដល់យុទ្ធជននៅខេត្តព្រះវិហារ

កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ នៅទីបញ្ជាការកងពលធំលេខ៣តំបន់៥មករា អង្គការអាដ្រាកម្ពុជា បានធ្វើការអប់រំពីផលប៉ះពាល់នៃថ្នាំជក់ ដល់យុទ្ធជននៅសមរភូមិមុខ ប្រចាំទិសព្រះវិហារ ។

ក្នុងឱកាសនោះ តំណាងអង្គការអាដ្រាបានជម្រាបជូនយុទ្ធជនថា ពិធីនេះធ្វើឡើងក្នុងគោលបំណងជួយដល់នាយទាហាន ពលទាហានទាំងអស់ ឱ្យបានស្វែងយល់កាន់តែច្បាស់អំពីផលប៉ះពាល់ យ៉ាងធ្ងន់ធ្ងររបស់ថ្នាំជក់មកលើសុខភាព បរិស្ថាន និងសេដ្ឋកិច្ច ហើយអ្នកដែលបានចូលរួមក្នុងថ្ងៃនេះនឹងក្លាយទៅជាអ្នកផ្ដល់ព័ត៌មានយ៉ាងសំខាន់ ដើម្បីជួយអ្នកជក់បារី នៅតាមកន្លែងធ្វើការ ឬអង្គភាព ក្រុមគ្រួសារ និងមិត្តភក្ដិឱ្យលះបង់ចោលទម្លាប់ជក់បារី ព្រោះការជក់បារីនាំឱ្យកើតជំងឺបេះដូង ជំងឺមហារីក ជំងឺដាច់សរសៃឈាម និងជំងឺជាច្រើនប្រភេទទៀត ។ មិនតែប៉ុណ្ណោះ អ្នកដែលទទួលផ្សែងបារីពីគេ ក៏ប្រឈមមុខនឹងការកើតជំងឺទាំងនោះដែរ ។

លោក ឧត្តមសេនីយ៍ទោ តំណាងឱ្យយុទ្ធជនដែលចូលរួម បានប្ដេជ្ញារួមសហការបន្តអប់រំ និងឈប់ឱ្យមានផ្សែងបារីនៅតាមអង្គភាពក៏ដូចជាកន្លែងធ្វើការ ព្រោះកងទ័ពការពារទឹកដី ចាំបាច់ណាស់ត្រូវតែមានសុខភាពរឹងមាំ ថេះថែទាំសុខភាព ហើយត្រូវតែព្យាយាមផ្ដាច់បារី ដើម្បីសុខភាពទាំងអស់គ្នា ។

(សម្រួលពីកាសែតរស្មីកម្ពុជា លេខ៥១៨៨ថ្ងៃអង្គារទី០៤ឧសភា២០១០)

## លំហាត់

តាមខ្លឹមសារកាសែតខាងលើ ចូរអ្នករៀបចំអត្ថបទសម្ភាសដោយបង្កើតសំណួរ និងចម្លើយដែលទាក់ទងនឹងអត្ថបទ បន្ថែមទៅលើសំណួរចម្លើយគំរូមានស្រាប់ខាងក្រោម ។

បន្ទាប់មក ចូរឡើងសម្តែងតួជាអ្នកសម្ភាសន៍ និងអ្នកត្រូវគេសម្ភាស ។

**បទសម្ភាស**

អ្នកកាសែត : ជម្រាបសួរលោក! ខ្ញុំបាទបានទទួលព័ត៌មានថា អង្គការអាជ្រាកម្ពុជា បានធ្វើការជួបជុំជាមួយយុវជននៅប្រចាំទិសព្រះវិហារ ។ តើពិធីជួបជុំគ្នានេះ អង្គការរបស់លោកមានបំណងអ្វីដែរ ?

តំណាងអង្គការ : បាទ! យើងមានបំណងបង្ហាញអំពីផលប៉ះពាល់នៃថ្នាំជក់ ។

អ្នកកាសែត : តើពិធីនេះមានគោលបំណងអប់រំនរណាខ្លះ?

តំណាងអង្គការ : ............................................................................

អ្នកកាសែត : ............................................................................

តំណាងអង្គការ : ............................................................................

## ការសរសេរអត្ថបទសារព័ត៌មាន

ក. ចូររៀបពាក្យក្នុងប្រអប់តាមជួរនីមួយៗឱ្យបានជាឃ្លាត្រឹមត្រូវ ។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១. | ដាច់ | លក់ | កាសែត | នេះ | ណាស់ | | | |
| ២. | ថ្ងៃ | ខ្លះ | អ្វី | នេះ | មាន | ព្រឹត្តិការណ៍ | តើ | |
| ៣. | អ្នក | ក្លាយ | ព័ត៌មាន | ខ្ញុំ | ជា | យក | ចង់ | |
| ៤. | អាន | ការ | ព័ត៌មាន | នាំ | ឱ្យ | ដឹង | ច្រើន | រឿង |
| ៥. | អ្នក | នៅ | ជនបទ | ពុំ | បាន | ទទួល | ព័ត៌មាន | សូវ |

ខ. ចូរភ្ជាប់កន្សោមពាក្យខាងក្រោមឱ្យមានន័យត្រឹមត្រូវ ។

| | | | |
|---|---|---|---|
| ១. | បងខ្ញុំ | ក. | មិនទាន់ចេះអក្សរ ។ |
| ២. | ប្រជាជនខ្លះ | ខ. | អានកាសែតនៅសាលារៀន ។ |
| ៣. | កាសែតនេះ | គ. | ត្រូវការសារព័ត៌មានអ្វី ? |
| ៤. | តើអ្នក | ឃ. | ដើរលក់កាសែត ។ |
| ៥. | សិស្ស | ង. | លក់ដាច់ជាងគេ ។ |

គ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ដើម្បីបង្កើតជាល្បះឱ្យបាន ៣ ល្បះ ។

| | | | | | |
|---|---|---|---|---|---|
| នៅ | ទីនេះ | ចូល | ទីក្រុង | ល្អ | នឹង |
| អាន | ខ្ញុំ | អាកាស | មាន | រស់ | សប្បាយ |
| ណាស់ | ចិត្ត | យើង | នៅ | ខ្យល់ | សៀវភៅ |

ឃ. អ្នកបានអានអត្ថបទសារព័ត៌មានរួចហើយ ។ ក្នុងអត្ថបទសារព័ត៌មាន មានចំណុចសំខាន់ៗដូចជា ចំណងជើងអត្ថបទ សេចក្តីដកស្រង់សម្តី និងឈ្មោះខេត្តដែលកើតមានព្រឹត្តិការណ៍ ។

ចូរអ្នកសាកល្បងសរសេរអត្ថបទសារព័ត៌មានខ្លីមួយ ដែលនិយាយអំពីប្រធានបទណាមួយខាងក្រោម តាមគំរូអត្ថបទអំណានខាងលើ ។

- កម្លាំងនគរបាលចុះបង្ក្រាបល្បែងស៊ីសង
- ពិធីបុណ្យនៅក្នុងភូមិ
- ការចាក់ថ្នាំបង្ការជំងឺ ៧ មុខ ។

មេរៀនទី

# ៥ ស្មារតីទទួលខុសត្រូវ



ប្រទេសជាតិមានការរីកចម្រើន លុះណាតែប្រជាជនមានចំណេះដឹង មានសីលធម៌ និងមានស្មារតីទទួលខុសត្រូវ ។ មនុស្សគ្រប់រូបត្រូវមានស្មារតីទទួលខុសត្រូវចំពោះខ្លួនឯង ចំពោះគ្រួសារ ចំពោះសហគមន៍ដែលខ្លួនរស់នៅ និងសង្គមជាតិទាំងមូល ។

## ការសង្ខេបព័ត៌មាន

សង្ខេបព័ត៌មាន មានន័យថា និយាយ ឬសរសេរបង្រួញអត្ថបទព័ត៌មានឱ្យខ្លីដោយប្រើប្រាស់ពាក្យពេចន៍របស់ខ្លួន ដើម្បីឱ្យគេស្តាប់បាន និងយល់ខ្លឹមសារសំខាន់ៗនៃអត្ថបទនោះ ។ អ្នកសរសេរ ត្រូវបញ្ចូលគំនិតដែលមាននៅក្នុងអត្ថបទឱ្យបានច្បាស់លាស់ទៅតាមគោលគំនិតសំខាន់នីមួយៗ មិនត្រូវយកផ្នែកមិនសំខាន់មកបញ្ចូលទេ ។ ដើម្បីសង្ខេបព័ត៌មាន ត្រូវអនុវត្តតាមជំហានបន្តបន្ទាប់ខាងក្រោម ៖

១. អានអត្ថបទ ឬព័ត៌មានទាំងមូល និងស្វែងយល់ខ្លឹមសារឱ្យបានច្បាស់លាស់ជាមុន ។

២. ស្រង់យកគំនិតធំៗរបស់អត្ថបទ ឬព្រឹត្តិការណ៍សំខាន់ៗ ឬខ្លឹមសារសំខាន់ៗរបស់រឿង ។

៣. ប្រមូលគំនិត ឬព្រឹត្តិការណ៍បន្ទាប់បន្សំដែលមាននៅក្នុងព្រឹត្តិការណ៍ធំនីមួយៗ ។

៤. រៀបចំគំនិត ឬព្រឹត្តិការណ៍តាមលំដាប់មុនក្រោយ ។

៥. និយាយ ឬសរសេរអត្ថបទ ឬរឿងឡើងវិញដោយផ្អែកលើគម្រោងដែលបានធ្វើរួច ។ អ្នកត្រូវប្រើកន្សោមពាក្យ ឬល្បះភ្ជាប់គំនិត ឬព្រឹត្តិការណ៍មួយទៀតឱ្យជាប់រដឹកតាំងពីដើមរហូតដល់ចប់ ។

ចូរអានអត្ថបទព័ត៌មានខាងក្រោម ។

### ជំងឺម្យ៉ាងមានរោគសញ្ញាដូចជំងឺអាសន្នរោគបានកើតឡើងនៅខេត្តក្រចេះ

អ្នកភូមិចំនួន៣ គឺភូមិសណ្តាយ ភូមិទ្រាប និងភូមិ១០៥ ស្ថិតក្នុងឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ បានកើតជំងឺម្យ៉ាងមានរោគសញ្ញាដូចជំងឺអាសន្នរោគ ។ អ្នកកើតជំងឺនេះបានកើនដល់ចំនួន១៣៤នាក់ និងអ្នកស្លាប់ចំនួន ៦ នាក់ គិតត្រឹមរសៀលថ្ងៃ សៅរ៍ ទី ២៧ ខែ មីនា ឆ្នាំ២០១០ បន្ទាប់ពីជំងឺនេះបានចាប់ផ្តើមកើតឡើងកាលពីថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០១០កន្លងទៅ ។ នេះបើតាមការបញ្ជាក់របស់មន្ទីរសុខាភិបាលខេត្តក្រចេះ ។

ដំបូងនៅថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១០ មានអ្នកជំងឺចំនួន ៣៩ នាក់ត្រូវបាននាំទៅមន្ទីរពេទ្យបង្អែកខេត្ត និងប៉ុស្តិ៍សុខភាពភូមិ១០៥ដែលជាតំបន់ផ្ទុះជំងឺ ។ នៅយប់ថ្ងៃទី ២៦ខែមីនា ឆ្នាំ២០១០ មានអ្នកជំងឺ ៩៩ នាក់ថែមទៀត ហើយនៅថ្ងៃទី ២៧ អ្នកជំងឺបានកើនឡើងថែម ៥ នាក់ទៀត ។

អាជ្ញាធរខេត្តបានឱ្យដឹងថា អ្នកស្លាប់ដោយការរាករូសនេះ មានចំនួន៦នាក់ និងអ្នកជំងឺចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្ត បានកើនឡើងជាបន្តបន្ទាប់ ។ គ្រូពេទ្យនិយាយថាអ្នកស្លាប់ម្នាក់ជាអ្នកជំងឺចាស់ គាត់មានរោគរាកក្អួតតាំងពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០មកម្ល៉េះ ។ តាមការរៀបរាប់របស់អ្នកជំងឺ គេសង្ស័យថាទឹកអណ្តូងអាចជាមូលហេតុមួយ ។

រោគសញ្ញាជំងឺនេះគឺ អ្នកជំងឺមានអាការៈរាក និងក្អួតយ៉ាងស្រួចស្រាល់ ។ គ្រូពេទ្យនិយាយថា គេនៅមិនទាន់រកឃើញមូលហេតុដែលនាំឱ្យកើតជំងឺនេះនៅឡើយទេ ហើយគេមិនទាន់ដឹងច្បាស់ថា ជំងឺដែលរាតត្បាតនេះ ជាជំងឺអាសន្នរោគ ឬជំងឺផ្សេងទៀតនោះទេ ។ ប៉ុន្តែជាក់ស្តែង អ្នកភូមិដែលកំពុងព្យាបាលនៅមន្ទីរពេទ្យខេត្ត និងអ្នកភូមិដែលបានស្លាប់មានអាការៈរាករូស ក្អួត ដូចរោគសញ្ញាជំងឺអាសន្នរោគអ៊ីចឹង ។

កាលពីថ្ងៃសុក្រ ទី២៦ ខែមីនា ឆ្នាំ ២០១០ ក្រសួងសុខាភិបាលបានបញ្ជូនគ្រូពេទ្យមួយក្រុមទៅកាន់ខេត្តក្រចេះ ដើម្បីធ្វើពិសោធ និងអប់រំអនាម័យក្នុងគោលបំណងទប់ស្កាត់ការរាលដាលនៃជំងឺដ៏កាចសាហាវនេះ ។

(សម្រួលពីសារព័ត៌មានរស្មីកម្ពុជាលេខ ៥១៦២ថ្ងៃអាទិត្យនិងចន្ទទី២៨ខែមីនាឆ្នាំ២០១០)

ការសង្ខេបអត្ថបទព័ត៌មានខាងលើ ៖

នៅឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ មានអ្នកជំងឺចំនួនបីភូមិគឺ ភូមិសណ្តាយ ភូមិទ្រាប និងភូមិ ១០៥ បានកើតជំងឺដែលមានរោគសញ្ញាម្យ៉ាងដូចជំងឺអាសន្នរោគ ។ ជំងឺនេះបានកើតឡើងចំពោះមនុស្សចំនួន ១៣៤នាក់ និងមានអ្នកស្លាប់ចំនួន៦នាក់ គិតពីថ្ងៃទី២៥ មកដល់ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១០ ។ រោគសញ្ញានៃជំងឺនេះគឺ អ្នកជំងឺរាក និងក្អួតយ៉ាងស្រួចស្រាល់ដូចជំងឺអាសន្នរោគ ។ ប៉ុន្តែគេមិនទាន់ដឹងច្បាស់ថា វាជាជំងឺអាសន្នរោគ ឬជំងឺអ្វីទេ ហើយគេក៏ពុំទាន់ដឹងពីមូលហេតុដែលនាំឱ្យកើតជំងឺនេះដែរ ។ ក្រសួងសុខាភិបាលបានបញ្ជូនគ្រូពេទ្យមួយក្រុមទៅខេត្តក្រចេះ ដើម្បីជួយទប់ស្កាត់ការរីករាលដាលនៃជំងឺនេះ ។

> សង្ខេបព័ត៌មានគឺ និយាយ ឬសរសេរបង្រួញព័ត៌មានឱ្យខ្លីដោយប្រើសម្តីផ្ទាល់ខ្លួន ហើយផ្តល់តែចំណុចគោលសំខាន់ៗរបស់ព័ត៌មាន ឬព្រឹត្តិការណ៍សំខាន់ៗ ។

## លំហាត់

ចូរអ្នកអានអត្ថបទខាងក្រោម រួចសង្ខេបអត្ថបទនេះ ។

### ត្រៀមទប់ទល់ការរាតត្បាតជាសកលនៃជំងឺផ្ដាសាយថ្មី

នៅក្នុងអង្គសិក្ខាសាលាស្ដីពី“ការកសាងផែនការត្រៀមរៀបចំ និងឆ្លើយតបចំពោះជំងឺផ្ដាសាយរាតត្បាតជាសកល ” នៅខេត្តកំពង់ចាម នាថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១០ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានលើកឡើងថា ការត្រៀមខ្លួនទប់ទល់ និងឆ្លើយតបចំពោះការរាតត្បាតជាសកលនៃជំងឺផ្ដាសាយមនុស្ស គឺជាបញ្ហាអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ថ្នាក់ដឹកនាំបានរំឭកថា នៅឆ្នាំ ២០០៥ ជំងឺផ្ដាសាយបក្សីបានធ្វើឱ្យប្រជាជន ៤នាក់ នៅខេត្តកំពត និង៣នាក់ផ្សេងទៀតនៅខេត្តកំពង់ស្ពឺ ព្រៃវែង និងកំពង់ចាម បានបាត់បង់ជីវិត ។ រីឯជំងឺផ្ដាសាយថ្មីអេអេកវ៉ាន់អ៊ែនវ៉ាន់(A/H1N1) បានកើតឡើងនៅប្រទេសម៉ិចស៊ិកកូ នាពាក់កណ្ដាលខែមេសា ឆ្នាំ២០០៩ ហើយមានវត្តមាននៅកម្ពុជាយើងនៅខែមិថុនា ឆ្នាំ ២០០៩ តាមរយៈនិស្សិតអាមេរិកដែលចូលមកប្រទេសកម្ពុជាតាមច្រកប៉ោយប៉ែត ។ ចាប់តាំងពីពេលនោះមក កម្ពុជាមានជំងឺផ្ដាសាយថ្មីនេះ ៥៦០ករណី ក្នុង១៣ខេត្ត និងរាជធានី ។ ការឆ្លងនេះ ធ្វើឱ្យមនុស្ស៦នាក់ស្លាប់ កាលពីចុងខែវិច្ឆិកា ឆ្នាំ២០០៩កន្លងទៅ ។ ចំណែកនៅខេត្តកំពង់ចាម ក្រុងសួង កាលពីដើមខែធ្នូ ឆ្នាំ ២០០៩មានជំងឺផ្ដាសាយថ្មី អេអេកវ៉ាន់អ៊ែនវ៉ាន់(A/H1N1) ចំនួនពីរករណីចំពោះម្ដាយនិងកូន តែត្រូវបានព្យាបាលទាន់ពេលវេលា ។ នៅថ្ងៃទី ១១ធ្នូឆ្នាំ ២០០៩ នៅឃុំក្រែក ស្រុកពញាក្រែក ខេត្តកំពង់ចាម មានឆ្លងវីរុស អេកហ្វាយអ៊ែនវ៉ាន់(H5N1)មួយករណីទៀតចំពោះបុរសម្នាក់អាយុ ៥៤ឆ្នាំ តែត្រូវបានព្យាបាលទាន់ពេលវេលា ។

ថ្នាក់ដឹកនាំគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានមានប្រសាសន៍ថា ដើម្បីដោះស្រាយបញ្ហានេះ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវសហការជាមួយក្រសួង មន្ទីរ ស្ថាប័ន អង្គការនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីបំពេញការងារនេះ ។

(សម្រួលពីកាសែតរស្មីកម្ពុជាលេខ៥១៦២ ថ្ងៃអាទិត្យ ចន្ទទី២៨និង២៩ ខែមីនា ឆ្នាំ២០១០)

# រឿង ជីតាថាដូ



ថាដូនិងជីតា រស់នៅលើចង្កេះភ្នំមួយនៃប្រទេសជប៉ុន ។ នៅជុំវិញផ្ទះតាមល្បាក់ភ្នំ មានស្រែរបស់អ្នកស្រុកជាច្រើន ។ រសៀលថ្ងៃមួយ មានហេតុការណ៍មួយកើតឡើងគួរឱ្យតក់ស្លុត ។ ដំបូង គេឃើញជីតាថាដូឈរសម្លឹងទៅសមុទ្រ ហើយស្រាប់តែមានទឹកមុខស្លេកស្លាំង ។ ភ្លាមនោះ គាត់ស្រែកយ៉ាងភ្លាត់សំឡេងទៅកាន់ថាដូ ៖“ ចៅឯងរត់ឱ្យលឿនទៅយកមែកឈើ ដែលកំពុងឆេះនោះមកឱ្យតា! ឆាប់ឡើង!” ។ ឮដូច្នោះ ថាដូក៏ប្រញាប់ប្រញាល់រត់សំដៅភ្នក់ភ្លើង ហើយចាប់កន្ទុយអុសដែលកំពុងឆេះក្រហមច្រាលមកឱ្យជីតា ។ ភ្លាមនោះ គាត់បានដុតស្រូវក្នុងស្រែឆេះយ៉ាងសន្ធោសន្ធៅ ។ ថាដូឆ្ងល់នឹងទង្វើរបស់ជីតាយ៉ាងខ្លាំង ។ វាយំនិងសួរបញ្ជាក់ ៖“ លោកតា! លោកតាកំពុងដុតស្រូវហើយណា៎!” ។ ជីតាគ្រាន់តែងក់ក្បាល តែគាត់មិនបានចាប់អារម្មណ៍នឹងសម្ដីថាដូឡើយ ។ គាត់ថែមទាំងប្រើថាដូឱ្យដុតស្រូវបន្ថែមទៀត ។

គ្រានោះ វាលស្រែដែលមានស្រូវពណ៌ក្រហមដូចកម្រាលព្រំ ប្រែជាមានពណ៌ខ្មៅគ្របដណ្ដប់ដោយផ្សែងខ្មៅខ្មួលខ្មាញ់ អណ្ដែតទៅលើអាកាស ។ ទិដ្ឋភាពនេះ ធ្វើឱ្យអ្នកភូមិនាំគ្នារត់ឡើងមកលើភ្នំ ដើម្បីពន្លត់ភ្លើង ។ គ្រាន់តែឡើងមកដល់ស្រែភ្លាម បុរសម្នាក់

បានសួរទាំងកំហឹងទៅកាន់លោកតារបស់ថាដូ ៖ “ ហេតុអ្វីបានជាមានរឿងនេះ កើតឡើង? ប្រាប់មក!” ។ លោកតាបានឆ្លើយ ៖ “ ខ្ញុំជាអ្នកដុត” ។

បុរសនោះសួរបន្ត ៖ “ ហេតុអ្វី ?ហេតុអ្វី ?” ។ លោកតាបានចង្អុលទៅសមុទ្រ ។ អ្នកស្រុកមើលតាមដៃគាត់ ឃើញរលកដ៏ធំសម្បើមមួយកំពុងបោះពួយយ៉ាងលឿនស្ទើរសំដៅមករកភូមិអ្នកស្រុក ។ ពួកគេឈរទ្រឹងគ្មានកម្រើក ឬនិយាយស្ដីអ្វីឡើយ ។ ទឹកបានរត់រំលងភូមិនោះ បោកផ្ទប់ចង្កេះភ្នំលាន់យ៉ាងខ្លាំង ។ ប្រជាជនមានទឹកមុខតក់ស្លុត និងព្រួយកង្វល់ ព្រោះឃើញភូមិរបស់ខ្លួនទាំងមូលនៅក្រោមផ្ទៃទឹក ។ ទីបំផុត ទើបពួកគេយល់ពីមូលហេតុ ដែលនាំឱ្យលោកតាសម្រេចចិត្តដុតស្រូវ ។

( ដកស្រង់និងប្រែសម្រួលពីអត្ថបទរឿង “ ថាដូនិងការនេះស្រូវ”)

## សំណួរ

១. តើជីតាថាដូប្រើថាដូឱ្យយកភ្លើងមកធ្វើអ្វី ? ហេតុអ្វី ?

២. តើថាដូពេញចិត្តនឹងកិច្ចការនេះ ឬទេ ? ហេតុអ្វី ?

៣. តើការសម្រេចចិត្តរបស់លោកតាត្រឹមត្រូវ ឬទេ ? ព្រោះអ្វី ? ចូរលើកអំណះអំណាងពីក្នុងរឿងមកបញ្ជាក់ឱ្យបានច្បាស់លាស់ ។

៤. តើរឿងនេះផ្ដល់គំនិតអប់រំយ៉ាងដូចម្ដេច ?

## លំហាត់

ក. ចូរសរសេរសង្ខេបរឿងឡើងវិញ ។

ខ. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយណាដែលអាចបញ្ជាក់ថា ជីតាថាដូ មានបំណងជួយសង្គ្រោះអ្នកភូមិ ។

☐ ១. ជីតាថាដូឃើញរលកសមុទ្រដ៏ធំ ក៏ដុតស្រូវដើម្បីឱ្យអ្នកភូមិរត់ឡើងលើភ្នំ ។

☐ ២. ជីតាថាដូឃើញរលកសមុទ្រដ៏ធំ ក៏ដុតស្រូវបំភ័យអ្នកភូមិ ។

☐ ៣. ជីតាថាដូឃើញរលកសមុទ្រយ៉ាងធំ ក៏ឆ្លៀតឱកាសដុតស្រូវបំផ្លាញចោល ។

គ. ចូររកពាក្យន័យដូចនឹងពាក្យ សមុទ្រ ភ្លើង ភ្នំ ។

## ការស្រង់ព័ត៌មានសំខាន់ៗនៅក្នុងរឿង

ក្រោយពីបានអានរឿង“ ជីតាថាដូ” រួច ចូរអ្នកសរសេរ ឬស្រង់ព័ត៌មានសំខាន់ៗ ឬព្រឹត្តិការណ៍សំខាន់ៗនៅក្នុងរឿងនេះ តាមលំនាំគំរូខាងក្រោម ៖

១. ជីតាថាដូឈរសម្លឹងទៅសមុទ្រ ហើយមានទឹកមុខស្លេកស្លាំង ។

២. គាត់ប្រើថាដូ ឱ្យប្រញាប់យកកន្ទុយអុសឱ្យគាត់ ។

៣. ........................................................ ។

៤. ........................................................ ។

៥. ........................................................ ។

៦. ........................................................ ។

## ភ្លៀងធ្លាក់និងខ្យល់ព្យុះនៅខេត្តកំពង់ឆ្នាំង

ក្រោយពីស្តាប់គ្រូអ្នកអាននៃអត្ថបទនេះរួច ចូរអ្នកឆ្លើយនឹងសំណួរខាងក្រោម ។

១. តើខ្យល់ព្យុះកើតឡើងនៅឯណា ? នៅពេលណា ?

២. តើកន្លែងណាខូចខាតច្រើនជាងគេ ?

៣. តើខ្យល់ព្យុះនេះបណ្តាលឱ្យខូចខាតអ្វីខ្លះ ?



៤. តើអាជ្ញាធរមូលដ្ឋានអំពាវនាវដូចម្តេចខ្លះ ?

## លំហាត់

ចូរសរសេរព័ត៌មានសំខាន់ៗមួយចំនួនក្នុងអត្ថបទ ដែលអ្នកបានស្ដាប់ ដាក់ក្នុងតារាងដោយមានឧទាហរណ៍ទី១ជាគំរូ ។

| ល.រ | ព័ត៌មានសំខាន់ៗ |
|---|---|
| ១. | ថ្ងៃទី ២៥ និងទី ២៦ ខែមីនា ឆ្នាំ២០១០ នៅខេត្តកំពង់ឆ្នាំង មានភ្លៀងនិងខ្យល់ព្យុះបោកបក់យ៉ាងខ្លាំង ។ |
| ២. | ............................................................................................................ |
| ៣. | ............................................................................................................ |
| ៤. | ............................................................................................................ |

## សព្វនាមបុរិសៈ

សព្វនាមមានច្រើនប្រភេទ ។ ខាងក្រោមនេះ ជាសព្វនាមបុរិសៈ ។ តើសព្វនាមបុរិសៈមានអ្វីខ្លះ ? ចូរអានដោយពិនិត្យពាក្យមានគំនូសពីក្រោមក្នុងល្បះនីមួយៗ ។

១. ឯងនិងខ្ញុំ ជាសិស្ស ។ យើងត្រូវខំរៀនឱ្យបានពូកែ ។

២. ការការពារព្រៃឈើ គឺជាភារកិច្ចរបស់ពួកយើងទាំងអស់គ្នា ។

៣. រក្សានិងរ៉ាស៊ី ជាក្មេងឧស្សាហ៍ ។ ពេលទំនេរ ពួកវាអានសៀវភៅរឿងនិទាន ។

៤. ពូសនតែងចូលរួមធ្វើអនាម័យក្នុងភូមិ ព្រោះគាត់ចង់ឱ្យភូមិគាត់ស្អាតជានិច្ច ។

៥. គ្រូខ្ញុំយកចិត្តទុកដាក់នឹងសិស្សទាំងអស់ ។ លោកតែងទូន្មាន ពួកយើងឱ្យប្រព្រឹត្តអំពើល្អ ។

ពាក្យ " ឯង ខ្ញុំ យើង ពួកយើង " ក្នុងឧទាហរណ៍ទី១ ទី ២ និងទី៥ បង្ហាញបុគ្គលដែលរួមក្នុងការប្រាស្រ័យទាក់ទងគ្នា ។

ពាក្យ " ពួកវា" ឧទាហរណ៍ទី ៣ ប្រើជំនួសកន្សោមនាម " រក្សា និង រ៉ាស៊ី" ។

ពាក្យ " គាត់" ក្នុងឧទាហរណ៍ទី ៤ ប្រើជំនួសកន្សោមនាមពូសន ។

ពាក្យ " លោក" ក្នុងឧទាហរណ៍ទី ៥ ប្រើជំនួសកន្សោមនាមគ្រូខ្ញុំ ។

សព្វនាមបុរិសៈ ជាពាក្យសម្រាប់បង្ហាញបុគ្គលចូលរួមប្រាស្រ័យទាក់ទងគ្នា និងសម្រាប់ជំនួសកន្សោមនាម ។

សព្វនាមបុរិសៈមាន ៖

• បុរសទី ១ សម្រាប់បង្ហាញអ្នកនិយាយ ៖ ខ្ញុំ អញ គ្នា អាត្មា យើង ពួកយើង... ។

• បុរសទី ២ សម្រាប់បង្ហាញអ្នកដែលគេនិយាយទៅកាន់ ៖ ឯង អ្នក លោក ពួកឯង ពួកអ្នក ឯងរាល់គ្នា អ្នកទាំងអស់គ្នា ញោម... ។

• បុរសទី ៣ សម្រាប់បង្ហាញអ្នកដែលត្រូវគេលើកយកមកនិយាយ ៖ វា គាត់ គេ នាង លោក ពួកវា ពួកគាត់ ពួកគេ... ។

ការប្រើប្រាស់សព្វនាមបុរិសៈ ៖

- " ខ្ញុំ" សម្រាប់និយាយទៅកាន់មនុស្សចាស់ជាង ឬសម្រាប់ប្រើក្នុងការគួរសម ។
- " គ្នា" សម្រាប់អ្នកស្និទ្ធស្នាល ។
- " អាត្មា" សម្រាប់ព្រះសង្ឃ ។
- " ឯង " សម្រាប់និយាយទៅកាន់មនុស្សដែលមានវ័យក្មេងជាង ឬ អ្នកស្និទ្ធស្នាល ។
- " អ្នក" សម្រាប់ប្រើក្នុងការគួរសម ។
- " លោក" សម្រាប់និយាយទៅកាន់អ្នកធំជាង ឬសម្រាប់ប្រើក្នុងការគួរសម ។
- " វា" សម្រាប់បង្ហាញមនុស្ស សត្វ ឬ វត្ថុ ។
- " គេ" សម្រាប់សម្គាល់មនុស្សទូទៅ ។
- " គាត់" សម្រាប់បង្ហាញមនុស្ស ដែលមានវ័យចាស់ជាង ។

## លំហាត់

**ក. ចូររកសព្វនាមបុរិសៈនៅក្នុងកថាខណ្ឌខាងក្រោម ៖**

យើងជាសិស្ស មានភារកិច្ចចម្បងមួយគឺការសិក្សា ។ ក្រៅពីនេះ ពួកយើងត្រូវទទួលខុសត្រូវលើកិច្ចការផ្សេងទៀតដូចជា ការគោរពវិន័យ ការចូលរួមធ្វើពលកម្មនៅសាលារៀន ឬក្នុងសហគមន៍ ការធ្វើអនាម័យ ។ល ។ ចំពោះអ្នកដែលមានការទទួលខុសត្រូវ តែងធ្វើកិច្ចការទាំងនេះបានផលល្អប្រសើរ ហើយពួកគេនឹងមានអនាគតល្អ ។

**ខ. ចូរបំពេញល្បះខាងក្រោមដោយប្រើសព្វនាមបុរិសៈឱ្យបានសមស្រប ។**

១. នាងជាសិស្សពូកែគណិតវិទ្យារីឯ........វិញជាសិស្សពូកែភាសាខ្មែរ ។

២. ........តែងជួយពន្យល់មេរៀនគ្នាទៅវិញទៅមក ។

៣. ជីតាខ្ញុំតែងអប់រំទូន្មាន.......និងចៅៗឯទៀត ព្រោះ.......ចង់ឱ្យ......ក្លាយជាមនុស្សល្អ ។

៤. សិស្សនេះ ព្យាយាមរៀនសូត្រណាស់ ។.........បានទទួលរង្វាន់រាល់ឆ្នាំ ។

៥. តើ.........ទៅឯណាបាត់ បានជា..........មករកឯងមិនឃើញ ?

៦. ពូសាន ជាយុទ្ធជនក្លាហានម្នាក់ ។ .............ធ្វើពលិកម្មគ្រប់យ៉ាងឱ្យជាតិ ។

**គ. ចូរតែងល្បះដោយប្រើសព្វនាមក្នុងប្រអប់ខាងក្រោម ក្នុងមួយពាក្យឱ្យបានមួយល្បះ ។**

| | | | | |
|---|---|---|---|---|
| គេ | ពួកគេ | នាង | វា | លោក |

## ព្រឹត្តិការណ៍ពិតនិងព្រឹត្តិការណ៍ប្រឌិត

ព្រឹត្តិការណ៍ គឺអំពើ ឬហេតុការណ៍ដែលកើតមានឡើង ។ ហេតុការណ៍ខ្លះ កើតឡើងពិតប្រាកដ តែហេតុការណ៍ខ្លះទៀតគឺជាការប្រឌិត ។ ចូរអ្នកអានឧទាហរណ៍ខាងក្រោម រួចកំណត់ឱ្យបានច្បាស់លាស់អំពីព្រឹត្តិការណ៍ពិត និងព្រឹត្តិការណ៍ប្រឌិត ។

## ក. ព្រឹត្តិការណ៍ពិត

ព្រឹត្តិការណ៍ពិត គឺជាហេតុការណ៍ ឬសកម្មភាពដែលកើតមានឡើងពិតជាក់ស្ដែងនៅក្នុងសង្គម ។ វាអាចបញ្ជាក់បានពីហេតុការណ៍ មនុស្ស ពេលវេលា និងទីកន្លែងពិតប្រាកដ ។

ឧទាហរណ៍ ៖ ប្រាសាទព្រះវិហារជាមរតកដ៏មានតម្លៃបំផុត នៃព្រះរាជាណាចក្រកម្ពុជា ។ ប្រាសាទនេះ ត្រូវបានដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោក កាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨នៅទីក្រុង កេបិច ប្រទេសកាណាដា ។ នេះ គឺជាមោទនភាពមួយរបស់ជាតិយើង ។

ព័ត៌មានខាងលើបង្ហាញ ពេលវេលា ទីកន្លែង និងព្រឹត្តិការណ៍ពិតប្រាកដដែលគេអាចបញ្ជាក់បាននៅក្នុងប្រទេសកម្ពុជា និងនៅទីក្រុង កេបិច ប្រទេសកាណាដា ។ នេះជាព្រឹត្តិការណ៍ពិត ។

## ខ. ព្រឹត្តិការណ៍ប្រឌិត

ព្រឹត្តិការណ៍ប្រឌិត គឺជាហេតុការណ៍ ឬសកម្មភាពដែលគេប្រឌិតឡើងទៅតាមគំនិតយល់ឃើញរបស់គេ ដោយពុំមានកើតឡើងពិតជាក់ស្ដែងនៅក្នុងសង្គមឡើយ ។ វាក៏ពុំមានបញ្ជាក់ពីហេតុការណ៍ មនុស្ស ពេលវេលា និងទីកន្លែងច្បាស់លាស់ដែរ ។

ឧទាហរណ៍ ៖ កាលកន្លងទៅ មានត្រីចំពុះដាវជាច្រើន មកកកកុញក្នុងទឹកសមុទ្រជុំវិញប្រទេសសិង្ហបុរី ។ អ្នកស្រុក និងអ្នកនេសាទមិនហ៊ានចុះទៅក្នុងសមុទ្រឡើយ ព្រោះខ្លាចត្រីទាំងនោះចាក់សម្លាប់ ។ ស្ដេចបានបញ្ជាទាហានឱ្យទៅសម្លាប់ត្រីទាំងនោះ តែទទួលបរាជ័យជាច្រើនលើក ដោយត្រូវត្រីចាក់ស្លាប់ និងរបួសជាច្រើន ។ ឃើញហេតុការណ៍បែបនេះ ក្មេងប្រុសម្នាក់បានទូលស្ដេចឱ្យយកដើមចេកមកតម្រៀបតាមឆ្នេរសមុទ្រ ។ ស្ដេចបានបញ្ជាឱ្យទាហានធ្វើតាមពាក្យក្មេងនោះ ។ នៅពេលរលកបោកបក់ទឹកសមុទ្រ វាបាននាំត្រីចំពុះដាវ មកចាក់ជាប់នឹងដើមចេកទាំងនោះ ។ លុះពេលដល់ពេលទឹកថយទៅវិញ គេឃើញត្រីទាំងនោះជាប់នៅនឹងដើមចេកលើគោក ។ ពួកទាហាន ក៏នាំគ្នាសម្លាប់ត្រីទាំងនោះអស់ទៅ ។

ព័ត៌មានខាងលើមិនបានបង្ហាញ ពេលវេលា ហេតុការណ៍ពិតប្រាកដ និងទីកន្លែងណាមួយច្បាស់លាស់ឡើយ ។ វាជាព្រឹត្តិការណ៍ប្រឌិត ។

## លំហាត់

ចូរអ្នកអានអត្ថបទខាងក្រោម ។ តើអត្ថបទណាបង្ហាញព្រឹត្តិការណ៍ពិត ហើយអត្ថបទណាបង្ហាញព្រឹត្តិការណ៍ប្រឌិត ? ចូរបញ្ជាក់ ។

១. រៀងរាល់ឆ្នាំ នៅថ្ងៃ ០៩ ខែវិច្ឆិកា ប្រទេសកម្ពុជាយើងតែងប្រារព្ធពិធីបុណ្យឯករាជ្យជាតិនៅបរិវេណវិមានឯករាជ្យ ក្នុងរាជធានីភ្នំពេញ ។ ប្រទេសយើងធ្វើពិធីបុណ្យឯករាជ្យ ដើម្បីរំឭកខួបឯករាជ្យដែលខ្មែរយើងបានទាមទារពីអាណានិគមនិយមបារាំងក្នុងឆ្នាំ១៩៥៣ ។

២. ថ្ងៃមួយ ចៅចិត្របានធ្វើដំណើរជាមួយនាងយុននារី លោកហ្លួងរតនសម្បត្តិ និងលោកបាល័ដ្ឋត្រឡប់ពីបាត់ដំបងទៅប៉ៃលិនវិញ ។ មកដល់ពាក់កណ្ដាលផ្លូវ រថយន្តត្រូវខូច ។ អ្នកដំណើរទាំងអស់ ត្រូវសម្រាកកណ្ដាលផ្លូវ ។ យប់នោះ មានចោរមួយក្រុមបានបាញ់រះមកលើក្រុមអ្នកដំណើរ ។ ចៅចិត្រព្យាយាមតស៊ូប្រយុទ្ធ បាញ់តបតនឹងក្រុមចោរទាំងនោះវិញ ។ ទីបំផុត ចៅចិត្របានត្រូវរបួសសន្លប់បាត់ស្មារតី ។ ទឹកចិត្តក្លាហានរបស់ចៅចិត្រ ធ្វើឱ្យយុននារីពេញចិត្តយ៉ាងខ្លាំង ។

៣. កាលពីព្រលប់ថ្ងៃទី ២៣ ខែ មេសា ឆ្នាំង ២០១០ មានខ្យល់ព្យុះដ៏ធំមួយធ្វើឱ្យផ្ទះប្រជាពលរដ្ឋក្នុងភូមិចំនួន៤ សង្កាត់សៀមរាប ក្រុងសៀមរាប រងការខូចខាតអស់៤៨ខ្នង ។ ក្នុងនោះផ្ទះ ៣០ខ្នង ដួលរលំដល់ដី និង ១៨ខ្នងទៀតរបើកដំបូលអស់ ។ ក្រៅពីនោះ មានមនុស្សរងរបួសចំនួន ៣នាក់ ប្រុសពីរនាក់ និងស្រីម្នាក់ ងាប់សត្វគោចំនួន ៣ក្បាល និងខូចខាតសម្ភារៈក្នុងផ្ទះមួយចំនួនធំទៀត ។

៤. ដោយគង់នៅក្នុងព្រះរាជវាំងឯទួលបាសានពុំបាន ព្រោះទឹកទន្លេជន់លិច ព្រះបាទសម្ដេចបរមរាជាពញាយ៉ាត ក៏បញ្ជាឱ្យសម្ដេចចៅពញាកែ និងឧកញ៉ាហោរាធិបតីខៀវ រកកន្លែងសាងសង់ព្រះរាជវាំងថ្មី ។ ឧកញ៉ាហោរាធិបតីខៀវទស្សន៍ទាយទៅឃើញថាទឹកដីនាទិសអាគ្នេយ៍នៃភ្នំដូនពេញជាកន្លែងល្អ ។ ព្រះអង្គ ក៏បញ្ជាឱ្យគេសាងសង់រាជវាំងថ្មីនេះ ។ នៅឆ្នាំ ១៤៣៧ ព្រះអង្គប្រទាននាមក្រុងថ្មីថា“ ក្រុងចតុមុខមង្គល ” ។ មកដល់ឆ្នាំ ១៨៦៥ ព្រះបាទសម្ដេចព្រះនរោត្តម បានផ្លាស់ព្រះរាជវាំងពីក្រុងឧដុង្គមានជ័យមកគង់នៅក្រុងចតុមុខនេះ ។ ព្រះអង្គបានបន្តកសាងក្រុងនេះជាលើកទីពីរ រហូតបានក្លាយជារាជធានីភ្នំពេញសព្វថ្ងៃនេះ ។

# ការនិយាយពីព្រឹត្តិការណ៍ដែលនឹងកើតឡើងក្នុងពេលខាងមុខ

ចូរអានការសន្ទនាខាងក្រោម ។ តើគេសន្ទនាអំពីអ្វី ?

ឌីណា : រិទ្ធ! ឯងមានការអីបានជាត្រហេបត្រហបម្ល៉េះ ?

រិទ្ធ : ខ្ញុំទើបឃើញសេចក្ដីជូនដំណឹងថា ក្រុមកីឡាករសាលារៀនយើងនឹងធ្វើការប្រកួត ដើម្បីដណ្ដើមយកពានរង្វាន់ប្រចាំឆ្នាំ ចាប់ពីថ្ងៃស្អែកនេះហើយ ។

ឌីណា : តើក្រុមកីឡាសាលាយើងប្រកួតជាមួយសាលាណា ?

រិទ្ធ : ពួកគេប្រកួតជាមួយកីឡាករនៃសាលាជាច្រើនក្នុងស្រុកយើងនេះ ។

ឌីណា : តើគេរៀបចំពិធីប្រកួតនៅឯណាទៅ ?

រិទ្ធ : គេរៀបចំពិធីប្រកួត នៅឯទីលានបាល់ទាត់ស្រុកយើងនេះ ។

ឌីណា : បើអ៊ីចឹង! ពិតជាមានការចូលរួមច្រើន អ៊ូអរណាស់ហើយមើលទៅ!

រិទ្ធ : ពិតមែនហើយ! យើងនឹងចូលរួមទស្សនា និងលើកទឹកចិត្តកីឡាករបាល់ទាត់សាលារៀនយើង ។

## សំណួរ

១. តើគេសន្ទនាអំពីអ្វី ?

២. តើពិធីនេះ ធ្វើនៅពេលណា ? នៅឯណា ?

៣. តើដៃគូសន្ទនាមានចំណាប់អារម្មណ៍ដូចម្ដេច ចំពោះព្រឹត្តិការណ៍នេះ ?

## លំហាត់

ចូររៀបគ្នាជាក្រុមតូចៗ ។ ក្រុមនីមួយៗ ត្រូវពិភាក្សារៀបចំព័ត៌មានស្ដីពីព្រឹត្តិការណ៍ពិត ឬព្រឹត្តិការណ៍ប្រឌិត ដែលនឹងកើតឡើងក្នុងពេលណាមួយឆាប់ៗ ដែលខ្លួនទើបនឹងដឹង បង្ហាញដល់ក្រុមដទៃ ។



# សេចក្តីជូនដំណឹងអំពី “ បាតុភូតអាកាសធាតុ ”

## សេចក្តីជូនដំណឹង

ក្រសួងធនធានទឹក និងឧតុនិយម សូមប្រកាសជូនដំណឹងដល់អាជ្ញាធរដែនដីនិង ប្រជាពលរដ្ឋទាំងអស់ដែលរស់នៅតាមបណ្តាខេត្តមួយចំនួន និងអ្នកដំណើរតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាសត្រូវបង្កើនការប្រុងប្រយ័ត្នខ្ពស់ ជាពិសេសអ្នកនៅតាមតំបន់មាត់សមុទ្រគួរផ្អាកការនេសាទ ឬធ្វើដំណើរ ដើម្បីចៀសវាងគ្រោះថ្នាក់ជាយថាហេតុ ។ បន្ទាប់ពីអាកាសធាតុធ្លាក់ចុះត្រជាក់រយៈពេលប៉ុន្មានថ្ងៃនេះ ក្រសួងធ្វើការតាមដាន និងស្រាវជ្រាវពីបាតុភូតធម្មជាតិ និងអាកាសធាតុរួចមកឃើញថា ៖

នៅវេលាម៉ោង ៦ព្រឹក ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១០នេះ សម្ពាធទាបមួយបាននឹងកំពុងស្ថិតនៅលើសមុទ្រចិនខាងត្បូង ។ សម្ពាធនេះ កំពុងធ្វើដំណើរមកទិសខាងលិចក្នុងល្បឿន ១៥ គីឡូម៉ែត្រក្នុងមួយម៉ោង ។ ល្បឿនអតិបរមាក្បែរចំណុចកណ្តាលនៃវិសម្ពាធទាបនេះ មានឥទ្ធិពលមកលើព្រះរាជាណាចក្រកម្ពុជា បង្កឱ្យផ្ទៃមេឃមានពពកច្រើន ខ្យល់បក់ប្រែប្រួលមានល្បឿនពី ១៨– ២៥គីឡូម៉ែត្រក្នុងមួយម៉ោង ។ មានភ្លៀងមធ្យមដោយកន្លែងនៅតាមបណ្តាខេត្តមួយចំនួនដូចជា រតនគិរី ស្ទឹងត្រែង ក្រចេះ មណ្ឌលគិរី កំពង់ចាម ស្វាយរៀង និងព្រៃវែង ។

សម្រាប់ថ្ងៃទី ២០ ខែមករា ឆ្នាំ២០១០ ព្រះរាជាណាចក្រកម្ពុជាយើងទទួលឥទ្ធិពលពីសម្ពាធទាបដដែលនឹងអាចធ្វើឱ្យផ្ទៃមេឃមានពពកច្រើន ខ្យល់បក់ប្រែប្រួលមានល្បឿនពី ២៥ ទៅ ៣៥គីឡូម៉ែត្រក្នុងមួយម៉ោង ខ្យល់កន្ត្រាក់មានល្បឿន ៥៤ គីឡូម៉ែត្រក្នុងមួយម៉ោង ។ រលកសមុទ្រអាចមានកម្ពស់ពី១.៥០ទៅ ២ម៉ែត្រ ។

សម្រាប់ ថ្ងៃទី ២១ ខែមករា ឆ្នាំ ២០១០ វិសម្ពាធបានថយឥទ្ធិពល ផ្ទៃមេឃមានពពកច្រើន ខ្យល់បក់ប្រែប្រួលមានល្បឿនពី ២៥ទៅ ៣៥គីឡូម៉ែត្រក្នុងមួយម៉ោង អាចមានភ្លៀងច្រើននៅតំបន់សមុទ្រ ។ រលកសមុទ្រអាចមានកម្ពស់ពី ១ម៉ែត្រទៅ ១.៥០ ម៉ែត្រ ។

(សម្រួលពីសារព័ត៌មានដើមអម្ពិលលេខ ៣៩២ ថ្ងៃពុធ ទី២០ ខែមករា ឆ្នាំ២០១០)

## សំណួរ

១. តើអ្នកណា ជាអ្នកចេញសេចក្ដីប្រកាសជូនដំណឹងនេះ ? តើគេប្រកាសជូនដំណឹងអំពីអ្វី ?

២. តើនៅថ្ងៃទី១៩ ទី២០ និងថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ មានហេតុការណ៍អ្វីកើតឡើងខ្លះ ?

៣. តើខេត្តណាខ្លះ ដែលរងឥទ្ធិពលអាកាសធាតុនេះ ?

៤. តើសេចក្ដីប្រកាសជូនដំណឹងនេះ ធ្វើឡើងក្នុងគោលបំណងអ្វី ?

៥. តើអ្នកណាខ្លះ ត្រូវអានសេចក្ដីជូនដំណឹងនេះ ?

៦. តើសេចក្ដីប្រកាសជូនដំណឹងនេះ មានចំណុចសំខាន់ៗអ្វីខ្លះ ?

## លំហាត់

ក. តើសេចក្ដីជូនដំណឹងនេះ ជាអត្ថបទពិត ឬប្រឌិត ? ចូរដកស្រង់អំណះអំណាងក្នុងសេចក្ដីជូនដំណឹងខាងលើមកបញ្ជាក់ឱ្យបានច្បាស់លាស់ ។

ខ. ចូរសរសេរពាក្យ " ត្រូវ" នៅពីមុខល្បះណា ដែលត្រូវនឹងខ្លឹមសារអត្ថបទខាងលើ ហើយសរសេរពាក្យ " ខុស" នៅពីមុខល្បះណា ដែលមិនត្រូវនឹងខ្លឹមសារអត្ថបទ ។

.........ក្រសួងធនធានទឹក និងឧតុនិយម បានប្រកាសជូនដំណឹងដល់ប្រជាពលរដ្ឋគ្រប់ខេត្តក្រុងទាំងអស់ឱ្យផ្អាកការនេសាទ ឬធ្វើដំណើរ ដើម្បីចៀសវាងគ្រោះថ្នាក់ ។

.........ដោយសារឥទ្ធិពលសម្ពាធទាប ធ្វើឱ្យរលកសមុទ្រមានកម្ពស់ពី ៣ ទៅ ៤ ម៉ែត្រ ។

.........នៅម៉ោង៦ព្រឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១០ មានសម្ពាធទាបមួយស្ថិតនៅលើសមុទ្រចិនខាងត្បូង ។

.........នៅថ្ងៃទី ២០ខែមករា ឆ្នាំ២០១០ ប្រទេសកម្ពុជាយើងទទួលឥទ្ធិពលខ្យល់ព្យុះដ៏ធំ ។

...........នៅថ្ងៃទី២០ខែមករា ឆ្នាំ២០១០ ប្រទេសកម្ពុជាយើងទទួលឥទ្ធិពលសម្ពាធទាបដដែល ធ្វើឱ្យផ្ទៃមេឃមានពពកច្រើន និងអាចមានភ្លៀងច្រើន ។

..........នគរបាលបានហាមឃាត់ប្រជាជនក្នុងការធ្វើដំណើរតាមផ្លូវទឹក ព្រោះខ្លាចខ្យល់ព្យុះ ។

..........នៅថ្ងៃទី ២១ ខែមករា ឆ្នាំ ២០១០ វិសម្ពាធបានថយឥទ្ធិពល ។

គ. ចូរតម្រូវពាក្យ និងន័យរបស់វា ។

| | |
|---|---|
| ១. បាតុភូតធម្មជាតិ | ក. កម្រិតយ៉ាងច្រើន យ៉ាងខ្ពស់ ។ |
| ២. ឥទ្ធិពល | ខ. ឈ្មោះក្រសួងមានភារកិច្ចខាងពិនិត្យនូវបាតុភូតដែលកើតមានតាមរដូវ ដូចជាភ្លៀង ផ្គរ រន្ទះ ខ្យល់ព្យុះ... ។ |
| ៣. អតិបរមា | គ. កម្លាំងនៃអំណាច ។ |
| ៤. ក្រសួងធនធានទឹក និងឧតុនិយម | ឃ. ហេតុដែលបណ្តាលឱ្យកើតឡើងឯងៗដោយធម្មជាតិ ។ |

ឃ. ចូររកពាក្យសូរដូចនឹងពាក្យ " គួរ និង ពី " ដោយពន្យល់ន័យរបស់ពាក្យនីមួយៗ និងលើកឧទាហរណ៍មកបញ្ជាក់ផង ។

ង. ចូររកពាក្យផ្ទុយនឹងពាក្យ "ប្រុងប្រយ័ត្ន ធ្លាក់ចុះ " ។

# សេចក្តីជូនដំណឹង

សេចក្តីជូនដំណឹង អាចធ្វើឡើងតាមរយៈការសរសេរ និងការនិយាយ ។ សំណេរសេចក្តីជូនដំណឹង អាចធ្វើតាមរយៈលិខិតស្នាម បដា សារព័ត៌មាន និងផ្ទាំងសម្រាប់ផ្សព្វផ្សាយជាដើម ។

ចូរអានសេចក្តីជូនដំណឹងខាងក្រោម ។

## សេចក្តីជូនដំណឹង

នាយកសាលាបឋមសិក្សា សាមគ្គីមានជ័យ សូមជូនដំណឹងដល់បុគ្គលិកសិក្សា មាតាបិតាសិស្ស អាណាព្យាបាលសិស្ស និងសិស្សានុសិស្សទាំងអស់ឱ្យបានជ្រាបថា ៖

នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១០វេលាម៉ោង ៧ព្រឹក ខាងមុខនេះ សាលារៀនយើងនឹងរៀបចំពិធីប្រគល់រង្វាន់ដល់សិស្សពូកែគ្រប់ថ្នាក់ ក្រោមអធិបតីភាពលោកអភិបាលខេត្ត ។

ដូច្នេះ សូមគោរពអញ្ជើញបុគ្គលិកសិក្សា មាតាបិតា អាណាព្យាបាលសិស្ស និងសិស្សានុសិស្សទាំងអស់ចូលរួមកុំបីខាន ដើម្បីជួយលើកទឹកចិត្ត និងអបអរសាទរចំពោះសិស្សពូកែនៃសាលារៀនយើង ។

សាមគ្គីមានជ័យ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០១០

នាយកសាលា

ឡុង វិសាល

## សំណួរ

១. តើអ្នកណា ជាអ្នកធ្វើសេចក្តីប្រកាសជូនដំណឹងនេះ ?

២. តើសេចក្តីជូនដំណឹងនេះនិយាយអំពីអ្វី ?

៣. តើគេជូនដំណឹងដល់អ្នកណាខ្លះ ? នៅពេលណា ? នៅឯណា ?

៤. តើសេចក្តីជូនដំណឹងនេះ មានទម្រង់ដូចម្តេច ?

## លំហាត់

ចូរសរសេរសេចក្តីជូនដំណឹងដល់មិត្តរួមថ្នាក់របស់អ្នក ដើម្បីឱ្យគេចូលរួមក្នុងទិវាពលកម្មអន្តរជាតិ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ ០១ ខែឧសភា ឆ្នាំ២០១០ នៅក្នុងសហគមន៍របស់អ្នក ។

ក្នុងសេចក្តីជូនដំណឹងនោះ អ្នកគប្បីប្រាប់ ៖

១. អ្នកជូនដំណឹង

២. មុខសញ្ញាដែលត្រូវជូនដំណឹង

៣. គោលបំណងនៃការជូនដំណឹង

៤. ពេលវេលា និងទីកន្លែងដែលត្រូវជួបជុំ

នៅពេលអ្នកសរសេររួច អ្នកគប្បីអានសេចក្តីជូនដំណឹងរបស់អ្នកឱ្យក្រុមរបស់អ្នកស្តាប់ដើម្បីកែលម្អ ។

មេរៀនទី ៦

# អតីតកាលរបស់យើង



យើងម្នាក់ៗ តែងតែឆ្លងកាត់អតីតកាលគ្រប់ៗគ្នា ប៉ុន្តែអតីតកាលរបស់មនុស្សម្នាក់ៗមិនសុទ្ធតែល្អ ឬអាក្រក់ទាំងអស់នោះទេ ។ អតីតកាលរបស់អ្នកខ្លះ ក៏ជួបរឿងល្អ ឬហេតុការណ៍ល្អ ឬបានធ្វើអំពើល្អ តែអតីតកាលរបស់អ្នកខ្លះជួបរឿងអាក្រក់ ហេតុការណ៍អាក្រក់ ឬបានធ្វើអំពើអ្វីមួយអាក្រក់ ។ ដូច្នេះ អតីតកាលអាចប្រែប្រួលទៅតាមហេតុការណ៍ ដែលមនុស្សម្នាក់ៗបានធ្វើ ឬជួបប្រទះ ។

## កំណត់ត្រាប្រចាំថ្ងៃ

មនុស្សខ្លះ ធ្វើកំណត់ត្រាអំពីហេតុការណ៍សំខាន់ៗ ដែលខ្លួនបានជួបប្រទះ ឬបទពិសោធន៍ផ្ទាល់ខ្លួន ។ ហេតុការណ៍ ឬបទពិសោធន៍ទាំងនោះអាចជាការឈឺចាប់ ទុក្ខព្រួយ ការខ្មាសអៀន ការខកចិត្ត សេចក្ដីរីករាយ ក្ដីរំភើប... ។ ដើម្បីឱ្យគេអាចរំឭក ឬចងចាំហេតុការណ៍ ឬបទពិសោធន៍ទាំងនោះ គេតោងកត់ត្រាហេតុការណ៍ដែលចាប់អារម្មណ៍ទាំងនោះទុក ។

ចូរអ្នកអានកំណត់ត្រារបស់ពូសំណាង ខាងក្រោមនេះ ៖

**ថ្ងៃទី ១៧ មេសា ១៩៧៥** ខ្ញុំបានជួបហេតុការណ៍ដ៏រន្ធត់មួយ គឺគ្រួសារខ្ញុំ និងប្រជាជនទូទាំងប្រទេស ត្រូវខ្មែរក្រហមជម្លៀសចេញពីទីក្រុង ដោយប្រញាប់ប្រញាល់បំផុត ។

**ថ្ងៃទី ៧ មករា ១៩៧៩** ខ្ញុំបានទទួលសេចក្ដីរីករាយ កក់ក្ដៅយ៉ាងខ្លាំង ដោយក្រុមគ្រួសារខ្ញុំបានវិលត្រឡប់ចូលមករស់នៅទីក្រុងភ្នំពេញវិញ ។

**ថ្ងៃទី០១ តុលា ១៩៨០** ខ្ញុំមានចិត្តរំភើបជាខ្លាំង ដោយបានចូលរៀនជាថ្មី ។

ក្នុងការសរសេរកំណត់ត្រាប្រចាំថ្ងៃ ដំបូងគេត្រូវចុះកាលបរិច្ឆេទ បន្ទាប់មកចុះទីកន្លែង និងខ្លឹមសារនៃហេតុការណ៍ ។

**ចំណុចសំខាន់ៗនៃកំណត់ត្រា ៖**

- ក្នុងកំណត់ត្រា គេតែងតែប្រើពាក្យ "ខ្ញុំ" សំដៅខ្លួនអ្នកកត់ត្រាផ្ទាល់ ។
- មានមតិយោបល់ពីខ្លួនឯងច្រើន ។
- មានការពណ៌នាច្រើន (ពណ៌នាអំពីសកម្មភាព ដែលខ្លួនបានធ្វើ ឬហេតុការណ៍ដែលខ្លួនបានជួបប្រទះ) ។

> កំណត់ត្រាប្រចាំថ្ងៃ គឺជាសំណេរហេតុការណ៍ផ្ទាល់ខ្លួន ដើម្បីកត់ត្រារឿងដែលខ្លួនបានជួបប្រទះ ។

## លំហាត់

ចូរអ្នកចុះកំណត់ត្រានៅក្នុងសៀវភៅដោយឡែកមួយតាមគំរូខាងក្រោម ៖

| កាលបរិច្ឆេទ | ហេតុការណ៍/ សកម្មភាព |
|---|---|
| ថ្ងៃទី.......... ខែ........... ឆ្នាំ............ | ............................................................ |
| ថ្ងៃទី.......... ខែ........... ឆ្នាំ............ | ............................................................ |
| ថ្ងៃទី.......... ខែ........... ឆ្នាំ............ | ............................................................ |

## បំភ្លេចមិនបាន

នៅពេលវិស្សមកាលកន្លងទៅថ្មីៗនេះ ម្ដាយសុជាតាបាននាំសុជាតាទៅលេងផ្ទះពូរបស់នាងនៅទីក្រុងភ្នំពេញ ។ ពូរបស់នាងបាននាំនាង និងម្ដាយនាង ទៅដើរលេងនៅកន្លែងប្លែកៗមួយចំនួន ។ នាងបានជួបហេតុការណ៍គួរឱ្យចាប់អារម្មណ៍ជាច្រើន នៅពេលដើរទស្សនាកន្លែងទាំងនោះ ។ សុជាតា បានសរសេររៀបរាប់ហេតុការណ៍ទាំងនោះ នៅក្នុងសៀវភៅកំណត់ត្រាប្រចាំថ្ងៃរបស់នាង ។

**ថ្ងៃទី ០១ ខែសីហា ឆ្នាំ២០០៩**







លោកពូ បាននាំម្ដាយខ្ញុំ និងខ្ញុំ ទៅទស្សនាមជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជើងឯក ។ ខ្ញុំមានចិត្តរន្ធត់ និងខ្លោចផ្សាបំផុត ដោយបានឃើញឆ្អឹងលលាដ៍ក្បាលមនុស្សជាច្រើន ត្រូវបានគេយកមករៀបតម្កល់ទុកធ្វើសក្ការបូជា និងដើម្បីឱ្យកូនចៅជំនាន់ក្រោយបានដឹង បានឃើញ និងចងចាំអំពើប្រល័យពូជសាសន៍របស់ពួកខ្មែរក្រហម ។ យើងបានដើរមើលរណ្ដៅធំៗដែល គេកប់សពរួម និងបានចូលទស្សនាសារមន្ទីរតម្កល់ឯកសារ ។ ក្នុងនោះ គេបានបិទរូបថត និងឈ្មោះអ្នកដែលគេបានសម្លាប់នៅទីនោះ ។ មកដល់រូបនាយទាហានម្នាក់ អ្នកម៉ាក់ឈរទ្រឹងយំខ្សឹកខ្សួល ហើយប្រាប់ខ្ញុំថាបុរសនោះគឺជាបងជីដូនមួយរបស់គាត់ ។ អ្នកម៉ាក់និយាយរឿងរ៉ាវដ៏ទារុណរបស់លោកអ៊ំនោះ ធ្វើឱ្យខ្ញុំមិនអាចទប់ទឹកភ្នែកបានឡើយ ។ នៅជិតនោះ ខ្ញុំព្រឺក្បាលនឹងឧបករណ៍ ដែលពួកខ្មែរក្រហមប្រើប្រាស់ ដើម្បីធ្វើទារុណកម្ម និងសម្លាប់មនុស្សដូចជា ដង្កាប់ ពូថៅ ញញួរ ចបកាប់... ។ ទិដ្ឋភាពនៅទីនោះ ធ្វើឱ្យខ្ញុំចងចាំជារៀងរហូត ។

ថ្ងៃទី ៥ ខែសីហា ឆ្នាំ២០០៩



ខ្ញុំបានទៅកម្សាន្ត នៅខេត្តមណ្ឌលគិរី ។ ខ្ញុំសប្បាយចិត្តណាស់ ដោយនៅទីនោះខ្ញុំបានឃើញទេសភាពល្អប្លែកគ្រប់ទីកន្លែង ។ ខ្ញុំបានឃើញភ្នំទាបខ្ពស់ នៅជាប់គ្នាហូរហែព្រមទាំងវាលស្មៅស្រស់ស្អាត គួរឱ្យត្រជាក់ចិត្តក្រៃលែង ។ អ្វីដែលធ្វើឱ្យខ្ញុំចាប់

អារម្មណ៍យ៉ាងខ្លាំងនោះ គឺជនជាតិភាគតិច ។ ពួកគេស្លៀកសម្លៀកបំពាក់ជនជាតិ និងមានកាផាស្ពាយនៅពីក្រោយខ្នងទៀតផង ។ ខ្ញុំជក់ចិត្តនឹងសង្កេតមើលកូនផ្ទះតូចមួយដែលមានកម្ពស់ប្រហែលជិតដប់ម៉ែត្រ ។ ខ្ញុំឮគេថា ផ្ទះនេះគេសង់ឡើងសម្រាប់ឱ្យកូនកំលោះជនជាតិនៅ មុនពេលរៀបការរហូតដល់ពេលរៀបការ ។ លោកពូរបស់ខ្ញុំ បានថតរូបជនជាតិនោះជាច្រើន ។

## សំណួរ

១. តើសុជាតាធ្វើអ្វី នៅពេលវិស្សមកាល ?

២. តើថ្ងៃទី ០១ សីហា ២០០៩ សុជាតាទៅទីណា ?

៣. តើអ្វីខ្លះ ដែលធ្វើឱ្យនាងចាប់អារម្មណ៍នៅទីនោះ ?

៤. តើថ្ងៃទី ៥ សីហា ២០០៩ នាងទៅទីណា ?

៥. តើនាងចាប់អារម្មណ៍នឹងអ្វីខ្លះនៅទីនោះ?

៦. តើសុជាតាប្រើពាក្យអ្វី ដើម្បីរៀបរាប់ពីខ្លួននាង ?

## លំហាត់

ក. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយណា ដែលមានន័យត្រូវនឹងពាក្យខាងដើម ។

១. រន្ធត់ ៖

☐ ក. ភ័យស្លុត ☐ ខ. តក់ក្រហល់ ☐ គ. ក្ដៅក្រហាយ ។

២. សព ៖

☐ ក. ឆ្អឹងខ្មោច ☐ ខ. ខ្មោចស្រស់ ☐ គ. ខ្មោចមនុស្ស ។

៣. ទារុណ ៖

☐ ក. អាក្រក់ ☐ ខ. ធ្ងន់ធ្ងរ ☐ គ. ថោកទាប ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ដើម្បីជំនួសពាក្យដែលមានគំនូសពីក្រោម ។

| | | | |
|---|---|---|---|
| មើល | គ្រឿងប្រើប្រាស់ | ឈប់សម្រាក | លំហើយចិត្ត |

១. នៅពេលវិស្សមកាល សុជាតាទៅលេងទីក្រុងភ្នំពេញ ។

២. ខ្ញុំព្រឺក្បាលនឹងឧបករណ៍ ដែលពួកខ្មែរក្រហមប្រើប្រាស់ ដើម្បីធ្វើទារុណកម្ម និងសម្លាប់មនុស្ស ។

៣. ខ្ញុំបានទៅកម្សាន្តនៅភ្នំតាម៉ៅ ។

៤. ខ្ញុំនិងម្តាយខ្ញុំ បានទៅទស្សនាមជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជើងឯក ។

## ការបំពេញកំណត់ត្រាប្រចាំថ្ងៃ

ចូរសរសេរពាក្យបំពេញកំណត់ត្រាប្រចាំថ្ងៃខាងក្រោមឱ្យបានសមស្រប ។

**ក. ថ្ងៃទី ១៥ កក្កដា ឆ្នាំ២០០៩**

ពុកបានទិញកង់ថ្មីមួយឱ្យខ្ញុំ ។ ពេលខ្ញុំរៀនជិះ... ដំបូង ខ្ញុំឱ្យគាត់ជួយទប់ ។ មួយថ្ងៃក្រោយមក ខ្ញុំហ៊ាន ...ម្នាក់ឯង ។ ខ្ញុំសាកល្បងជិះទៅសាលារៀន ស្រាប់តែទៅ...របងសាលារៀន ដួលបែកមាត់ ។

**ខ. យប់ទី ៣នៃពិធីបុណ្យអុំទូកឆ្នាំ២០០៩**

ពុកបាននាំ...ទៅមុខព្រះបរមរាជវាំង ដើម្បីមើលការបណ្តែត... និងការប្រគំ... ។ ពេលនោះ មានមនុស្សច្រើនណាស់ប្រជ្រៀតគ្នារង់ចាំមើលការអុជ.... ។ ពេលឮកាំជ្រួចផ្ទុះ ខ្ញុំស្ទុះរុលទៅ... ដើម្បីឱ្យបានឃើញច្បាស់ ។ ខ្ញុំក៏របូតដៃពី... ។ មួយស្របក់ក្រោយមកទើបខ្ញុំ បានជួប...វិញ ។ ខ្ញុំរត់ទៅឱបគាត់ ដោយត្រេកអរ ។ ពុកក៏នាំខ្ញុំ មក...វិញ ។

# ខ្ញុំសាកល្បង







## សំណួរ

១. តើកំណាត់ត្រាទី១ និយាយអំពីអ្វី ? នៅឯណា ?

២. តើអ្នកកត់ត្រាមានអារម្មណ៍បែបណា នៅគ្រាដំបូង ? នៅទីបញ្ចប់ ?

៣. តើកំណាត់ត្រាទី ២ និយាយអំពីអ្វី ? នៅឯណា ?

៤. តើនៅពេលនោះ គេមានអារម្មណ៍យ៉ាងណា?

# សញ្ញារះមុខ "ះ"

ចូរអានឧទាហរណ៍ខាងក្រោម ។ តើសញ្ញារះមុខសម្រាប់ធ្វើអ្វី ?

## ក. ឧទាហរណ៍

១. ខ្ញុំជិះកង់ទៅសាលារៀន ។

២. ប្អូនខ្ញុំចេះដើរតេះតះ ។

៣. គ្រូប្រាប់ថា មេរៀននេះងាយស្រួលរៀនណាស់ ។

៤. កោះកាពិនៅឆ្ងាយណាស់ ។

៥. គេជីកស្រះចិញ្ចឹមត្រីប្រា ។

សញ្ញារះមុខ សម្រាប់ប្រើជំនួសព្យញ្ជនៈ"ហ"ប្រកបនឹងស្រៈខ្លី ។

## ខ. វិធីប្រើ

សញ្ញារះមុខប្រើនៅខាងក្រោយស្រៈប្រកប ។

សញ្ញាស្រៈខ្លះ ប្រកបនឹងរះមុខកត់សូរផ្សេងទៅវិញ ។

ឧទាហរណ៍ : កះ

ជះ

កោះ

ចេះ

## លំហាត់

**ក. ចូរបំពេញល្បះខាងក្រោម ដោយពាក្យដែលមានសញ្ញារះមុខ ឱ្យបានសមស្រប ។**

១. ខ្ញុំបានទៅលេងអង្គរវត្ត ។ នៅទី..... មានប្រាសាទល្អអស្ចារ្យជាច្រើន ។

២. ជីដូនខ្ញុំឈឺ..... ដោយសារគាត់ពិសាបន្លែឆៅច្រើនពេក ។

៣. ធីតា.....ម៉ូតូទៅទិញ.....មួយបាច់យកមកចាប់នំបញ្ចុកហូប ។

៤. ម្ដាយខ្ញុំ កើប..... ពីចង្ក្រានយកទៅចាក់ក្នុងរណ្ដៅទុកធ្វើជី ។

៥. ពេលគេនិយាយចំឈ្មោះ បូណាអៀនអង្គុយ..... ក្រចកដៃ ។

៦. ខ្ញុំបានទៅលេង..... ទន្សាយ កាលពីពេលចូលឆ្នាំខ្មែរ ។

៧. ប្រជាជនខ្មែរតស៊ូរើ..... ពីការ ... ជាន់របស់បារាំង ដើម្បីទាមទារឯករាជ្យ ។

៨. គេដាំផ្កា..... នៅក្នុងសួនច្បារមុខថ្នាក់រៀន ។

៩. ពេលចូលឆ្នាំខ្មែរ យើងមិនត្រូវលេង..... ទឹកដាក់គ្នាឡើយ ។

១០. គេខំ..... ពារគ្រប់ឧបសគ្គ ដែលមករារាំងការរៀនសូត្ររបស់គេ ។

ខ. ចូរតែងល្បះតាមរូបភាពខាងក្រោម ដោយប្រើពាក្យមានសញ្ញារះមុខ ។





........................................ ។ ........................................ ។

គ. ចូរតែងល្បះនឹងពាក្យខាងក្រោម ឱ្យបានមួយល្បះក្នុងមួយពាក្យ ។

១. ឈ្មោះ

២. ព្រះពុទ្ធ

៣. កុះករ

ឃ. ចូររកពាក្យដែលប្រើសញ្ញារះមុខ ឱ្យបានបីពាក្យហើយយកពាក្យនោះទៅតែងជាល្បះ ។

# ប្រាសាទព្រះវិហារ

ចូរអានអត្ថបទ រួចឆ្លើយនឹងសំណួរ ។



ប្រាសាទព្រះវិហារ ឋិតនៅយ៉ាងខ្ពស់ត្រដែត លើកំពូលរាបស្មើនៃជួរភ្នំដងរែក ក្នុងខេត្តព្រះវិហារ ។ ប្រាសាទនេះ បានសាងសង់ឡើងនៅចុងសតវត្សរ៍ទី ៩ ប្រកបដោយក្បូរក្បាច់រចនាដ៏ប្រណីត ។

នៅថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០០៨ ប្រជាជនទូទាំងប្រទេសមានទឹកមុខសប្បាយរីករាយឥតឧបមា ។ ក្រោមការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ប្រាសាទព្រះវិហារដែលជាកេរមរតករបស់ខ្មែរ ត្រូវបានអង្គការយូនីស្កូយល់ព្រមដាក់បញ្ចូលក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោក ។

ក្នុងថ្ងៃដដែលនោះ គ្រប់ក្រសួង មន្ទីរ សាលារៀនបានប្រមូលផ្តុំគ្នា នៅដងទង់ជាតិ ដើម្បីច្រៀងចម្រៀងជាតិ និងបង្ហូតទង់ជាតិ ហើយនិងស្តាប់សាររបស់ប្រមុខដឹកនាំរាជរដ្ឋាភិបាល ដែលចាក់ផ្សាយតាមវិទ្យុ ទូរទស្សន៍ជាសាធារណៈ ។ ឯទីវត្តអារាម ព្រះសង្ឃបានទូងស្គរ និងសូត្រជយតុប្រសិទ្ធពរជ័យក្នុងឱកាសនោះដែរ ។

រយៈពេលប៉ុន្មានខែក្រោយមក ក្រោមមូលនិធិទូរទស្សន៍បាយ័ន និងអំណោយរបស់សប្បុរសជន គេបានកសាងផ្លូវចាក់បេតុងមួយខ្សែយ៉ាងប្រណីត គួរឱ្យស្ញើចសរសើរទៅកាន់ប្រាសាទព្រះវិហារ ដែលធ្វើឱ្យយើងងាយស្រួលក្នុងការធ្វើដំណើរទៅកាន់ទីនោះ ។

សមិទ្ធផលទាំងនេះ បានមកពីកម្លាំងសាមគ្គីដ៏ស្អិតរមួតរបស់ប្រជាជនខ្មែរយើង ។ អំណឹះតទៅ យើងត្រូវតែប្ដេជ្ញាការពារសម្បត្តិបេតិកភណ្ឌពិភពលោកឱ្យបានឋិតថេរចីរកាលជានិរន្តរ៍ ។

## សំណួរ

១. តើប្រាសាទព្រះវិហារឋិតនៅឯណា ?

២. តើប្រាសាទព្រះវិហារ ត្រូវបានបញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោកនៅថ្ងៃណា ? ខែណា ? ឆ្នាំណា ?

៣. តើរាជរដ្ឋាភិបាលសុំបញ្ចូលប្រាសាទនេះ ជាបេតិកភណ្ឌពិភពលោកដើម្បីអ្វី ?

៤. តើនៅក្រោមមូលនិធិបាយ័ន និងអំណោយរបស់សប្បុរសជនគេបានកសាងអ្វី?

៥. តើអ្នកត្រូវធ្វើដូចម្ដេច ដើម្បីឱ្យប្រាសាទព្រះវិហារនៅគង់វង្សឋិតថេរចីរកាលតទៅ ?

## លំហាត់

ក. ចូរស្រង់ពាក្យដែលមានសញ្ញារះមុខក្នុងអត្ថបទខាងលើ ។

ខ. ចូរសរសេរពាក្យ“ ត្រូវ” ពីមុខល្បះណាដែលត្រូវនឹងខ្លឹមសារអត្ថបទ និងសរសេរពាក្យ“ ខុស” ពីមុខល្បះណាដែលមិនត្រូវនឹងខ្លឹមសារអត្ថបទ ។

........ប្រាសាទព្រះវិហារ ឋិតនៅលើកំពូលរាបស្មើនៃជួរភ្នំក្នុងប្រទេសថៃ ។

.........ថ្ងៃ ៧ ខែកក្កដា ឆ្នាំ២០០៨ អង្គការយូនីស្កូ បានយល់ព្រមដាក់បញ្ចូលប្រាសាទព្រះវិហារក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោក ។

.........ក្រោមមូលនិធិបាយ័ន និងអំណោយរបស់សប្បុរសជន គេបានកសាងផ្លូវមួយខ្សែទៅកាន់ប្រាសាទព្រះវិហារ ។

## ការនិយាយពីហេតុការណ៍នៅក្នុងកំណត់ត្រាប្រចាំថ្ងៃ

ក្រោយពីបានអានកំណត់ត្រាប្រចាំថ្ងៃរបស់សុជាតារួចមក សុខានិងធីតាបានលើកយកហេតុការណ៍នៅក្នុងកំណត់ត្រានាថ្ងៃទី ២៨ កក្កដា របស់សុជាតាមកជជែកគ្នាអំពីទស្សនៈរបស់អ្នកសរសេរ ។ ចូរអានការសន្ទនារវាងសុខានិងធីតា ។

**សុខា :** ធីតា! តើនៅក្នុងកំណត់ត្រារបស់សុជាតា នៅថ្ងៃទី០១ ខែសីហា ដែលយើងបានអាន មានហេតុការណ៍អ្វីខ្លះគួរឱ្យចាប់អារម្មណ៍ ?

**ធីតា :** តាមខ្ញុំយល់ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺ ឆ្អឹងលលាដ៍ក្បាលមនុស្សជាច្រើនត្រូវគេរៀបតម្កល់ទុក រណ្តៅកប់សពរួមដែលមានទំហំធំៗរួមទាំងវិធីនិងឧបករណ៍សម្រាប់សម្លាប់មនុស្ស ។

**សុខា :** មែនហើយ! តើសុជាតា ឬអ្នកសរសេរកំណត់ត្រានេះ យល់ឃើញយ៉ាងណាចំពោះហេតុការណ៍នេះ?

**ធីតា :** តាមខ្ញុំយល់ អ្នកសរសេរកំណត់ត្រានេះយល់ថា ហេតុការណ៍នេះចម្លែកមិនគួរឱ្យជឿ ជារឿងដែលគួរឱ្យរន្ធត់ និងខ្លោចផ្សាខ្លាំងណាស់ ឃើញហើយគួរឱ្យព្រឺក្បាល មិននឹកស្មានថា ពួកខ្មែរក្រហមមានចិត្តកាចឃោរឃៅ ហ៊ានកាប់សម្លាប់មនុស្សគ្មានញញើតដៃដូច្នេះសោះ ។ នាងយល់ទៀតថា ត្រូវតែកត់ត្រារឿងនេះទុក ព្រោះអំពើនេះជាអំពើព្រៃផ្សៃអស្ចារ្យ គ្មាននរណាធ្វើដូចទេ ។ អំពើនេះ ធ្វើឱ្យនាងចងចាំជានិច្ច គ្មានថ្ងៃបំភ្លេចបាន ។ ដូច្នេះ កូនចៅជំនាន់ក្រោយត្រូវតែបានដឹងគ្រប់ៗគ្នា ។

### លំហាត់

ចូរអ្នករៀបចំការពណ៌នាពីហេតុការណ៍ខាងលើ ដោយប្រាប់ពីទស្សនៈរបស់អ្នកសរសេរកំណត់ត្រានេះ ហើយឡើងបង្ហាញដល់សិស្សទាំងអស់ ដោយការនិយាយផ្ទាល់មាត់ ។

# ស្រមោលអតីតកាល



យប់នេះ ខ្ញុំគេងមិនលក់សោះ ខ្ញុំចេះតែស្រមៃទៅដល់អតីតកាលដែលគួរឱ្យឈឺចាប់បំផុត ។ ខ្ញុំនៅចាំបានថា នៅខែកក្កដា ឆ្នាំ ១៩៧៧ ខ្ញុំមានអាយុប្រាំបីឆ្នាំ ។ ខ្ញុំមានជំងឺហើម ដោយខ្វះជីវជាតិអាហារ ។ យប់មួយ ខ្ញុំឃ្លានខ្លាំងពេកមិនអាចទ្រាំបាន ក៏លួចរត់ទៅភូមិ ក្រែងបានអ្វីបន្តិចបន្តួចហូបឱ្យមានកម្លាំង ។ ទៅដល់មុខផ្ទះ ដោយសារពន្លឺព្រះចន្ទ ខ្ញុំឃើញក្រូចថ្លុងនៅសល់បីផ្លែ ។ ពេលនោះ នៅក្នុងខ្ទម ម្ដាយឪពុកខ្ញុំសម្រាន្តលក់ស្ងាត់ឈឹង ។ ខ្ញុំចូលទៅដាស់គាត់ ហើយសូមឱ្យគាត់បេះផ្លែក្រូចឱ្យខ្ញុំហូប ។ ឪពុកខ្ញុំ អាណិតខ្ញុំពេក ក៏ដាច់ចិត្តប្រថុយលីតម្ដក់ដើរទៅកាន់ដើមក្រូចទាំងភិតភ័យបំផុត ។ ពុកថ្ពក់ផ្លែក្រូចថ្នមៗ ។ ផ្លែក្រូចធ្លាក់ខ្ទុកដូចចិត្ត ។ ខ្ញុំឃើញគាត់ឱនរើសផ្លែក្រូច ស្រាប់តែកងឈ្លបមិនដឹងជាមកដល់ពីថ្មើរណាចាប់ដៃគាត់ជាប់ ហើយស្រែកដាក់គាត់ ៖“ មិត្តឯងក្បត់! យើងរកឃើញខ្មាំងហើយ! ” ។ ពួកវាក៏ចាប់ចងពុកបណ្ដើរយកទៅ ។ ពេលនោះខ្ញុំភ័យពេក រត់យករួចខ្លួនភ្លេចគិតអ្វីទាំងអស់ ។ ព្រឹកស្អែកឡើងខ្ញុំឮគេខ្សឹបគ្នាថា កងឈ្លបបានយកឪពុកម្ដាយ និងប្អូនស្រីខ្ញុំទៅសម្លាប់អស់ហើយ ។

នេះហើយជារឿង ដែលធ្វើឱ្យខ្ញុំចងចាំមិនដែលភ្លេច ។ ខ្ញុំសូមឱ្យខ្មែរជំនាន់ក្រោយចេះអត់ឱន អធ្យាស្រ័យគ្នា ហើយបែងចែកមិត្ត និងសត្រូវឱ្យបានច្បាស់ និងរួបរួមសាមគ្គីគ្នាកសាងមាតុភូមិឱ្យបានរុងរឿង ។

## សំណួរ

១. តើរឿងនេះ កើតនៅក្នុងសម័យណា ?

២. តើចំពោះរឿងនេះ អ្នកមានអារម្មណ៍យ៉ាងណា?

៣. តើតទៅមុខ អ្នកគួរធ្វើយ៉ាងណា?

# កំណត់ត្រាប្រចាំថ្ងៃ

នៅក្នុងអត្ថបទកំណត់ត្រាដែលអ្នកបានអាន និងបានស្តាប់ អ្នកបានដឹងហេតុការណ៍ដ៏សោកសៅ ហេតុការណ៍គួរឱ្យសប្បាយរីករាយ និងគួរចាប់អារម្មណ៍ ។ កន្លងមកអ្នកផ្ទាល់ក៏ប្រាកដជាធ្លាប់ជួបហេតុការណ៍គួរឱ្យចាប់អារម្មណ៍ដែរ ។

ចូរអ្នកសរសេរបទពិសោធន៍ទាំងនោះ ជាទម្រង់កំណត់ត្រាប្រចាំថ្ងៃ ដោយសរសេរកាលបរិច្ឆេទ និងហេតុការណ៍ដែលកើតឡើងនៅពេលនីមួយៗនោះ ដោយប្រើពាក្យ " ខ្ញុំ" តាមលំនាំកំណត់ត្រារបស់សុជាតា ។

នៅពេលសរសេរចប់ ចូរអ្នកអានកំណត់ត្រានោះនៅក្នុងក្រុមអ្នក ដើម្បីឱ្យពួកគេជួយកែលម្អឱ្យកាន់តែប្រសើរ ។

ថ្ងៃទី.......... ខែ.......... ឆ្នាំ................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

មេរៀនទី ៧

# ទូរគមនាគមន៍នៅកម្ពុជា



ក្នុងការរស់នៅប្រចាំថ្ងៃ មនុស្សគ្រប់រូបតែងត្រូវការទំនាក់ទំនងគ្នាទៅវិញទៅមក ។ បច្ចុប្បន្ននេះ មានមធ្យោបាយជាច្រើនសម្រាប់ទាក់ទងគ្នាទាំងនៅក្នុងប្រទេស ក៏ដូចជានៅក្រៅប្រទេសដែរ ។ មធ្យោបាយទាំងនោះមានដូចជា សំបុត្រ វិទ្យុទាក់ទង ទូរស័ព្ទ ទូរសារ និងអ៊ីនធឺណិតជាដើម ។ ដោយសារបច្ចេកវិទ្យាកាន់តែទំនើប ការធ្វើទំនាក់ទំនងគ្នាតាមប្រព័ន្ធទូរគមនាគមន៍កាន់តែមានភាពងាយស្រួល និងរហ័សទាន់ចិត្ត ។

## ការផ្ដល់មូលហេតុដើម្បីគាំទ្រមតិដកស្រង់ចេញពីសំបុត្រ

នៅក្នុងសំបុត្រ អ្នកសរសេរច្រើនបញ្ចេញមតិ យោបល់ ឬគំនិតរបស់ខ្លួន ។ រីឯអ្នកអានវិញក៏មានមតិ យោបល់ ឬគំនិតរបស់ខ្លួន ក្នុងការជំទាស់ ឬគាំទ្រដែរ ។ តើមូលហេតុអ្វីបានជាគាំទ្រ ? ចូរអានសំបុត្រខាងក្រោម រួចសិក្សាពីមូលហេតុដែលនាំឱ្យគេគាំទ្រមតិនៅក្នុងសំបុត្រនេះ ។

ព្រៃវែង ថ្ងៃទី ២០ ខែមីនា ឆ្នាំ២០១០

### មកដល់សត្យា !

សត្យា! រយៈពេលជាច្រើនខែមកហើយ ដែលខ្ញុំបានឃ្លាតឆ្ងាយពីមិត្ត ។ ក្នុងរយៈពេលនេះ ខ្ញុំតែងតែនឹកមមៃមកដល់សម្លាញ់ជានិច្ច ។ រាត្រីនេះ ខ្ញុំគេងមិនលក់សោះទើបខ្ញុំខិតខំផ្ចង់អារម្មណ៍ រិះរកពាក្យពេចន៍មកសរសេរជាសំបុត្រនេះ ។ សម្លាញ់! តើឯងនឹករំឭកមកដល់ខ្ញុំទេ ? តើឯងមានសេចក្ដីសុខដែរ ឬយ៉ាងណា ? បើឯងបានសេចក្ដីសុខ ខ្ញុំពិតជាត្រេកអររកអ្វីមកប្រៀបផ្ទឹមគ្មាន ។ ចំណែកខ្ញុំវិញ នៅឯនេះមានសេចក្ដីសុខជាធម្មតាទេ ហើយតែងនឹកមកឯងជានិច្ច ។ ខ្ញុំមិនអាចរកពាក្យអ្វី មកសរសេររៀបរាប់ឱ្យត្រូវនឹងទំហំនៃសេចក្ដីនឹករំឭករបស់ខ្ញុំ ចំពោះឯងបានឡើយ ។

សត្យា! អនុស្សាវរីយ៍របស់យើងទាំងពីរ កំពុងដិតនៅជាប់នឹងដួងចិត្តខ្ញុំជានិច្ច ។ យើងធ្លាប់អានសៀវភៅជាមួយគ្នា ធ្វើលំហាត់ជាមួយគ្នា ។ យើងទៅណាមកណាពីរនាក់ជានិច្ច ។ ឯងឆ្លាតណាស់ ឆាប់ចេះ ឆាប់យល់ រហ័សចាំ ហើយឧស្សាហ៍ទៀតផង ។ ខ្ញុំមិនដឹងថា សម្លាញ់នៅចាំរឿងរ៉ាវទាំងនេះដែរ ឬអត់ ?

អូ! ខ្ញុំភ្លេចនិយាយប្រាប់ឯង សព្វថ្ងៃក្រៅពីរៀននៅសាលារដ្ឋ ខ្ញុំរៀនភាសាអង់គ្លេស និងកុំព្យូទ័របន្ថែមទៀត ។ ឥឡូវ ខ្ញុំអាចប្រើអ៊ីនធឺណិតបានខ្លះៗហើយ ។ ខ្ញុំជឿថាឯងក៏ចេះប្រើប្រាស់វាដែរនៅពេលខាងមុខ ហើយឆាប់ចេះប្រើជាងខ្ញុំផង ប្រសិនឯងបានរៀន ។ យប់ជ្រៅណាស់ហើយ ខ្ញុំសូមបញ្ចប់អក្ខរាតែត្រឹមនេះចុះ ។

តាមរយៈសំបុត្រដ៏ខ្លីនេះ ខ្ញុំសូមផ្ញើសេចក្ដីនឹករឭកដល់មិត្តភក្ដិទាំងអស់ និងអ្នកភូមិយើងផង ។ ចុងបញ្ចប់នេះ ខ្ញុំសុំឱ្យសត្យា និងក្រុមគ្រួសារបានជួបតែសេចក្ដីសុខគ្រប់ ទិវារាត្រី ។

ពីមិត្តជានិរន្តរ៍

នាសា

- មតិដែលមាននៅក្នុងសំបុត្រនេះ ៖

ខ្ញុំជឿថា ប្រសិនបើឯងបានរៀន ឯងក៏ចេះប្រើវាដែរនៅពេលខាងមុខ ហើយឆាប់ចេះប្រើជាងខ្ញុំផង ។

- ការផ្ដល់មូលហេតុគាំទ្រមតិរបស់នាសានៅក្នុងសំបុត្រ ៖

បានជានាសានិយាយថា“ ខ្ញុំជឿថា ឯងក៏ចេះប្រើវាដែរនៅពេលខាងមុខ ហើយឆាប់ចេះប្រើជាងខ្ញុំផង” ពីព្រោះសត្យាជាក្មេងឆ្លាតណាស់ រៀនអ្វីឆាប់ចេះ ឆាប់យល់ រហ័សចាំ ហើយឧស្សាហ៍ទៀត ។

ការផ្ដល់មូលហេតុដើម្បីគាំទ្រមតិយោបល់ ឬគំនិតនៅក្នុងសំបុត្រ គឺជាការលើកយកមូលហេតុផ្សេងៗ ដែលសមស្របមកពន្យល់បញ្ជាក់ដើម្បីគាំទ្រមតិយោបល់ ឬគំនិតនេះ ។

## លំហាត់

ចូរអ្នកអានសំបុត្រខាងក្រោម រួចផ្តល់មូលហេតុដើម្បីគាំទ្រមតិរបស់កុសលនៅក្នុងសំបុត្រនោះ ។

កំពង់ឆ្នាំង ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១០

**មកដល់មាណវិកា !**

មាណវិកា! ខ្ញុំទើបតែបានទទួលដំណឹងថ្មីៗថា គ្រួសារឯងរងគ្រោះដោយខ្យល់ព្យុះកាលពីយប់ថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១០ ធ្វើឱ្យផ្ទះឯងដួលរលំ ព្រមទាំងខូចខាតទ្រព្យសម្បត្តិមួយចំនួនទៀតផង ។

គ្រាន់តែបានទទួលដំណឹងនេះភ្លាម ខ្ញុំមានចិត្តរន្ធត់ និងសោកស្តាយខ្លាំងណាស់ចំពោះគ្រោះមហន្តរាយដែលបានបំផ្លាញផ្ទះសម្បែង និងទ្រព្យសម្បត្តិរបស់គ្រួសារមិត្ត ។ ខ្ញុំសូមចូលរួមសោកស្តាយមិត្ត ព្រមទាំងគ្រួសារទាំងអស់ ដោយទឹកចិត្តស្មោះអស់ពីដួងចិត្តហើយសង្ឃឹមថា ក្រុមគ្រួសាររបស់មិត្តនឹងឆាប់បានធូរស្រាលពីការលំបាក ។

សូមមិត្តនិងគ្រួសារ បានជួបប្រទះតែសេចក្តីសុខគ្រប់ប្រការ ។

ពីកល្យាណមិត្ត

កុសល

ចូរជ្រើសរើសចម្លើយមួយដែលបង្ហាញមូលហេតុ ដើម្បីគាំទ្រមតិខាងលើ“ ខ្ញុំមានចិត្តរន្ធត់ និងសោកស្តាយខ្លាំងណាស់” ។

១. ពីព្រោះការរងគ្រោះនេះ ធ្វើឱ្យអ្នកផងអាណិតអាសូរ ។

២. ពីព្រោះការរងគ្រោះនេះ ធ្វើឱ្យមាណវិកាបាត់បង់ជម្រក និងទ្រព្យសម្បត្តិ ។

៣. ពីព្រោះការរងគ្រោះនេះ ធ្វើឱ្យពិបាកដល់អ្នកដទៃ ។

# សំបុត្រឯកជន

ចូរអានសំបុត្រខាងក្រោម តើជាប្រភេទសំបុត្រអ្វី ? តើសំបុត្រនេះ និយាយអំពីអ្វី ?

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០

**បងស្រីជាទីគោរពនិងជាទីនឹករំឭក!**

បងស្រី! អស់រយៈពេលជាយូរមកហើយ ដែលខ្ញុំបានឃ្លាតពីបងស្រី និងភូមិកំណើតមករស់នៅភ្នំពេញជាមួយលោកអ៊ំ ។ ក្នុងរយៈពេលដ៏យូរនេះ ខ្ញុំពុំបានដឹងសុខទុក្ខរបស់បងស្រីទេ ។ ខ្ញុំមានក្ដីនឹករំឭកបងស្រីជានិច្ច ។ តើបងស្រី មានចិត្តនឹករំឭកប្អូនទេ? សព្វថ្ងៃ ខ្ញុំនិងលោកអ៊ំនៅឯភ្នំពេញមានសេចក្ដីសុខធម្មតាទេ ។ តើបងស្រីមានសេចក្ដីសុខដែរ ឬយ៉ាងណា? ឯការសិក្សារបស់បងវិញយ៉ាងណាដែរ ?

បងស្រីជាទីនឹករំឭក! ខ្ញុំសូមជម្រាបបងថា កាលពីមកដល់ភ្នំពេញដំបូង ខ្ញុំឃើញចរាចរណ៍តាមផ្លូវណែនណាន់តាន់តាប់ ខ្ញុំពុំហ៊ានដើរចេញពីផ្ទះទេ ។ ខ្ញុំមានអារម្មណ៍ថាភ្នំពេញពិបាករស់នៅណាស់ តែឥឡូវនេះទៅជាធម្មតាដូចគេ ដូចឯង ។ សព្វថ្ងៃ នៅសាលារៀន ខ្ញុំយកចិត្តទុកដាក់រៀនសូត្រណាស់ ។ នៅផ្ទះ ខ្ញុំខិតខំមើលមេរៀន ធ្វើលំហាត់ និងរៀនភាសាអង់គ្លេសបន្ថែមទៀត ។ ការសិក្សារបស់ខ្ញុំ ទទួលបានលទ្ធផលល្អជារៀងរាល់ខែ ។ ខ្ញុំប្រាកដជាប្រឡងជាប់មិនខាន ។ ក្រៅពីការសិក្សា ខ្ញុំឆ្លៀតជួយបោសសម្អាត ស្រោចផ្កាជាដើម ។ ចាប់ពីពេលនេះទៅ ខ្ញុំប្ដេជ្ញាចិត្តថា នឹងខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានពូកែ ធ្វើជាមនុស្សល្អ មិនឱ្យបងស្រីអស់សង្ឃឹមឡើយ ។ សូមបងស្រីកុំព្រួយបារម្ភពីខ្ញុំឱ្យសោះ ។

ជាមួយគ្នានេះដែរ ខ្ញុំក៏សូមផ្ញើនូវសេចក្ដីនឹករំឭកដ៏លើសលប់ក្រៃលែង និងការសួរសុខទុក្ខពីចម្ងាយផង ចំពោះលោកពូ អ្នកមីង ញាតិជិតខាង អ្នកភូមិទាំងអស់គ្នា ជាពិសេសមិត្តភក្ដិរបស់ខ្ញុំ ។ សូមបងស្រីជួបប្រទះនូវពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ ។

ពីប្អូនប្រុសសម្លាញ់ចិត្តរបស់បង

មាស ចន្ទដែន

## សំណួរ

១. តើសំបុត្រនេះ ជាប្រភេទសំបុត្រអ្វី ?

២. តើអ្នកណា ជាអ្នកសរសេរសំបុត្រនេះ ? តើគេសរសេរផ្ញើទៅជូនអ្នកណា ?

៣. តើសំបុត្រនេះ មានខ្លឹមសារសំខាន់ដូចម្ដេចខ្លះ ?

៤. តើសំបុត្រនេះ ចែកចេញជាប៉ុន្មានផ្នែក ? គឺអ្វីខ្លះ ?

## លំហាត់

ចូរអានខាងក្រោម តើល្បះណាខ្លះ បង្ហាញមតិយោបល់ផ្ទាល់ខ្លួនរបស់អ្នកសរសេរ ។ តើល្បះណាខ្លះបង្ហាញពីការពណ៌នា ។

១. ខ្ញុំប្រាកដជាប្រឡងជាប់មិនខាន ។

២. ខ្ញុំសូមជម្រាបបងថា ខ្ញុំឃើញចរាចរណ៍ណែនណាន់តាន់តាប់ខ្ញុំមិនហ៊ានដើរចេញពីផ្ទះទេ ។

៣. សព្វថ្ងៃ ខ្ញុំយកចិត្តទុកដាក់រៀនសូត្រណាស់ ។

៤. ចាប់ពីពេលនេះទៅ ខ្ញុំប្ដេជ្ញាចិត្តថានឹងខិតខំរៀនសូត្រឱ្យបានពូកែ ។

៥. ការសិក្សារបស់ខ្ញុំ ទទួលបានលទ្ធផលល្អ ជារៀងរាល់ខែ ។

៦. ក្រៅពីការសិក្សា ខ្ញុំឆ្លៀតជួយបោសសម្អាត ស្រោចផ្កាជាដើម ។

៧. ដំបូងខ្ញុំមានអារម្មណ៍ថា ភ្នំពេញពិបាករស់នៅណាស់ តែឥឡូវនេះទៅជាធម្មតាដូចគេដូចឯង ។

# កម្រិតគុណនាម

អ្នកបានសិក្សារួចមកហើយ អំពីប្រភេទនៃគុណនាម ។ ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីកម្រិតរបស់គុណនាម ។ ចូរអានឧទាហរណ៍ខាងក្រោម ពាក្យមានគំនូសពីក្រោម បង្ហាញពីកម្រិតរបស់គុណនាម ។

| កម្រិតស្មើ | កម្រិតមិនស្មើ | កម្រិតផ្តាច់ |
|---|---|---|
| ១. សានជាសិស្សពូកែដូចនារីដែរ ។ | ១. សានជាសិស្សពូកែជាងនារី ។ | ១. សានជាសិស្សពូកែជាងគេ ។ |
| ២. នាងមានកាតាបស្អាតដូចកាតាបបងស្រីខ្ញុំដែរ ។ | ២. នាងមានកាតាបស្អាតជាងកាតាបបងស្រីខ្ញុំ ។ | ២. នាងមានកាតាបស្អាតដាច់គេ ។ |
| ៣. គាត់មានរាងខ្ពស់ប្រហែលពូខ្ញុំ ។ | ៣. គាត់មានរាងខ្ពស់លើសពូខ្ញុំ ។ | ៣. គាត់មានរាងខ្ពស់លើសគេបំផុត ។ |
| ៤. សុខទទួលបានពិន្ទុច្រើនស្មើនឹងខ្ញុំដែរ ។ | ៤. សុខទទួលបានពិន្ទុច្រើនជាងខ្ញុំ ។ | ៤. សុខទទួលបានពិន្ទុច្រើនបំផុត ។ |

- ឧទាហរណ៍ក្នុងខ្ទង់ទី១បង្ហាញគុណនាមកម្រិតស្មើ ។ គេប្រើពាក្យ “ ដូច ប្រហែល ស្មើ ” ។
- ឧទាហរណ៍ក្នុងខ្ទង់ទី២បង្ហាញគុណនាមកម្រិតមិនស្មើ ។ គេប្រើពាក្យ“ ជាង លើស ” ។
- ឧទាហរណ៍ក្នុងខ្ទង់ទី៣បង្ហាញគុណនាមកម្រិតផ្តាច់ ។ គេប្រើពាក្យ“ ជាងគេ ដាច់គេ ” ។

កម្រិតគុណនាមមាន កម្រិតស្មើ កម្រិតមិនស្មើ និងកម្រិតផ្តាច់ ។

# លំហាត់

ក. ចូរបំពេញល្បះខាងក្រោម ដោយប្រើកម្រិតគុណនាមឱ្យបានត្រឹមត្រូវ ។

១. តារាជាកីឡាករពូកែ.......... ។

២. កុមារីបានពិន្ទុល្អ............... កុមារា ។

៣. ស្រ្តីក៏មានប្រាជ្ញាឈ្លាសវៃ............ បុរសដែរ ។

៤. ភូមិគ្រឹះនេះធំ............ ។

៥. ការផ្ញើសារតាមអ៊ីមែល.............. ការផ្ញើសារតាមសំបុត្រ ។

ខ. ចូរតែងល្បះនឹងគុណនាមនីមួយៗខាងក្រោម ឱ្យបានត្រឹមត្រូវតាមកម្រិត ។

| គុណនាម | កម្រិតស្មើ | កម្រិតមិនស្មើ | កម្រិតផ្តាច់ |
|---|---|---|---|
| ធំ | .................... | .................... | .................... |
| ថ្លៃ | .................... | .................... | .................... |
| ល្អ | .................... | .................... | .................... |
| លឿន | .................... | .................... | .................... |

# សំបុត្រផ្ទាល់ខ្លួន

## សំណួរ

១. តើសំបុត្រនេះ ជាប្រភេទសំបុត្រអ្វី ?

២. តើអ្នកសរសេរសំបុត្រ ប្រុស ឬស្រី ?

៣. តើអ្នកទទួលសំបុត្រ ប្រុស ឬស្រី ?

៤. តើអ្នកសរសេរសំបុត្រ មានអាយុប៉ុន្មាន ?

៥. តើអ្នកទទួលសំបុត្រ មានអាយុប៉ុន្មាន ?

៦. តើអ្នកសរសេរសំបុត្រ និងអ្នកទទួលសំបុត្រស្គាល់គ្នាក្នុងរយៈពេលប្រហែលប៉ុន្មាន ?

## លំហាត់

នៅក្នុងសំបុត្រ អ្នកសរសេរមានយោបល់ថា បងសូមចាត់ទុកប្អូន ជាប្អូនប្រុសបង្កើត ។ ហេតុអ្វីបានជាវិបុល ចាត់ទុកសូផាតជាប្អូនប្រុសបង្កើត ? ចូរអ្នកផ្ដល់មូលហេតុដើម្បីគាំទ្រមតិខាងលើ ។

# ឈ្នាប់និងផ្នែកទាក់ទងនៃល្បះ

ក្នុងការនិយាយ ឬសរសេរ យើងតែងតែបញ្ចេញគំនិតពីរ ឬច្រើននៅពេលជាមួយគ្នា ។ គំនិតទាំងនោះ អាចជាពាក្យ កន្សោមពាក្យ ឬល្បះ ។ ដើម្បីឱ្យគំនិតទាំងនោះ ជាប់ទាក់ទងគ្នា គេប្រើពាក្យសម្រាប់ភ្ជាប់ ។ ពាក្យទាំងនោះ មានឈ្មោះថា“ឈ្នាប់” ។

ចូរអានឧទាហរណ៍ខាងក្រោម តើពាក្យណាខ្លះជា ឈ្នាប់ចង ឬចំណងឈ្នាប់ ។

ឧទាហរណ៍ ៖

១. ការទាក់ទងគ្នាតាមទូរស័ព្ទ នាំឱ្យចំណេញពេលវេលា និងថវិកា ។

២. បច្ចុប្បន្ននេះ យើងអាចទាក់ទងគ្នាតាមទូរស័ព្ទ ឬសំបុត្រ ។

៣. ឪពុកខ្ញុំមានទូរស័ព្ទដៃ ប៉ុន្តែគាត់គ្មានទូរស័ព្ទលើតុទេ ។

- ក្នុងឧទាហរណ៍ទី១ ពាក្យ “ និង” ភ្ជាប់ពាក្យ “ ពេលវេលា” និងពាក្យ “ ថវិកា” ។ ពាក្យ “ ពេលវេលា” និងពាក្យ“ ថវិកា” ជាធាតុនៃល្បះ ។
- ក្នុងឧទាហរណ៍ទី២ ពាក្យ“ឬ”ភ្ជាប់ពាក្យ“ទូរស័ព្ទ” និងពាក្យ“សំបុត្រ” ។ ពាក្យ“ ទូរស័ព្ទ” និងពាក្យ“ សំបុត្រ” ជាធាតុនៃល្បះ ។
- ក្នុងឧទាហរណ៍ទី៣ ពាក្យ “ប៉ុន្តែ”ភ្ជាប់ល្បះ“ឪពុកខ្ញុំមានទូរស័ព្ទដៃ” និងល្បះ “គាត់គ្មានទូរស័ព្ទលើតុទេ” ។

ពាក្យ“និង ឬ ប៉ុន្តែ” ជាឈ្នាប់ចង ។

ឈ្នាប់ចងមាន ៖ “និង ហើយ តែ ប៉ុន្តែ ឬ...” ។

ឈ្នាប់ចង គឺជាពាក្យចំណងសម្រាប់ភ្ជាប់ ពាក្យនិងពាក្យ កន្សោមពាក្យនិងកន្សោមពាក្យ ឬល្បះនិងល្បះ ។

## លំហាត់

ក. ចូរបំពេញល្បះខាងក្រោម ដោយប្រើឈ្នាប់ចងឱ្យបានត្រឹមត្រូវ ។

១. ដើម្បីទាក់ទងគ្នា អ្នកខ្លះប្រើទូរស័ព្ទ.....អ្នកខ្លះទៀតប្រើអ៊ីមែល ។

២. កាលពីមិនទាន់មានភាសានិយាយ មនុស្សប្រើសញ្ញា.....កាយវិការ ដើម្បីទាក់ទងគ្នា ។

៣. អ្នកភូមិខ្ញុំ ប្រកបរបរធ្វើស្រែចម្ការ.....នេសាទត្រី ។

៤. បងប្រុសខ្ញុំ ចូលចិត្តប្រើទូរស័ព្ទ.....គាត់មិនចូលចិត្តសរសេរសំបុត្រទេ ។

ខ. ចូរតែងល្បះដោយប្រើឈ្នាប់ចង“ និង ឬ ប៉ុន្តែ ” ក្នុងមួយពាក្យឱ្យបានមួយល្បះ ។

# រឿង កំណើតទូរស័ព្ទ



នៅឆ្នាំ ១៨៧៦ លោកអាឡិចសាន់ដឺ ក្រាហាំបែល និងជំនួយការរបស់គាត់ម្នាក់ឈ្មោះវីល្លីហាប់ប៊ីត បានធ្វើដំណើរពីបូស្តុនទៅកាន់ហ្វីឡាដែលហ្វី ដើម្បីចូលរួមក្នុងពិធីតាំងពិព័រណ៍ ។ គាត់បានយកផលិតផលវិទ្យាសាស្ត្រ ដែលគាត់ទើបផលិតបានទៅដាក់តាំងពិព័រណ៍ ។ លោកបែលអង្គុយក្បែរផលិតផលរបស់គាត់ រីឯវីល្លីវិញអន្ទះអន្ទែងរកមើលគណៈកម្មការមកត្រួតពិនិត្យ និងវាយតម្លៃ ។ ពេលឃើញគណៈកម្មការដើរចូលមក វីល្លីពោល ៖“នុះន៏! លោកឡូតខេវិន! គាត់ជាអ្នកវិទ្យាសាស្ត្រដ៏ល្បីល្បាញជាងគេ ។ ចុះអ្នកណានោះ! មានសក់ក្រហម និងពុកចង្កាវែងជាងសក់ទៅទៀត ?” ។ លោកបែលតប ៖“នោះ គឺជាអធិរាជនៃប្រទេសប្រេស៊ីលមានព្រះនាមថា ដុនប៉េដ្រូ” ។ វីល្លីសួរ ៖“ តើឯងធ្លាប់ស្គាល់ទ្រង់ ឬ ?” ។ លោកបែលឆ្លើយ ៖“ មែនហើយ! គាត់នៅបូស្តុន!” ។ ពេលគណៈកម្មការមកជិតដល់ ព្រះចៅដុនប៉េដ្រូក្រឡេកឃើញ លោកបែលទ្រង់មានបន្ទូល ៖ “ អ៊ូ ! លោកបែល! តើលោកបានអ្វីមកបង្ហាញទីនេះ ?” ។ លោកបែលឆ្លើយ៖“ នេះ គឺជាទូរស័ព្ទ ។ ឧបករណ៍នេះ អាចធ្វើឱ្យមនុស្សពីរនាក់ ដែលនៅកន្លែងផ្សេងគ្នា

និយាយឆ្លើយឆ្លងគ្នាបាន" ។ ព្រះអង្គទ្រង់បញ្ជា ៖ " សូមលោកបែល ចាប់ផ្តើមបង្ហាញទៅ!" ។ លោកបែលពន្យល់ ៖"ទូរស័ព្ទនេះ អាចនាំសំឡេងមនុស្សតាមខ្សែអគ្គិសនី ។ មនុស្សដែលឈរនៅចុងម្ខាង អាចស្តាប់ឮអ្នកដែលនៅខាងចុងម្ខាងទៀតនិយាយ ដូចគេឈរនិយាយក្បែរគ្នាដែរ" ។ លោកបែលនិងវីល្លី បានធ្វើបង្ហាញគណៈកម្មការ រួចបានឱ្យព្រះចៅអធិរាជសាកល្បងមុនគេ ។ មួយរំពេចនោះ ព្រះអង្គមានបន្ទូលដោយរំភើប ៖" អស្ចារ្យណាស់! ពិតជាអាចនិយាយគ្នាបានមែន!" ។ គណៈកម្មការបានសាកល្បងម្នាក់ម្តងៗ ហើយសរសើរគ្រប់ៗគ្នា ។

ព្រះចៅអធិរាជដុនប៉េដ្រូមានបន្ទូលថា លោកបែលជាមនុស្សឆ្នើមដូចអ្នកស្រាវជ្រាវមុនៗដែរ ។ ឧបករណ៍ដែលលោកបង្កើត អាចកែប្រែរបៀបរស់នៅរបស់មនុស្សក្នុងសង្គមបាន ។ លោកប្រាកដជា បានទទួលរង្វាន់មិនខានឡើយ ។

(ដកស្រង់និងកែសម្រួលពីអត្ថបទលោក កាតេរីនបីស៊្តីដី)

## សំណួរ

១. តើលោកបែល និងវីល្លីធ្វើដំណើរទៅណា ? តើគាត់ទៅទីនោះដើម្បីអ្វី ?

២. តើអ្នកវិទ្យាសាស្ត្រល្បីល្បាញជាងគេឈ្មោះអ្វី ?

៣. តើលោកបែលស្រាវជ្រាវរកឃើញអ្វី ? នៅឆ្នាំណា ?

៤. តាមគំនិតរបស់អ្នកផ្ទាល់ តើអ្នកឱ្យតម្លៃលោកបែលជាមនុស្សដូចម្តេច ?

៥. តើអត្ថបទនេះ មានខ្លឹមសារសំខាន់ៗអ្វីខ្លះ ?

## លំហាត់

ក. ចូរស្រង់ល្បះដែលប្រើឈ្នាប់ចងក្នុងអត្ថបទអំណាន ឱ្យបាន ៣ ល្បះ និងប្រាប់ឈ្នាប់ចងទាំងនោះ ។

ខ. ចូរស្រង់ល្បះដែលប្រើកម្រិតគុណនាមផ្សេងៗគ្នា ដែលមានក្នុងអត្ថបទអំណាន ឱ្យបាន៣ ល្បះ ។

គ. ចូររកពាក្យន័យដូចនឹងពាក្យ"អធិរាជ បន្ទូល" ។

# សំបុត្រសួរសុខទុក្ខ

កន្លងមក ដើម្បីឆ្លើយឆ្លងគ្នា ទាក់ទងគ្នា ឬផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក គេនិយមសរសេរសំបុត្រ ។ សំបុត្រមានច្រើនប្រភេទ ហើយមានទម្រង់សំណេរប្លែកៗគ្នា ។ សំបុត្រឯកជន គឺសំបុត្រធម្មតាសម្រាប់ផ្ញើដំណឹងសួរសុខទុក្ខ ឬធ្វើទំនាក់ទំនងអ្វីមួយចំពោះគ្រួសារ សាច់ញាតិ និងមិត្តភក្តិដែលនៅឆ្ងាយពីគ្នា ។

ការសរសេរសំបុត្រជាការសំខាន់មួយ ដែលយើងត្រូវតែផ្ចិតផ្ចង់ ដោយប្រើពាក្យគួរសម សុជីវធម៌ ងាយយល់ ច្បាស់លាស់ ត្រឹមត្រូវដោយសង្ខេបខ្លឹមសារ ឬសេចក្តីសំបុត្រឱ្យខ្លីល្មម កុំឱ្យវែងហួសប្រមាណ ដើម្បីឱ្យអ្នកអានងាយយល់ ។

តាមធម្មតា ការសរសេរសំបុត្រត្រូវចែកជាបីផ្នែកគឺ ក្បាលសំបុត្រ តួសំបុត្រ និងការបញ្ចប់សំបុត្រ ៖

១. ក្បាលសំបុត្រ

- ត្រូវចុះឈ្មោះ ទីកន្លែង និងកាលបរិច្ឆេទនៃការសរសេរ
- ចំណងជើងសំបុត្រ

២. តួសំបុត្រ

- ដំបូង ត្រូវរៀបរាប់អំពីសុខទុក្ខផ្ទាល់ខ្លួនរបស់អ្នកសរសេរ
- បន្ទាប់មក សួរសុខទុក្ខអ្នកដែលទទួលសំបុត្រ និងសរសេររៀបរាប់រឿងរ៉ាវផ្សេងៗមានដូចជា ដំណឹង ដំបូន្មាន... ដែលអ្នកសរសេរ និងអ្នកទទួលមានទំនាក់ទំនងជាមួយគ្នា ។

៣. ការបញ្ចប់សំបុត្រ

- ត្រូវជូនពរ (ត្រូវប្រើពាក្យសមស្របនឹងកាលៈទេសៈ) និងជូនកាលអាចភ្ជាប់ឃ្លាបញ្ចប់សំបុត្រដូចជា“ ពីកូនសម្លាញ់ចិត្តរបស់ម៉ែ ឬនឹកជានិច្ច...”
- ទីបញ្ចប់ ត្រូវចុះហត្ថលេខា និងឈ្មោះអ្នកសរសេរ ។

## លំហាត់

ឪពុកអ្នកបានចាកចេញពីស្រុកកំណើត ទៅរស់នៅកន្លែងមួយផ្សេងទៀត ហើយអ្នកត្រូវផ្លាស់ទៅរៀននៅកន្លែងថ្មីនោះ ។

ចូរអ្នកសរសេរសំបុត្រមួយច្បាប់ ផ្ញើទៅសួរសុខទុក្ខមិត្តភក្តិរបស់អ្នក ដែលធ្លាប់រៀនជាមួយគ្នានៅស្រុកកំណើត ដើម្បីប្រាប់ពីសុខទុក្ខ និងការរៀនសូត្ររបស់អ្នក ដោយប្រើទម្រង់សំបុត្រខាងលើ ។

## ការរៀបរាប់ពីមធ្យោបាយទាក់ទងគ្នា

ព្រឹកមួយ អ្នកគ្រូរៀបនឹងចាប់ផ្ដើមបង្រៀន ស្រាប់តែម្ដាយធីតាទូរស័ព្ទមកសុំច្បាប់អ្នកគ្រូ ។ ចូរអានការសន្ទនារវាងអ្នកគ្រូ និងសិស្សក្នុងថ្នាក់ ។

អ្នកគ្រូ : សួស្ដីកូនៗ! ព្រឹកមិញនេះ ម្ដាយធីតាបានទូរស័ព្ទមកសុំច្បាប់អ្នកគ្រូ ព្រោះធីតាឈឺ ។ អ្នកទាំងអស់គ្នានៅពេលឈឺ ឬមានធុរៈចាំបាច់ត្រូវជម្រាបសុំច្បាប់អ្នកគ្រូមិនត្រូវឈប់ដោយឥតច្បាប់ទេ ។

មេត្តា : សូមទោសអ្នកគ្រូ! បើម្ដាយ ឪពុកខ្ញុំគ្មានទូរស័ព្ទ តើគាត់ត្រូវធ្វើដូចម្ដេច ?

អ្នកគ្រូ : អ្នកទាំងអស់បានរៀនរួចហើយ អំពីមធ្យោបាយសម្រាប់ទាក់ទងគ្នា ។ អ្នកណាអាចរៀបរាប់បាន តើមធ្យោបាយសម្រាប់ទាក់ទងគ្នាមានអ្វីខ្លះ ?

សុខា : ចាសអ្នកគ្រូ! មធ្យោបាយធ្វើទំនាក់ទំនងមានសំបុត្រ ទូរស័ព្ទ ទូរសារ និងអ៊ីនធឺណិតជាដើម ។

អ្នកគ្រូ : តើក្នុងសហគមន៍យើង អាចប្រើប្រាស់មធ្យោបាយអ្វីខ្លះ?

តុលា : បាទអ្នកគ្រូ! គឺយើងអាចប្រើសំបុត្រ ឬទូរស័ព្ទ ។

អ្នកគ្រូ : ល្អណាស់! មធ្យោបាយធ្វើទំនាក់ទំនងមានច្រើន តែនៅក្នុងសហគមន៍យើងពុំទាន់មានអ៊ីនធឺណិតទេ ។ យើងគួរប្រើសំបុត្រ ឬមកទាក់ទងគ្នាដោយផ្ទាល់តែម្ដង ទើបជាការសមរម្យ និងគាប់ប្រសើរជាងការសុំច្បាប់តាមទូរស័ព្ទ ។

## លំហាត់

ចូររៀបគ្នាជាក្រុមតូចៗ ។ ក្រុមនីមួយៗ ត្រូវនិយាយប្រាប់គ្នាទៅវិញទៅមក អំពីមធ្យោបាយសម្រាប់ទាក់ទង នៅក្នុងសហគមន៍របស់ខ្លួន ។

## សំបុត្រសូមអភ័យទោស

ដាំដាំ បានសរសេរសំបុត្រមួយច្បាប់ ទៅសូមអភ័យទោសពីមិត្តរបស់គេ ។ ចូរអ្នកអានសំបុត្រសូមអភ័យទោសខាងក្រោម តើវាមានទម្រង់ដូចម្ដេច ?

ស្ទឹងត្រែង ថ្ងៃទី ០៤ឧសភា ឆ្នាំ២០១០

**មកដល់ខាំថង!**

ខាំថង! ខ្ញុំនឹកស្ដាយណាស់ ដោយកាលពីម្សិលមិញ ខ្ញុំបានធ្វើអំពើមិនគួរគប្បីទៅលើមិត្ត ។ ខ្ញុំស្ដីបន្ទោស និងប្រើពាក្យគំរោះគំរើយមិនសមរម្យជាច្រើនចំពោះឯង ។ ខ្ញុំធ្វើអំពើទាំងនេះ មកពីខ្ញុំយល់ច្រឡំ ហើយម្យ៉ាងទៀតនៅពេលនោះខ្ញុំមានអារម្មណ៍មិនល្អ បណ្ដាលឱ្យខ្ញុំសម្ដែងអាកប្បកិរិយាមិនសមរម្យចំពោះមិត្តបែបនេះ ។ ក្រោយមក ទើបខ្ញុំពិចារណាឃើញថា ខ្ញុំមានកាយវិការមិនគប្បី ។ ខ្ញុំសូមអរគុណ និងកោតសរសើរមិត្តដោយស្មោះ ដែលមានចិត្តធូន់ ។ ខ្ញុំពិតជាអៀនខ្មាសនឹងអំពើ ដែលខ្ញុំបានប្រព្រឹត្តនាពេលនោះ ។ ខ្ញុំគិតថា មិត្តមិនសប្បាយចិត្ត ហើយអាក់អន់ ស្រពន់ចិត្តនឹងខ្ញុំពុំខាន ។

សូមមិត្តអភ័យទោសឱ្យខ្ញុំផងចុះ ចំពោះអំពើឆ្គាំឆ្គងទាំងឡាយរបស់ខ្ញុំទៅលើមិត្ត ។ ខ្ញុំចង់ទៅសុំអភ័យទោសពីមិត្តដោយផ្ទាល់ តែពីពេលនោះមកខ្ញុំពុំជួបមិត្តសោះ ។ ដោយខ្លាចពេលវេលាអូសបន្លាយ ខ្ញុំសម្រេចចិត្តសរសេរលិខិតសុំទោសមិត្តសិន ។ ខ្ញុំសង្ឃឹមថា បន្ទាប់ពីមិត្តបានអានសំបុត្រនេះ មិត្តនឹងអភ័យទោសដល់ខ្ញុំជាមិនខាន ។

**ពីមិត្តជិតស្និទ្ធរបស់អ្នក**

**ដាំដាំ**

## លំហាត់

អ្នកបានអានសំបុត្រ សូមអភ័យទោសរួចហើយ ។ ចូរអ្នកសរសេរសំបុត្រមួយច្បាប់ទៅសូមអភ័យទោសពីអ្នកណាម្នាក់ ដោយសារអ្នកបានធ្វើខុសទៅលើគេ តាមទម្រង់ខាងក្រោម ៖

១. ក្បាលសំបុត្រ

............ថ្ងៃទី.........ខែ.........ឆ្នាំ............

ចំណងជើងសំបុត្រ

២. តួសំបុត្រ

- សម្ដែងសេចក្ដីសោកស្ដាយ
- រៀបរាប់រឿងរ៉ាវផ្សេងៗ ដែលខ្លួនបានប្រព្រឹត្តខុស និងប្រាប់ពីមូលហេតុដែលនាំឱ្យប្អូនប្រព្រឹត្តអំពើនោះ

៣. ការបញ្ចប់សំបុត្រ

- ជូនកាលអាចភ្ជាប់ឃ្លាបញ្ចប់សេចក្ដីដូចជា ពីកូនរបស់ម៉ែ ពីមិត្ត អមតៈ ពីមិត្តជាទីរាប់អាន ...
- ចុងក្រោយ ចុះហត្ថលេខា និងឈ្មោះអ្នកសរសេរ

មេរៀនទី ៨

# ផលិតផលខ្មែរ


ផ្លែក្រូច ពោធិ៍សាត់


ផ្លែទុរេន


ត្រីងៀត


ហូល ផាមួង


គ្រែក្បាច់


ផ្តិលប្រាក់


ចម្លាក់ថ្មកែវ


ក្រមា


កាបូបធ្វើពីសូត្រ


កន្ទេលកក់

សព្វថ្ងៃនេះ ផលិតផលខ្មែរ មានការនិយមគាំទ្រខ្លាំងពីអតិថិជនក្នុង និងក្រៅប្រទេស ។ ផលិតផលទាំងនោះមានរូបចម្លាក់ ហូល ផាមួង ក្រមាសូត្រ កាបូបធ្វើអំពីសូត្រ ។ ល ។ អាស្រ័យដោយការខិតខំប្រឹងប្រែងពីមួយថ្ងៃទៅមួយថ្ងៃ ធ្វើឱ្យប្រជាជនខ្មែរយើងមានការយល់ដឹងកាន់តែខ្ពស់ក្នុងការផលិតសម្ភារៈប្រើប្រាស់ ការដាំដុះ ការកែច្នៃវត្ថុធាតុដើមឱ្យមានគុណភាពល្អប្រសើរ ដើម្បីទាក់ទាញអតិថិជនឱ្យកាន់តែកើនឡើងជាលំដាប់ ។

## ប្រធានបទនៃអត្ថបទ

អត្ថបទមួយបង្ហាញគំនិតធំមួយ ។ គំនិតនេះ ហៅថាប្រធានបទនៃអត្ថបទ ។ ល្បះនីមួយៗក្នុងអត្ថបទ ត្រូវទាក់ទងនឹងប្រធានបទនោះ ។

ចូរអានអត្ថបទខាងក្រោម តើអត្ថបទនេះនិយាយអំពីអ្វី ?

ខ្មែរជាជនជាតិ ដែលមានទេពកោសល្យខាងចម្លាក់ ។ អាស្រ័យហេតុនេះក្បាច់ចម្លាក់នីមួយៗ តែងតែផុសឡើងនៅជាប់នឹងសម្ភារៈប្រើប្រាស់ផ្សេងៗ និងវត្ថុតាំងលម្អមានតុ ទូ គ្រែ ផ្តិល ដងកាំបិត ដងស្លាបព្រា ដាវ ជើងពាន ប្រអប់ស្លាម្លូ ខ្សែក្រវាត់ និងវត្ថុច្រើនមុខទៀត ។ មិនតែប៉ុណ្ណោះនៅតាមហោជាង សសរ និងជញ្ជាំងព្រះវិហារក៏មានភាពរស់រវើកដែរ ។

អត្ថបទនេះ និយាយអំពី " ចម្លាក់ខ្មែរ" ។ " ចម្លាក់ខ្មែរ " ជាប្រធានបទរបស់អត្ថបទ ។ ប្រធានបទមានទម្រង់ជាកន្សោមពាក្យ ។ ប្រធានបទខ្លះ បង្ហាញតាមរយៈចំណងជើងរបស់អត្ថបទ តែប្រធានបទខ្លះមិនបានបង្ហាញទេ អ្នកអានត្រូវធ្វើការសំយោគទៅលើសេចក្តីលម្អិតដែលមាន ។

ប្រធានបទរបស់អត្ថបទ គឺអ្វីដែលល្បះភាគច្រើន ឬល្បះទាំងអស់ផ្តោតគំនិតសំខាន់ទៅលើ ។ ប្រធានបទ មានទម្រង់ជាកន្សោមពាក្យ ។

### លំហាត់

ចូរអ្នកអានអត្ថបទព័ត៌មានខាងក្រោម រួចប្រាប់ប្រធានបទនៃអត្ថបទ ។

សព្វថ្ងៃ ទោះជាមានស្ករសផលិតក្នុងប្រទេស និងស្ករនាំចូលពីបរទេសក៏ដោយ ក៏ស្ករត្នោតនៅតែជាទីនិយមចូលចិត្តរបស់ប្រជាជនខ្មែរ ។ ប្រជាកសិករខ្មែរ ប្រកបរបរធ្វើស្ករត្នោតនៅតាមទីកន្លែង ដែលមានដើមត្នោតច្រើន ។ ខ្មែរយើងមានវិធីគាបត្នោតយកទឹក និងវិធីរម្ងាស់ត្នោតយ៉ាងស្ទាត់ជំនាញ ។ ការធ្វើស្ករត្នោត ច្រើនបានទិន្នផលខ្ពស់នៅរដូវប្រាំង ។

# ផលិតផលនៅប្រទេសកម្ពុជា

ចូរអានអត្ថបទ រួចឆ្លើយនឹងសំណួរ ។



ប្រជាជនកម្ពុជា មានស្នាដៃខ្ពស់ក្នុងការផលិតសម្ភារៈប្រើប្រាស់ និងគ្រឿងតុបតែងច្រើនប្រភេទ ។ ជាក់ស្តែងនៅខេត្តសៀមរាប មានអ្នកជំនាញខាងឆ្លាក់ ឬជាប់ឈើ ស្បែក ស្ពាន់ និងថ្ម ធ្វើជារូបប្រាសាទ រូបអប្សរា ផ្តិល វែក ថូផ្កា កាបូប ។ល ។ ខេត្តកំពង់ឆ្នាំងសម្បូរផលិតផលធ្វើអំពីឫស្សី ផ្តៅ រពាក់ និងដី ។ ខេត្តកំពង់ចាម កណ្តាល ព្រៃវែង និងតាកែវប្រជាជនចូលចិត្តផលិតសម្ភារៈពីសរសៃសូត្រ អំបោះ និងកក់ ។ ពលរដ្ឋនៅទីនោះស្ទាត់ជំនាញក្នុងការត្បាញសារុងសូត្រ ក្រមាសូត្រ ស្បៃ ផាមួង ហូល និងកន្ទេល ។ នៅតំបន់ផ្សេងៗទៀត ប្រជាជនផលិតនេសាទុបករណ៍មាន ឈ្នាង អង្រុត មង អួន និងឧបករណ៍សម្រាប់ធ្វើស្រែចម្ការ ដូចជានង្គ័ល រនាស់ ផាល កណ្តៀវ ។ ជាទូទៅ នៅទីក្រុងឬទីប្រជុំជន គេច្រើនឃើញមានសិប្បកម្មស្លដែក ធ្វើថង់ប្លាស្ទិច ធ្វើគ្រឿងអលង្ការ ផ្តិលប្រាក់ ចានដែក និងរបស់របរអំពីជ័រទៀតផង ។

បច្ចុប្បន្ននេះ ប្រជាជនខិតខំកែច្នៃគុណភាពផលិតផលទាំងនោះឱ្យកាន់តែប្រសើរជាបន្តបន្ទាប់ ដើម្បីបម្រើតម្រូវការរបស់អតិថិជនក្នុង និងក្រៅប្រទេស ។

## សំណួរ

១. តើប្រជាជនកម្ពុជា មានស្នាដៃក្នុងការផលិតអ្វីខ្លះ ?

២. តើនៅខេត្តសៀមរាប មានផលិតផលធ្វើអំពីអ្វីខ្លះ ?

៣. តើខេត្តណាខ្លះ មានជំនាញខាងត្បាញសូត្រ និងអំបោះ ?

៤. តើនៅទីក្រុងភ្នំពេញ មានសិប្បកម្មធ្វើអ្វីខ្លះ ?

៥. តើប្រជាជនត្រូវធ្វើដូចម្តេច ដើម្បីឱ្យសម្ភារៈកាន់តែមានគុណភាព ?

## លំហាត់

ក. ចូរស្រង់គុណនាមចេញពីក្នុងអត្ថបទអំណាន ។

ខ. ចូរពន្យល់ន័យរបស់ពាក្យសិប្បកម្ម ។

គ. ចូរបង្ហាញប្រធានបទរបស់អត្ថបទ ដោយជ្រើសរើសចម្លើយសមស្របមួយ ។

- ☐ ១. ការកែច្នៃសម្ភារៈប្រើប្រាស់
- ☐ ២. ប្រភេទផ្សេងៗនៃផលិតផលខ្មែរ
- ☐ ៣. ការតុបតែងលម្អផ្ទះ ។

## ការឃោសនា

ជា រៀងរាល់ថ្ងៃ យើងតែងតែទទួលព័ត៌មានផ្សេងៗតាមរយៈវិទ្យុ ទូរទស្សន៍ កាសែត និងទស្សនាវដ្តី ។ ប៉ុន្តែអ្វីៗទាំងអស់ ដែលយើងបានស្តាប់ឮ ឬមើលឃើញនោះ មិនមែនសុទ្ធតែជាការពិតទាំងអស់នោះទេ ។ ព័ត៌មានខ្លះ មានលក្ខណៈបញ្ចុះបញ្ចូល ជំរុញ ទាក់ទាញទឹកចិត្តអ្នកអាន អ្នកស្តាប់ ឬអ្នកទស្សនាឱ្យមានជំនឿជាក់ ។ ព័ត៌មានបែបនេះហៅថា "ការឃោសនា" ។ គេសង្កេតឃើញមានការឃោសនាអំពីសាសនា កីឡា សិល្បៈ គណៈបក្ស ពិសេសឃោសនាផ្សាយពាណិជ្ជកម្មលក់ផលិតផលជាដើម ។ នៅក្នុងការឃោសនាលក់ផលិតផលគេតែងតែ ៖

- បង្ហាញឈ្មោះផលិតផល
- សរសើរគុណភាពល្អនៃផលិតផលនោះ

- បង្ហាញគុណប្រយោជន៍នៃផលិតផលនោះ
- អួតឈ្មោះក្រុមហ៊ុន
- ប្រើសិល្បវិធីសព្វបែបយ៉ាង ដើម្បីទាក់ទាញអតិថិជនគ្រប់រូប ។

ចូរអានអត្ថបទឃោសនាខាងក្រោម ។ តើអត្ថបទនេះ ប្រើសិល្បវិធីអ្វីខ្លះ ដើម្បីឱ្យអតិថិជនចាប់អារម្មណ៍ ?

## ដំណឹងពិសេស

ហាងលក់វត្ថុអនុស្សាវរីយ៍ "ស្នាដៃខ្មែរ" សូមជម្រាប ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាទីមេត្រីថា ហាង "ស្នាដៃខ្មែរ" យើងខ្ញុំមានលក់វត្ថុអនុស្សាវរីយ៍ច្រើនមុខដូចជា ក្រមាសូត្រ ក្រវាត់ក ផ្តិលប្រាក់ កាបូបដៃ គ្រឿងចម្លាក់ជាច្រើនមុខទៀត ដែលជាស្នាដៃដ៏សម្រិតសម្រាំងរបស់ខ្មែរយើង ហើយមានគុណភាពល្អដាច់គេ មានក្បាច់រចនាទាន់សម័យនិយម លក់ក្នុងតម្លៃថោកសមរម្យ ប្រើហើយធានាថាមិនខុសបំណងឡើយ ។

ជាពិសេសទៀត ដើម្បីអបអរពិធីបុណ្យចូលឆ្នាំថ្មី ហាងយើងខ្ញុំមានលក់បញ្ចុះតម្លៃជូន២០% ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅរហូតដល់ថ្ងៃទី៣០ ខែមេសាខាងមុខនេះ ។

សូមអញ្ជើញប្រញាប់ឡើង ព្រោះឱកាសល្អសម្រាប់លោកអ្នកមកដល់ហើយ ។ សូមកុំភ្លេចហាងលក់វត្ថុអនុស្សាវរីយ៍ "ស្នាដៃខ្មែរ" ដែលមានអាសយដ្ឋានតាមផ្លូវម៉ៅសេទុង សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

អត្ថបទខាងលើប្រើសិល្បវិធីមួយចំនួនដូចជា ៖

បញ្ជាក់គុណភាពនៃវត្ថុ ៖ ជាស្នាដៃដ៏សម្រិតសម្រាំង មានគុណភាពល្អដាច់គេមានក្បាច់រចនាទាន់សម័យនិយម ប្រើហើយធានាថាមិនខុសបំណង ។

ការទាក់ទាញ ៖តម្លៃថោកសមរម្យ បញ្ចុះតម្លៃ២០% ។

> ការឃោសនាជាការខិតខំរិះរកមធ្យោបាយផ្សព្វផ្សាយយោបល់ គំនិត ឬជំនឿផ្សេងៗ ក្នុងគោលបំណងអន្ទង ឬបញ្ចុះបញ្ចូលអ្នកដទៃឱ្យជឿ ។

## លំហាត់

ចូរអានសេចក្តីជូនដំណឹងខាងក្រោម ។

### សេចក្តីជូនដំណឹង

សិប្បកម្មចម្លាក់ "វិចិត្រអង្គរ" មានលក់គ្រឿងចម្លាក់គ្រប់មុខ ដែលមានក្បាច់រចនាតាមបែបចម្លាក់ខ្មែរអង្គរពីបុរាណ ។ សិប្បកម្មយើងខ្ញុំ មានគ្រឿងចម្លាក់ជារូបព្រះកេសព្រះបាទជ័យវរ្ម័នទី ៧ រូបព្រះពុទ្ធ ព្រះព្រហ្ម រូបប្រាសាទអង្គរវត្ត អប្សរា ដែលធ្វើអំពីថ្មកែវ ស្ពាន់ ប្រាក់ និងឈើដែលសុទ្ធ សឹងជាស្នាដៃរបស់សិល្បករខ្មែរ ដែលមានបទពិសោធន៍អស់រយៈពេលយូរឆ្នាំមកហើយ ។ លោកអ្នកដែលបានទិញយកទៅប្រើហើយតែងលាន់មាត់សរសើរគ្រប់ៗគ្នាថា ពិតជាមានគុណភាពល្អ១០០% ប្រើហើយមិនប្រេះស្រាំ មិនខ្មៅព្រោះវត្ថុសុទ្ធ ល្អពិតៗមែន ។

សូមអញ្ជើញមកសិប្បកម្ម" វិចិត្រអង្គរ" យើងខ្ញុំដែលមានលេខទូរស័ព្ទ....... ។

### ដំណឹងថ្មី !

ហាងលក់ផ្កា "សម្រស់បុប្ផា" មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ឯកឧត្តមលោកជំទាវ លោក លោកស្រីថា ហាងយើងខ្ញុំមានលក់ផ្កាស្រស់គ្រប់ប្រភេទ ចម្រុះពណ៌ ថែមទាំងមានការរៀបចំជូនសម្រាប់ពិធីផ្សេងៗ គួរឱ្យចាប់ចិត្តក្រៃលែង ។ ហាងយើងខ្ញុំ មានទីតាំងនៅខាងត្បូងផ្សារធំថ្មី ។ យើងខ្ញុំនឹងមានលក់បញ្ចុះតម្លៃជូនយ៉ាងសមរម្យ ។

សូមអញ្ជើញមកហាងយើងខ្ញុំ ពិតជាមិនខុសបំណងឡើយ ។

សួស្តីហាងលក់ផ្កា "សម្រស់បុប្ផា " ។

## សំណួរ

១. តើសេចក្តីជូនដំណឹងខាងលើចាត់ទុកជាការឃោសនាបានដែរ ឬទេ?ហេតុអ្វី?

២. តើគេប្រើសិល្បវិធីអ្វីខ្លះក្នុងការឃោសនា ដើម្បីទាក់ទាញអតិថិជន ?



# ដំណឹងពិសេស

សុខាចាប់អារម្មណ៍នឹងព័ត៌មានពាណិជ្ជកម្មមួយ ។ ចូរអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ ។



ហាងលក់ហូលផាមួង " នារីអង្គរ " សូមជម្រាបឯកឧត្តម លោកជំទាវ លោកលោកស្រី អ្នកនាងកញ្ញាថា ហាង " នារីអង្គរ " យើងខ្ញុំ មានលក់សាច់សំពត់សូត្រសុទ្ធរបស់ខ្មែរយើង ដែលមានគុណភាពល្អគ្មានពីរ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ផ្ទៃសំពត់មានគោមប្លែកៗ ទាន់សម័យនិយម ផលិតដោយសិប្បករខ្មែរជំនាញៗ មានគ្រប់ពណ៌ ល្អប្រណីត ត្រូវនឹងមនុស្សគ្រប់វ័យ ទាំងបុរស ទាំងស្ត្រី ព្រមទាំងមានតម្លៃថោកសមរម្យ ។ អតិថិជនតែងមានការគាំទ្រ និងកោតសរសើរគ្រប់ៗគ្នា ។

សូមអញ្ជើញមកកាន់ហាង " នារីអង្គរ " តាមអាសយដ្ឋាន សង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីនេះ ហាងយើងខ្ញុំនឹងចុះតម្លៃជូន១០% ។

សួស្តី! ហាងលក់ហូលផាមួង " នារីអង្គរ " ។

## សំណួរ

១. តើសុខាអានព័ត៌មានអ្វី ?

២. តើគេឃោសនាលក់អ្វី ?

៣. តើហាងនោះមានទីតាំងនៅឯណា ?

៤. តើគេបង្ហាញគុណភាពដូចម្តេចខ្លះ ?

## លំហាត់

ក. ចូរបង្ហាញប្រធានបទរបស់អត្ថបទ ដោយគូសសញ្ញា✓ ក្នុងប្រអប់នៅមុខចម្លើយត្រឹមត្រូវមួយ ។

☐ ១. ការឃោសនាលក់ហូលផាមួង

☐ ២. ការផ្សព្វផ្សាយអំពីផលិតផលខ្មែរ

☐ ៣. ការបង្ហាញអំពីសូត្ររបស់ខ្មែរ ។

ខ. ចូរបង្ហាញទស្សនៈរបស់អ្នកសរសេរក្នុងសេចក្ដីជូនដំណឹង ដោយជ្រើសរើសចម្លើយសមស្របមួយ ។

☐ ១. យើងនឹងចុះតម្លៃជូន នៅឱកាសបុណ្យចូលឆ្នាំថ្មី ។

☐ ២. យើងខ្ញុំមានសាច់សំពត់សូត្រសុទ្ធរបស់ខ្មែរ ដែលមានគុណភាពល្អគ្មានពីរ ។

☐ ៣. យើងជឿជាក់ថាលោក លោកស្រីប្រាកដជាពេញចិត្ត ។

គ. តើអ្វីខ្លះជាការពិត ? អ្វីខ្លះជាទស្សនៈ ឬមតិរបស់អ្នកសរសេរក្នុងអត្ថបទខាងលើ ?

ចូរសរសេរអក្សរ (ព) ពីមុខការពិត និងសរសេរអក្សរ (ទ) ពីមុខទស្សនៈ ។

១. ហាង "នារីអង្គរ" មានលក់ហូលផាមួង ។

២. សាច់សំពត់ទាំងនេះ មានគ្រប់ពណ៌និងមានគោមប្លែកៗ ។

៣. សាច់សំពត់មានគុណភាពល្អគ្មានពីរ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤. សាច់សំពត់ល្អប្រណីត ផលិតដោយសិប្បករខ្មែរជំនាញ ។

ឃ. ហេតុអ្វីបានជាអ្នកសរសេរ បញ្ចេញទស្សនៈ អួតសរសើរផលិតផលរបស់ខ្លួន ? ចូរជ្រើសរើសចម្លើយត្រឹមត្រូវមួយ ។

☐ ១. ដើម្បីលក់ផលិតផលដាច់បានច្រើន ។

☐ ២. ដើម្បីឱ្យគេកោតសរសើរ ។

☐ ៣. ដើម្បីឱ្យគេចូលចិត្ត ។

# ១ បទបង្ហាញអំពីផលិតផលចម្លាក់ថ្មកែវ

ចូរមើលរូបភាព រួចស្ដាប់បទបង្ហាញ និងឆ្លើយសំណួរ ។







## សំណួរ

១. តើប្រជាជនមួយចំនួននៅខេត្តពោធិ៍សាត់ មានស្នាដៃខាងផ្នែកអ្វី ?

២. តើចម្លាក់អំពីថ្មកែវមានការលំបាក ឬងាយជាងចម្លាក់អំពីឈើ ?

៣. ហេតុអ្វីបានជាប្រជាជនមួយចំនួន នៅខេត្តពោធិ៍សាត់ចាប់យកអាជីពចម្លាក់ថ្មកែវ ?

៤. តើអ្នកយល់ឃើញថា តម្លៃថ្មកែវនៅខេត្តពោធិ៍សាត់ និងនៅទីកន្លែងផ្សេងទៀតយ៉ាងណាដែរ ? ព្រោះអ្វី ?

## ប្រធាននិងកិរិយាបង្គោល

នៅក្នុងល្បះនីមួយៗ តែងតែមានប្រធាន និងកិរិយាបង្គោល ។

ចូរអានឧទាហរណ៍ខាងក្រោមនេះ ។ តើពាក្យណាខ្លះជាប្រធាន ? ពាក្យណាខ្លះជាកិរិយាបង្គោល ?

១. គេផ្សព្វផ្សាយពីគុណភាពល្អនៃទូរស័ព្ទដៃ ។

២. ខ្ញុំសរសេរប័ណ្ណឃោសនា ។

៣. យើងស្ដាប់ការឃោសនាតាមវិទ្យុ ។

៤. ពួកគេសរសើរថា ផ្ដិលប្រាក់នេះស្អាតល្អ ។

៥. បងខ្ញុំធ្វើបញ្ជីរាយមុខទំនិញ ។

៦. ប្រជាជនខ្មែរភាគច្រើន ចូលចិត្តទិញផលិតផលក្នុងស្រុក ។

៧. សុភីរៀនត្បាញហូលផាមួង ។

៨. ពូចាន់លក់ផលិតផលផ្ទះបាយ ។

ក. ប្រធាន

ពាក្យ “ គេ ខ្ញុំ យើង ពួកគេ បងខ្ញុំ ប្រជាជនខ្មែរភាគច្រើន សុភី ពូចាន់” សម្គាល់អ្នកធ្វើអំពើ ។ ពាក្យទាំងនេះ ជាប្រធាននៅក្នុងល្បះ ។ ប្រធាន អាចជានាម កន្សោមនាម ឬសព្វនាម នៅខាងឆ្វេងកិរិយា ។

ប្រធាន ជាពាក្យសម្គាល់អ្នកធ្វើអំពើ ។

ខ. កិរិយាបង្គោល

ពាក្យ “ ផ្សព្វផ្សាយ សរសេរ ស្ដាប់ សរសើរ ធ្វើ ទិញ ត្បាញ លក់ ” នៅក្នុងឧទាហរណ៍ខាងលើប្រាប់អំពើ ឬសកម្មភាព ។ ពាក្យទាំងនេះជាកិរិយាបង្គោល ។ រីឯពាក្យ “ ចូលចិត្តរៀន” ជាជំនួយកិរិយា ។ កិរិយាបង្គោល អាចនៅជាប់ប្រធាន ឬនៅខាងឆ្វេង ឬនៅខាងស្ដាំជំនួយកិរិយា ។

កិរិយាបង្គោល គឺជាពាក្យសម្គាល់ ឬសម្ដែងអំពើរបស់ប្រធាន ។

កំណត់សម្គាល់ ៖ កិរិយាបង្គោល ឬកិរិយាស្នូល គឺជាកិរិយាដែលមានតួនាទីសំខាន់បំផុតនៅក្នុងល្បះ ។

## លំហាត់

ចូរអានឧទាហរណ៍ខាងក្រោម រួចស្រង់ពាក្យដែលជាប្រធាន និងជាកិរិយាបង្គោលដាក់ចូលក្នុងតារាងខាងក្រោម ។

១. ពូសុខចូលចិត្តឆ្លាក់រូបព្រះពុទ្ធ ។

២. គេលក់សម្លៀកបំពាក់សម្រាប់ស្ត្រី ។

៣. ក្រុមហ៊ុននេះចែកចាយផលិតផលថ្មី ។

៤. ពួកគេដុតកម្ទេចចោលផលិតផលក្លែងក្លាយ ។

៥. ក្រុមហ៊ុននេះលក់ផលិតផលដាច់ជាងគេ ។

| ប្រធាន | កិរិយាបង្គោល |
|---|---|
| | |

# បទបង្ហាញអំពីផលិតផលត្បូងខ្មែរ

ចូរមើលរូបភាព រួចអានបទបង្ហាញខាងក្រោមនេះ ។



រមណីយដ្ឋានផ្អោក ស្ថិតនៅក្នុងស្រុកគិរីវង់ ខេត្តតាកែវ ជាតំបន់ទេសចរណ៍ដែលគួរឱ្យចាប់អារម្មណ៍ ដោយសារនៅទីនោះមានទឹកជ្រោះ និងជាពិសេសមានលក់សុទ្ធតែត្បូងរបស់ខ្មែរ ។

ក្រៅពីរបរធ្វើស្រែចម្ការ ប្រជាជនខ្មែរបានជីករុករកត្បូងនៅតំបន់នេះ អស់រយៈពេល៥ ទៅ៦ ឆ្នាំហើយ ឯការច្នៃត្បូងឱ្យចេញពន្លឺចិញ្ចាចចិញ្ចែងនោះ ក៏ជាស្នាដៃដ៏ប៉ិនប្រសប់របស់ខ្មែរយើងដែរ ។ នៅតាមតូបតូចៗដំបូលប្រក់ស្លឹក មានទូកញ្ចក់យ៉ាងស្អាតដាក់តាំងលក់ត្បូងខ្មែរព្រោងព្រាត គ្រប់ម៉ូតចម្រុះពណ៌ ជះពន្លឺផ្លេកៗ មិនចាញ់ត្បូងនាំចូលពីប្រទេសក្រៅឡើយ ឯតម្លៃទៀតសោតក៏ថោកសមរម្យ ។

ភ្ញៀវដែលបានមកកម្សាន្តទីនេះ តែងនិយមគាំទ្រ និងកោតសរសើរ ពីគុណភាពនៃត្បូង និងស្នាដៃច្នៃត្បូងរបស់ប្រជាជនខ្មែរយើងថា ពិតជាល្អមែន ។

បើលោក លោកស្រី ជួយទិញត្បូងខ្មែរនៅទីនេះមានន័យថា លោក លោកស្រីជួយលើកតម្កើងផលិតផលខ្មែរ និងជួយកាត់បន្ថយភាពក្រីក្ររបស់ខ្មែរយើងទៀតផង ។

## សំណួរ

១. តើនៅរមណីយដ្ឋានផ្អោក មានលក់អ្វីខ្លះ ?

២. តើត្បូងទាំងនោះ មានគុណភាពដូចម្ដេច ?

៣. ហេតុអ្វីបានជាត្បូងនៅរមណីយដ្ឋានផ្អោក មានគុណភាពល្អ ?

៤. ហេតុអ្វីបានជាត្បូងនៅទីនោះ លក់ក្នុងតម្លៃថោកសមរម្យ ?

៥. តើអ្នកគួរសម្រេចចិត្តដូចម្ដេច បើត្បូងខ្មែរ និងត្បូងនាំចូលពីបរទេស មានគុណភាពប្រហាក់ប្រហែលគ្នា ?

## លំហាត់

ចូរធ្វើបទបង្ហាញខ្លីមួយអំពីការឃោសនាផលិតផលមួយ ប្រាប់មិត្តភក្តិរបស់អ្នកដោយមើលតាមគំរូខាងលើ ។

## អត្ថបទឃោសនា

ចូរសរសេរអត្ថបទឃោសនាខ្លីមួយអំពីប្រធានបទណាមួយ តាមអ្នកចូលចិត្ត ឬអាចជ្រើសរើសប្រធានបទខាងក្រោម ៖

- ការឃោសនាលក់ផ្លែទុរេនខេត្តកំពត
- ការឃោសនាលក់ផ្លែក្រូចពោធិ៍សាត់ខេត្តបាត់ដំបង
- ការឃោសនាលក់ទឹកឃ្មុំសុទ្ធពីខេត្តមណ្ឌលគិរី
- ការឃោសនាអំពីផលិតផលអ្វីមួយ នៅក្នុងភូមិអ្នក

ដើម្បីសរសេរអត្ថបទឃោសនា ចូរអ្នកបង្ហាញ ៖

១. ចំណងជើងអត្ថបទ

២. គុណភាពរបស់ផលិតផលនោះ

៣. ឈ្មោះហាង ឬភូមិស្រុកដែលមានផលិតផលនោះ

៤. ការទាក់ទាញផ្សេងទៀត ដូចជា (ជូនរង្វាន់ បញ្ចុះតម្លៃ...)

៥. ប្រាប់អាសយដ្ឋាន ឬលេខទូរស័ព្ទសម្រាប់ទាក់ទង ។

មេរៀនទី

# ៩ ពេលវេលាជាមាសប្រាក់



ពេលវេលាចេះតែរំកិលទៅមុខ ឥតឈប់ឈរ ។ កុមារី កុមារា ដែលកំពុងពេញវ័យសិក្សាត្រូវតែស្រវាស្រទេញ ខិតខំរៀនសូត្រទាន់ខ្លួននៅក្មេង ព្រោះពេលវេលាមានតម្លៃជាទីបំផុត ។ ការបណ្តែតបណ្តោយឱ្យពេលវេលាកន្លងហួសទៅ ដោយពុំបានធ្វើអ្វីឱ្យមានប្រយោជន៍សម្រាប់ខ្លួន គឺជាការខ្ជះខ្ជាយបំផុតសម្រាប់មនុស្សម្នាក់ៗ ។ តើកុមារី កុមារានៅក្នុងរូបភាពនេះ កំពុងធ្វើអ្វីខ្លះ ?

# តម្លៃនៃពេលវេលា

ពេលវេលា ចេះតែរំកិលទៅមុខជានិច្ច មិននៅនឹងមួយកន្លែងទេ ។ តើកុមារី កុមារា ត្រូវធ្វើអ្វីខ្លះ ដើម្បីកុំឱ្យពេលវេលាខាតបង់ដោយឥតប្រយោជន៍ ?



## បទពាក្យប្រាំពីរ

ហៃអស់កុមារទាំងអស់គ្នា
ស្វែងរកវិជ្ជាទាន់នៅក្មេង
សង្វាតស្វូត្ររៀនកុំបែកឆ្វេង
ហ៊ឹហាដើរលេងឥតប្រយោជន៍ ។
មិត្តភក្ដិបនភឿនគេចសាលា
ធ្វើឱ្យគ្រួសារឈឺផ្សាខ្លោច
ទ្រព្យធនម៉ែឪក៏ហិនហោច
កេរ្តិ៍ឈ្មោះអសោចដល់ខ្លួនប្រាណ ។
ទម្រាំដឹងខ្លួនហួសពេលស្ដារ
កែច្នៃយ៉ាងណាក៏មិនបាន
មិត្តភក្តិធ្លាប់ស្គាល់ទាំងប៉ុន្មាន
ផៅញាតិសន្ដានគេនិន្ទា ។
មនុស្សក្នុងលោកិយខិតខំណាស់
ប្រឹងប្រែងស្វែងស្វះគ្រប់អង្គា
រៀនរករៀនធ្វើសព្វការងារ
ឱ្យទាន់វេលាជាយុវវ័យ ។
កុំខ្ជះខ្ជាយពេលមិនសោកស្ដាយ
ពេលជួបអន្តរាយទើបភិតភ័យ
ស្ដាយពេលវេលាមានតម្លៃ
លោកទុកវិស័យស្មើមាសប្រាក់ ។

## សំណួរ

១. តើអ្នកត្រូវប្រឹងប្រែងរៀនសូត្រនៅពេលណា ?

២. តើអ្នកគួរខ្ជះខ្ជាយពេលវេលាដែរ ឬទេ ? ព្រោះអ្វី ?

៣. តើអ្នកនឹងទទួលផលអាក្រក់អ្វីខ្លះ ពីការដើរលេងឥតប្រយោជន៍ ?

៤. តើអ្នកខិតខំរៀនសូត្រនឹងទទួលផលអ្វីខ្លះ ?

៥. តើគេចាត់ទុកពេលវេលាស្មើនឹងអ្វី ?

## លំហាត់

ក. ចូរសូត្រកំណាព្យខាងលើឡើងវិញ ។ តើវគ្គនីមួយៗនៃកំណាព្យនិយាយអំពីអ្វី ?

ខ. ចូររកពាក្យសូរដូចនឹងពាក្យ " វ័យ ផ្សា អង្គា " ។

## អត្ថបទកាព្យ

ឃ្លានៃកំណាព្យបទពាក្យប្រាំពីរខាងក្រោម មិនទាន់ត្រូវតាមលំដាប់ទេ ។ ចូរអ្នករៀបឃ្លាទាំងនេះ ឱ្យបានត្រឹមត្រូវតាមវគ្គនីមួយៗ ។

" វគ្គទី ១ "

ម៉ែពុកនឿយហត់ចិញ្ចឹមបុត្រ ឱ្យកូនសិក្សាយកវិជ្ជា
ទឹកចិត្តបរិសុទ្ធនឹងកូនភ្ងា ចំណេះនានាទុកជាស្ពាន ។

" វគ្គទី ២"

យាយតាស្រឡាញ់ថ្នាក់ថ្នមចៅ សម្តីផ្អែមល្ហែមគ្រប់ជំហាន
មិនវាយបំពានលើកាយា ឃើញឆ្គងលោកហៅមកទូន្មាន ។

" វគ្គទី ៣"

ហេតុនេះកូនចៅទាំងប្រុសស្រី ពេលធំដឹងក្តីចូលសាលា
យឹតយោងគ្រួសារឱ្យរុងរឿង ខំរៀនខំធ្វើសព្វកិច្ចការ ។

## ខំប្រឹងទាន់ខ្លួននៅក្មេង

១. តើវ័យណា ដែលអ្នកត្រូវចាប់យកការសិក្សា ?

២. តើចំណេះវិជ្ជាជួយអ្នក ឱ្យរកបានអ្វីខ្លះ ?

៣. តើអ្នកគ្មានចំណេះ ត្រូវរកប្រាក់ដោយវិធីណា ?

៤. តើអ្នកសោកស្ដាយដែរ ឬទេ ពេលដែលអ្នកឱ្យពេលវេលារសាត់ផុតទៅ ? ហេតុអ្វី ?

៥. តើនៅវ័យចំណាស់ អ្នកអាចស្វែងរកចំណេះបានដែរ ឬទេ ? ព្រោះអ្វី ?

## លំហាត់

ក. ចូរគូសសញ្ញា✓ ក្នុងប្រអប់ដែលអ្នកយល់ថា ជាគំនិតសំខាន់របស់កំណាព្យ ។

☐ ១. ត្រូវខំរៀនទាន់ខ្លួននៅក្មេង ។

☐ ២. ត្រូវខំដើរហ៊ឺហាទាន់ខ្លួននៅក្មេង ។

☐ ៣. ត្រូវខំធ្វើការទាន់ខ្លួននៅក្មេង ។

ខ. ចូរស្រង់ពាក្យចួននៅក្នុងវគ្គកំណាព្យខាងក្រោម ៖

ស្ដាយពេលវេលាកន្លងទៅ គ្មានពេលណានៅឈប់ស្ងៀមស្ងប់
អណ្ដែតត្រសែតគ្មានត្រឡប់ រសាត់បញ្ចប់ដោយវាសនា ។

## សញ្ញាចុចពីរ (:)

ចូរសង្កេតមើលឧទាហរណ៍ខាងក្រោម តើសញ្ញាចុចពីរ(:)សម្រាប់ធ្វើអ្វី ?

១. ឪពុកខ្ញុំមានធុរៈចាំបាច់ ទើបគាត់មិនបានមកធ្វើការ ។

២. ចូរកុំប្រកាន់ចិត្ត លោភៈ ទោសៈ ព្រោះវានាំមកនូវសេចក្ដីទុក្ខ ។

៣. រាល់ថ្ងៃសីល ជីដូនខ្ញុំយកគ្រឿងសក្ការៈទៅវត្ត ។

៤. បុរសនេះ មានឋានៈខ្ពង់ខ្ពស់ណាស់ ។

សញ្ញាចុចពីរ (:) ប្រើសម្រាប់ញ៉ាំងព្យញ្ជនៈឱ្យមានសំឡេងតាមបែបបាលីសំស្ក្រឹត ។

## វិធីប្រើ

**ក. ទីកន្លែង**

សញ្ញាចុចពីរ ប្រើនៅខាងស្ដាំព្យញ្ជនៈនៃពាក្យក្លាយពីបាលី និងសំស្ក្រឹត ដើម្បីកត់សូរ [អាក់] និង [ អ៊ាក់] ។

**ខ. សូរ [ អាក់] និង [អ៊ាក់]**

សូរ [ អាក់] ផ្សំនឹងព្យញ្ជនៈពួកអ ។ ឧទាហរណ៍ ៖ សច្ចៈ សុខៈ អន្តរៈ លោកៈ លក្ខណៈ វណ្ណៈ.. ។

សូរ [ អ៊ាក់] ផ្សំនឹងព្យញ្ជនៈពួកអ៊ ។ ឧទាហរណ៍ ៖ ភារៈ ធុរៈ លោភៈ សុច្ឆន្ទៈ... ។

**គ. ការសង្កេត**

ពាក្យក្លាយពីបាលីសំស្ក្រឹតខ្លះ មិនប្រើសញ្ញាចុចពីរទេ លើកលែងតែពាក្យ កាលៈទេសៈ គណៈកម្មការ គណៈប្រតិភូ រយៈពេល... ។

## លំហាត់

ក. ចូររកពាក្យដែលប្រើសញ្ញាចុចពីរឱ្យបានបីពាក្យ ។

ខ. ចូរស្រង់ពាក្យដែលពុំប្រើសញ្ញាចុចពីរនៅក្នុងល្បះខាងក្រោម ៖

១. ទេសចរជាតិ និងអន្តរជាតិទៅទស្សនាប្រាសាទព្រះវិហារ ។

២. វីរកងទ័ព យកចិត្តទុកដាក់ការពារព្រំដែន ។

៣. ប្រជាជន យុវជន យុវនារី ត្រូវតស៊ូប្រយុទ្ធប្រឆាំងនឹងខ្មាំងឈ្លានពានទឹកដី ។

៤. នៅមុនថ្ងៃចូលឆ្នាំ ប្រជាជននាំគ្នារៀបចំគ្រឿងសក្ការបូជាទទួលទេវតាថ្មី ។

# រឿង កូនភ្លោះ



ប៉ែននិងពិន ជាកូនភ្លោះ ។ ក្រោយពីឪពុកចែកឋានទៅ ប៉ែននិងពិនរស់នៅជាមួយម្ដាយ ដែលប្រកបមុខរបរលក់នំអាកោ ។

ឆ្នាំនេះ ពួកគេបានរៀនដល់ថ្នាក់ទី៥ ហើយ ។ កុមារទាំងពីរ មានរូបសម្បត្តិដូចគ្នាបេះបិទ តែមានចរិតខុសគ្នាស្រឡះ ។ ប៉ែន យកចិត្តទុកដាក់ក្រេបជញ្ជក់ចំណេះវិជ្ជាទាំងឡាយដែលគ្រូបានបង្ហាត់ បង្រៀន ដោយឥតនឿយណាយ ។ នៅដំណាច់ឆ្នាំ ប៉ែនបានទទួលប័ណ្ណសរសើរ និងរង្វាន់ជាច្រើនធ្វើឱ្យមីងសានជាម្ដាយសប្បាយចិត្តណាស់ ។

ឯពិនវិញពុំចូលចិត្តការរៀនសូត្រទេ ។ វាឆ្លៀតលេងប្រលែងគ្នា ពេលកំពុងរៀន ។ ជួនកាល ពិនបបួលក្មេងៗលេងគប់វង់ដាក់លុយ ឬដាក់កៅស៊ូ ។ ទោះបីម្ដាយ ឬអ្នកគ្រូជួយអប់រំយ៉ាងណា ក៏ពិនមិនធ្វើតាមដែរ ។ ឯប៉ែនវិញ មិនដែលខ្ជះខ្ជាយពេលវេលាសម្រាប់ការងារឥតប្រយោជន៍នោះទេ ។ រាល់ថ្ងៃ នៅពេលជិតភ្លឺ ម្ដាយក្រោកចំហុយនំ ប៉ែនក្រោករៀនសូត្របណ្ដើរ ជួយថែភ្លើងបណ្ដើរ ។ ថ្ងៃទំនេរ ប៉ែនតែងដើរលក់កាសែតទស្សនាវដ្ដី ដើម្បីរកប្រាក់ចំណេញ សន្សំទុកទិញសម្លៀកបំពាក់ ឬសម្ភារៈសិក្សា ។



ថ្ងៃខែចេះតែវិកិលទៅមុខ ឥតឈប់ឈរ ។ ពេលនេះ ប៉ែនបានប្រឡងជាប់ចូលរៀននៅឧត្ដមសិក្សា ។ ប៉ែននៅតែប្រឹងប្រែងរៀនសូត្រ រហូតក្លាយទៅជាវិស្វករសំណង់ម្នាក់ដ៏ចំណាន ។ ប៉ែន មិនបញ្ឈប់ការសិក្សាស្រាវជ្រាវទេ ។ គាត់ខិតខំដកស្រង់បទពិសោធផ្នែក សំណង់ទំនើបៗ បន្ថែមទៀត ។ ប៉ែនពូកែគូរប្លង់ និងធ្វើសំណង់ប្រកបដោយបច្ចេកទេសទៀតផង ។ គាត់បានធ្វើឱ្យគ្រួសារ រួចផុតពីភាពក្រីក្រតោកយ៉ាក ។ ដោយឡែក ពិនបានដើរផ្លូវខុស ធ្វើឱ្យខាតបង់ពេលវេលារៀនសូត្រ ។ ថ្ងៃមួយ មានឈ្មួញម្នាក់ច្រឡំពិនថាប៉ែន នៅពេលគេពឹងពិនឱ្យជួយគូរប្លង់ និងប៉ាន់ស្មានតម្លៃសាងសង់សាលតាំងពិព័រណ៍មួយ ។ ពិនពុំ អាចឆ្លើយតបនឹងសំណូមពររបស់ឈ្មួញបាន ក៏មានការអៀនខ្មាសយ៉ាងខ្លាំង ។ ចាប់តាំងពីពេលនោះមក ពិនតាំងចិត្តកែខ្លួនឡើងវិញ ។ ដោយសារមានប៉ែនជាអ្នកពន្យល់ណែនាំជាប្រចាំ ពិនបានក្លាយជាកម្មកររោងចក្រ ។ ក្រោយមក ប៉ែនតែងតាំងពិនជាប្រធានការដ្ឋានសំណង់ ។ នៅពេលនេះ ទើបពិនយល់ច្បាស់ថា ពេលវេលាមានតម្លៃណាស់ បើវាកន្លងហួសទៅមិនអាចនឹងវិលត្រឡប់មកវិញបានទេ ។

## សំណួរ

១. តើម្តាយប៉ែនមានអារម្មណ៍យ៉ាងណា នៅពេលដែលគាត់ឃើញប៉ែន ខំប្រឹងរៀននិងជួយធ្វើការគាត់ ?

២. តើគាត់មានអារម្មណ៍យ៉ាងណា នៅពេលដែលពិនមិនស្តាប់តាមការណែនាំរបស់គាត់ និងគ្រូ?

៣. តើប៉ែនទទួលផលដូចម្តេច នៅពេលអនាគត ? ចុះពិនវិញទទួលផលដូចម្តេចដែរ ?

៤. តើគ្រួសារប៉ែនមានជីវភាពដូចម្តេច ក្រោយពេលប៉ែនក្លាយជាវិស្វករ ?

៥. តើពិនមានអារម្មណ៍ដូចម្តេច នៅពេលគេច្រឡំគាត់ថាជាប៉ែន ?

៦. តើប៉ែនជួយពិនដែរ ឬទេ ? ព្រោះអ្វី ?

## ការបំពេញឃ្លានៃកំណាព្យបទពាក្យប្រាំពីរ

អ្នកបានសិក្សារួចហើយពីរង្វាស់កាព្យបទពាក្យប្រាំពីរ ចំណាប់ចួនក្នុងវគ្គ និងចំណាប់ចួនឆ្លងវគ្គ ។ ចូរអ្នកមើលគំនូសតាងខាងក្រោម រួចជ្រើសរើសពាក្យក្នុងប្រអប់មកបំពេញក្នុងអត្ថបទកាព្យខាងក្រោម ៖

### បទពាក្យប្រាំពីរ



| គ្នេរ | ប្រឹង | ទំនេរ | ប្រាណ | រិះរេ | ស្ងៀម | ទឹមទាម | ជ្រៃ |
|---|---|---|---|---|---|---|---|

មនុស្សក្នុងគ្រួសារគ្រប់ៗ ...
រៀនសូត្រគ្រប់គ្នាកុំ ...
បើចង់ស្រណុកត្រូវខំ ...
ប្រឹងប្រែងធ្វើការខំឃ្មាន់ ...

គ្រប់វ័យប៉ុន្មានកុំនៅ ...
គិតរួចធ្វើភ្លាមកុំ ... ។
វាសនាកុំពឹងត្រូវ ...
រសៀលជ្រៀង ... អស់ពេលប្រឹង ។

## ពេលវេលា

ពេលវេលាមានតម្លៃបំផុតសម្រាប់មនុស្សគ្រប់ៗគ្នា ។ តើយើងត្រូវធ្វើដូចម្តេចដើម្បីកុំឱ្យពេលវេលា កន្លងហួសទៅដោយឥតប្រយោជន៍ ?

ចូរអានអត្ថបទអំណានខាងក្រោម ។



តុកតាក់! តុកតាក់ ទ្រនិចនាឡិកា ចេះតែដើរទៅមុខជានិច្ចឥតឈប់ឈរ ពីមួយនាទីទៅមួយនាទី ពីមួយម៉ោងទៅមួយម៉ោង ពីមួយថ្ងៃទៅមួយថ្ងៃ ។ រីឯសន្លឹកប្រតិទិនតែងបើកមួយសន្លឹកម្តងៗ រហូតដល់អស់បីរយហុកសិបប្រាំថ្ងៃ ពុំមានវិលត្រឡប់ថយក្រោយឡើយ ។ ដើម្បីកុំឱ្យពេលវេលាកន្លងផុតទៅដោយឥតប្រយោជន៍ មនុស្សម្នាក់ៗត្រូវបំពេញកាតព្វកិច្ចឱ្យសមស្របតាមវ័យនីមួយៗ ។ បឋមវ័យ ជាវ័យដែលត្រូវស្រវា

ស្រទេញស្វែងរកចំណេះវិជ្ជា ដើម្បីកសាងអនាគត ។ ប៉ុន្តែមនុស្សគ្រប់រូប ត្រូវតែយល់ឱ្យច្បាស់ថាវ័យនេះ ក៏ជាវ័យដែលផុយស្រួយ ប្រសិនបើយើងពុំមានគោលជំហររឹងមាំ ។ ក្នុងវ័យនេះ អ្នកមិនត្រូវប្រព្រឹត្តអំពើអបាយមុខ មានការសេពគ្រឿងញៀន លេងល្បែងស៊ីសង ឬដើរលេងគេចសាលាឡើយ ពីព្រោះវានាំឱ្យអ្នកខាតបង់ពេលវេលា ប្រាក់កាសព្រមទាំងអាប់ឱនកេរ្តិ៍ឈ្មោះទៀតផង ។

បឋមវ័យ ជាឈ្នាន់សម្រាប់កសាងមជ្ឈិមវ័យឱ្យរីកចម្រើនលូតលាស់ ។ មជ្ឈិមវ័យជាវ័យដែលត្រូវកសាងគ្រួសារ រកទ្រព្យសម្បត្តិទុកឱ្យកូនចៅ និងទុកសម្រាប់ខ្លួនពេលឈានដល់បច្ឆិមវ័យ ។ បច្ឆិមវ័យ ឬវ័យចាស់ជរា ជាវ័យដែលត្រូវរកធម៌អាថ៌កសាងកុសលទៅកាន់បរលោក ។

ដូច្នេះដើម្បីកសាងខ្លួន គ្រួសារ និងប្រទេសជាតិឱ្យបានរុងរឿង យុវជនត្រូវបំពេញភារកិច្ចនៅក្នុងបឋមវ័យ ឱ្យបានសម្រេចកុំបីមានការធ្វេសប្រហែសឡើយ ។

## សំណួរ

១. តើគេចែកវ័យរបស់មនុស្សជាប៉ុន្មាន ? គឺវ័យអ្វីខ្លះ ?

២. តើក្នុងវ័យនីមួយៗ យើងត្រូវធ្វើអ្វីខ្លះ ?

៣. ហេតុអ្វីជាបានជាគេថា បឋមវ័យជាវ័យដែលផុយស្រួយ ?

៤. ហេតុអ្វីបានជា យើងត្រូវប្រឹងប្រែងរៀនសូត្រនៅបឋមវ័យ ?

៥. តើយើងត្រូវធ្វើអ្វីខ្លះ នៅមជ្ឈិមវ័យ ?

៦. តើយើងត្រូវធ្វើអ្វីខ្លះ នៅបច្ឆិមវ័យ ឬវ័យចាស់?

# បទផ្សេងៗនៃកំណាព្យខ្មែរ

អ្នកគ្រូ បានបង្រៀនសិស្សអំពីកំណាព្យ ។ សុខានិងវីរៈ បានសួរអ្នកគ្រូអំពីបទកំណាព្យដែលខ្មែរមាន ។ ចូរអានការសន្ទនារបស់ពួកគេ ។

**អ្នកគ្រូ :** ថ្ងៃនេះ យើងរៀនកំណាព្យបទពាក្យប្រាំពីរ ។ តើកូនៗដឹងទេថា កំណាព្យខ្មែរយើងមានបទអ្វីខ្លះ ?

**សុខា :** ចាស៎អ្នកគ្រូ! កំណាព្យខ្មែរមាន បទកាកគតិនិងបទព្រហ្មគីតិ ។

**អ្នកគ្រូ :** តើកូនណាដឹងថា មានបទអ្វីទៀតទេ ?

**វីរៈ :** បាទអ្នកគ្រូ! មានបទពាក្យប្រាំពីរ និងបទពំនោល ។

**អ្នកគ្រូ :** ល្អណាស់! ប៉ុន្តែក្រៅពីបទដែលកូនបានរៀបរាប់នេះ នៅមានបទជាច្រើនទៀតដូចជា បទបន្ទោលកាក បទពាក្យប្រាំបី បទពាក្យប្រាំបួន បទភុជង្គលីលា... ។

**សុខា :** តើបទទាំងនេះ ខុសគ្នាត្រង់ណាអ្នកគ្រូ ?

**អ្នកគ្រូ :** បទទាំងអស់មានចំនួនព្យាង្គ និងឃ្លាមិនដូចគ្នាទេ ឯការចាប់ចុងចួនក៏មិនដូចគ្នាដែរ ។ បទខ្លះក្នុង១វគ្គមាន ៤ឃ្លា បទខ្លះមាន ៣ឃ្លា ហើយខ្លះទៀតមាន ៧ឃ្លា ។

**សុខា និងវីរៈ :** អរគុណអ្នកគ្រូ! ខ្ញុំយល់បានមួយកម្រិតហើយ ។

## លំហាត់

ចូរអ្នកប្រាប់ចំនួនឃ្លានៅក្នុងវគ្គនីមួយៗនៃបទពាក្យប្រាំពីរ ចំនួនព្យាង្គនៅក្នុងឃ្លានីមួយៗ និងបង្ហាញចុងចួនតាមគំនូសតាងខាងក្រោម ។

# បទពាក្យប្រាំពីរ




## ការតែងកំណាព្យបទពាក្យប្រាំពីរ

ចូរអ្នកសង្កេតមើលគំនូសតាងកំណាព្យបទពាក្យប្រាំពីរខាងលើ ។ ក្នុង១វគ្គមាន ៤ ឃ្លា ហើយឃ្លានីមួយៗមាន ៧ព្យាង្គ ។ ព្យាង្គដែលចួនគ្នាមានគំនូសភ្ជាប់ ជាឧទាហរណ៍ស្រាប់ ។

ចូរអ្នកតែងកំណាព្យបទពាក្យប្រាំពីរឱ្យបានចំនួន ២វគ្គ ដោយជ្រើសរើសប្រធានបទដែលអ្នកពេញចិត្ត ។

......................

........................................ ..........................................

........................................ .......................................... ។

........................................ ..........................................

........................................ .......................................... ។

មេរៀនទី

# ១០ ប្រយោជន៍នៃវិទ្យាសាស្ត្រ



ថ្នាំពេទ្យ



អង់តែនទូរទស្សន៍



យន្តហោះ



សំណង់អាគារ



រថយន្តក្រុង



ស្ពាន



កប៉ាល់

ដោយវិទ្យាសាស្ត្ររីកចម្រើន មនុស្សបានបង្កើតឧបករណ៍ ឬសម្ភារៈប្រើប្រាស់ទំនើបៗជាច្រើន ដើម្បីជួយសម្រួលដល់ជីវភាពរស់នៅ ។ ឧបករណ៍ទាំងអស់នោះ ធ្វើឱ្យការរស់នៅកាន់តែល្អប្រសើរជាបណ្ដើរៗ ។ តើអ្នកស្គាល់ឧបករណ៍អ្វីខ្លះ ក្នុងរូបភាពខាងលើ ? តើឧបករណ៍អ្វីខ្លះដែលជាផលិតផលនៃវិទ្យាសាស្ត្រ សម្រាប់ទ្រទ្រង់សុខភាពមនុស្ស ?

# ការណែនាំច្រើនជំហាន

ពេលអ្នកចង់រកកន្លែងណាមួយ ចង់ឆ្លងផ្លូវដែលមានមនុស្សច្រើន ប្រើថ្នាំពេទ្យ ធ្វើតែស ឬលេងល្បែងកម្សាន្ត អ្នកចាំបាច់ត្រូវធ្វើតាមការណែនាំ ទើបអ្នកអាចសម្រេចបានផលល្អ ។ ការណែនាំខ្លះ គេសរសេរឱ្យយើងអាន ការណែនាំខ្លះគេនិយាយឱ្យយើងស្តាប់ ។

ចូរអានការណែនាំអំពី "ការប្រើថ្នាំពេទ្យ" ខាងក្រោម ៖

១. ដំបូង ហែកកញ្ចប់ថ្នាំ ហើយចាក់ថ្នាំនោះចូលទៅក្នុងកែវ ។

២. បន្ទាប់មក ចាក់ទឹកឆ្អិនចូលក្នុងកែវចំនួនកន្លះកែវ ។

៣. បន្ទាប់មកទៀត យកកូនស្លាបព្រាកូរឱ្យសព្វ ។

៤. ទីបញ្ចប់ ផឹកថ្នាំនោះភ្លាមកុំទុកឱ្យយូរ ។

## សំណួរ

តើការណែនាំខាងលើនេះ មានប៉ុន្មានជំហាន ? តើជំហានទី១ គេឱ្យធ្វើអ្វី ? ជំហានទី ២ ទី ៣ ទី ៤ គេឱ្យធ្វើអ្វី ?

តើគេប្រើពាក្យអ្វី សម្រាប់សម្គាល់ជំហានទី ១ ទី ២ ទី ៣ និងជំហានចុងក្រោយ ?

ក្នុងការណែនាំភាគច្រើន គេប្រើពាក្យ "ដំបូង បន្ទាប់មក បន្ទាប់មកទៀត ... និង ទីបញ្ចប់" ដើម្បីបញ្ជាក់លំដាប់លំដោយ នៃជំហាននីមួយៗ ។

> ការណែនាំច្រើនជំហាន គឺការរៀបរាប់អំពីរបៀបធ្វើ ឬប្រើអ្វីមួយតាមលំដាប់លំដោយនៃជំហាននីមួយៗតាំងពីដើមដល់ចប់ ។

## លំហាត់

ចូរអ្នកអានការណែនាំខាងក្រោម តើការណែនាំនេះមានប៉ុន្មានជំហាន រួចធ្វើតាមជំហាននីមួយៗរហូតដល់ចប់ ។

ជំហានទី ១ ៖ កន្ត្រាក់ជើងឱ្យល្មម ។

ជំហានទី ២ ៖ លើកដៃទាំងពីរត្រង់ទៅមុខ ។

ជំហានទី ៣ ៖ លើកដៃទាំងពីរត្រង់ទៅលើ ។

ជំហានទី ៤ ៖ សន្ធឹងដៃទាំងពីរ ។

ជំហានទី ៥ ៖ ទម្លាក់ដៃទាំងពីរចុះក្រោម ។

ជំហានទី ៦ ៖ បង្រួមជើងមកវិញ ។



## របៀបប្រើទូរទស្សន៍



ថ្ងៃនេះ ពេលត្រឡប់មកដល់ផ្ទះ សុគន្ធបានឃើញប្រអប់ធំមួយនៅលើទូសម្អាងក្នុងផ្ទះ ។ នាងដើរចូលទៅជិតទើបដឹងថា ជាប្រអប់ទូរទស្សន៍ ។ សុគន្ធសប្បាយចិត្តខ្លាំងណាស់ ។ នាងបើកប្រអប់ថ្មមៗ ព្រមទាំងសួរម្ដាយ ៖

- ម៉ែ ! ម៉ែទើបនឹងទិញទូរទស្សន៍មែនទេ ?
- មែនហើយកូន! ព្រោះម៉ែចង់ឱ្យកូនបានទទួលព័ត៌មាន និងបានបន្ធូរអារម្មណ៍ខ្លះ ។

- អរគុណម៉ែ! តើគេប្រើវាយ៉ាងម៉េចទៅម៉ែ ? កូនចង់មើលណាស់ ។
- ម៉ែក៏មិនទាន់ដឹងថា ប្រើយ៉ាងម៉េចដែរ តែអ្នកលក់ប្រាប់ថាឱ្យយើងមើល ការណែនាំអំពីរបៀបប្រើ នៅក្នុងសៀវភៅនេះ ។

សុគន្ធបើកសៀវភៅអានមួយសន្ទុះក៏យល់ ។ គេនិយាយទៅកាន់ម្ដាយ ៖

- ម៉ែ! កូនចេះប្រើវាហើយ!
- តើប្រើយ៉ាងម៉េចទៅកូន ?
- ម៉ែចាំស្ដាប់ណា៎ កូនអានជូនម៉ែស្ដាប់ ៖

១. ដំបូង យកឆ្នាប់ចរន្តឈ្មោលទៅដោតនឹងឆ្នាប់ចរន្តញីនៅជញ្ជាំង ។

២. បន្ទាប់មក ចុចប៊ូតុងនៅលើប្រដាប់បញ្ជា ដើម្បីបើកទូរទស្សន៍ ។

៣. បន្ទាប់មកទៀត ចុចលេខដើម្បីរកប៉ុស្តិ៍ដែលយើងចង់មើល ។

៤. ជាចុងក្រោយ បើកនិងតម្រូវសំឡេងឱ្យល្មមតាមយើងចូលចិត្តស្ដាប់ ។

- អូ!ម៉ែយល់ហើយ! គិតទៅមិនពិបាកសោះ ។ ឥឡូវ កូនសាកល្បងបើកវាទៅ ម៉ែរៀបចំបាយ ។ យើងហូបបាយបណ្ដើរ មើលទូរទស្សន៍បណ្ដើរ ។

## សំណួរ

១. តើម្ដាយសុគន្ធទិញអ្វី ?

២. ហេតុអ្វីបានជាគាត់ទិញទូរទស្សន៍ ?

៣. តើសុគន្ធធ្វើដូចម្ដេច ដើម្បីប្រើទូរទស្សន៍បាន ?

៤. តើការណែនាំនៅក្នុងអត្ថបទអំណាននេះ និយាយអំពីអ្វី ?

៥. តើការណែនាំនេះ មានប៉ុន្មានជំហាន ?

៦. តើជំហានទី ១ គេឱ្យធ្វើអ្វី ? ជំហានទី ២ ទី ៣ ...?

# រឿង ចៅប្រាក់ភ្នែកបី




## សំណួរ

១. តើចៅប្រាក់ពិតជាមានភ្នែកបីមែន ឬទេ ? តើភ្នែកទី ៣ នោះគឺអ្វី ?

២. មុននឹងចេញដំណើរ តើឪពុកបានប្រគល់អ្វីដល់ចៅប្រាក់ ?

៣. តើនៅពេលធ្វើដំណើរ ពួកគេមានរឿងអ្វី ?

៤. តើអ្នកណា ជាអ្នកជួយពួកគាត់ឱ្យរួចផុតពីគ្រោះថ្នាក់ ?

៥. តើចៅប្រាក់អាចជួយប្អូន និងឪពុកគេបានដោយសារអ្វី ?

៦. តើកែវយឺតមានប្រយោជន៍អ្វីខ្លះ ? តើទូរស័ព្ទសម្រាប់ធ្វើអ្វី ?

៧. តើរឿងនេះ កើតនៅកន្លែងណា ? នៅពេលណា ?

## លំហាត់

ក. ចូរបង្ហាញចរិតលក្ខណៈរបស់តួអង្គឪពុក ។

ខ. ចូរប្រៀបធៀបតួអង្គចៅប្រាក់ និងព្រីង ។

គ. ចូរស្រង់ព្រឹត្តិការណ៍សំខាន់ៗ នៅក្នុងដំណើររឿងខាងលើ ។

## សញ្ញាឧទាន (!)

ចូរអានឧទាហរណ៍ខាងក្រោម ។ តើសញ្ញាឧទានសម្រាប់ធ្វើអ្វី ?

១. យី! លំបាកណាស់តើ!

២. យី! ធ្វើអ្វីដូច្នេះ!

៣. យុយ! ដំរីធំណាស់!

៤. អែយ៉ា! ទូរស័ព្ទនេះល្អណាស់!

៥. យើ! ធ្វើខុសហើយនៅតែមិនដឹងខ្លួន ។

នៅក្នុងឧទាហរណ៍ទី ១ ឧទានសញ្ញា ជាឧទានសម្រាប់សម្គាល់សេចក្ដីត្អូញត្អែរ ។

ឧទាហរណ៍ទី ២ សម្គាល់ពាក្យស្ដីបន្ទោស ។

ឧទាហរណ៍ទី ៣ សម្គាល់ការភ័យស្លន់ ។

ឧទាហរណ៍ទី ៤ សម្គាល់ការស្ងើចសរសើរ ។

ឧទាហរណ៍ទី ៥ សម្គាល់កំហឹង ។

សញ្ញាឧទាន សម្រាប់ដាក់ក្រោយពាក្យ ឃ្លា ឬល្បះ ដើម្បីសម្គាល់ពាក្យឧទាន ដែលសម្ដែងអំពីការភ័យស្លន់ ត្អូញ ការបន្ទោស ការស្ងើចសរសើរ និងកំហឹង ។

## លំហាត់

ចូរតែងល្បះ ដោយប្រើសញ្ញាឧទានឱ្យបាន៥ ល្បះ ។

# ប្រដាប់ជំនួយត្រចៀក



មានកុមារីម្នាក់ឈ្មោះអង់ជេឡា ។ នាងធ្ងន់ត្រចៀកបន្តិច ។ នាងបាននិយាយរឿងទាក់ទងនឹងប្រដាប់ជំនួយត្រចៀករបស់នាង ៖

ថ្ងៃមួយ ឪពុកម្ដាយខ្ញុំបាននាំខ្ញុំទៅមន្ទីរពេទ្យ ។ ដំបូងគ្រូពេទ្យ " អាដាំ " បានយកប្រដាប់ម្យ៉ាងមានអំពូលភ្លឺ ឆ្លុះចូលក្នុងរន្ធត្រចៀកខ្ញុំ រួចថា គ្មានអាចម៍ត្រចៀក គ្មានគ្រាប់ក្រួស ថ្មអ្វីទេ ។ លោកសួរឪពុកម្ដាយខ្ញុំថា តើខ្ញុំធ្លាប់ឈឺធ្ងន់ដែរ ឬទេ ។

បន្ទាប់មក លោកសរសេរក្រដាសមួយ ហើយហុចឱ្យឪពុកម្ដាយខ្ញុំ ។ លោកនិយាយដោយសំឡេងតិចៗ ប្រាប់ឪពុកម្ដាយខ្ញុំ ឱ្យនាំខ្ញុំទៅជួបនឹងវេជ្ជបណ្ឌិតម្នាក់ទៀតឈ្មោះលោកម៉ាតាំង ។ លោកម៉ាតាំងដាក់ខ្ញុំក្នុងបន្ទប់កញ្ចក់មួយ រួចយកប្រដាប់ជំនួយត្រចៀកដាក់ក្នុងត្រចៀកខ្ញុំ ។ គាត់ឱ្យខ្ញុំលើកដៃ កាលណាឮសំឡេងខ្លាំង ។ អាដាំចូលក្នុងបន្ទប់មួយទៀត ហើយបញ្ជាមកប្រដាប់ជំនួយត្រចៀកដែលខ្ញុំកំពុងពាក់នោះ ។ គាត់ឱ្យខ្ញុំលើកដៃ កាលណាខ្ញុំឮសំឡេងខ្លាំង ។ រាល់ដង អាដាំតែងងក់ក្បាល ព្រមទាំងគូសវាសលើតារាងមួយ ។

បន្ទាប់មកទៀត ខ្ញុំដោះប្រដាប់ពាក់ត្រចៀកចេញ រួចខ្ញុំចេញមកក្រៅបន្ទប់ ហើយអង្គុយជិតឪពុកម្ដាយខ្ញុំ ។ លោកម៉ាតាំងហុចតារាងមួយរួចនិយាយ ៖" អង់ជេឡា ត្រូវការប្រដាប់ជំនួយ" ។ ខ្ញុំហាក់ភ័យអរបន្តិច រួចបន្លឺពាក្យ ៖" តើត្រចៀកខ្ញុំមានបញ្ហាអ្វី ?" ។ លោកម៉ាតាំងឱ្យប្រដាប់ជំនួយត្រចៀកដល់ខ្ញុំ ។ ប្រដាប់នោះ តភ្ជាប់ពីប្រអប់មួយដែលប្រើថ្មតូចៗពីរកូន ។ ពេលខ្ញុំពាក់ប្រដាប់នោះនឹងត្រចៀក ខ្ញុំអាចឮគេនិយាយយ៉ាងច្បាស់ ទោះមិនឃើញមាត់គេក៏ដោយ ។ ខ្ញុំរីករាយណាស់ ហាក់ដូចមានរបស់ទិព្វនៅក្នុងដៃខ្ញុំ ប៉ុន្តែខ្ញុំបារម្ភក្រែងវាខូច ឬបាត់បង់ ។ លោកគ្រូពេទ្យម្នាក់ទៀត បានបង្ហាញពីរបៀបប្រើ និងផ្លាស់ប្ដូរថ្ម ។ គាត់ប្រាប់ថា ខ្ញុំអាចពាក់វាតែក្នុងពេលចាំបាច់ប៉ុណ្ណោះ ។

ថ្ងៃក្រោយមក ខ្ញុំបានពាក់ប្រដាប់ជំនួយត្រចៀកនេះ ទៅសាលារៀន ។ អ្នកគ្រូខ្ញុំបានសួរខ្ញុំតិចៗ ៖ "អង់ជេឡា ឯងអាចប្រាប់ពីហេតុផល បង្ហាញពីសារប្រយោជន៍ និងរបៀបប្រើប្រាស់ប្រដាប់នេះផងបានដែរ ឬទេ ?" ។ ខ្ញុំនិយាយរឿងរ៉ាវ ដែលខ្ញុំទទួលបានប្រដាប់នេះពាក់ និងពន្យល់ពីរបៀបដូរថ្ម ។ ពេលនោះ មិត្តរួមថ្នាក់ខ្ញុំលាន់មាត់ ៖ "យី! ប្រដាប់ជំនួយត្រចៀកជាវត្ថុអស្ចារ្យណាស់ សម្រាប់អ្នកដែលមានត្រចៀកធ្ងន់" ។

(សម្រួលពីរឿង "ប៊ូតុងក្នុងត្រចៀកនាង" របស់អាមេរិក)

## សំណួរ

១. តើកុមារីធ្ងន់ត្រចៀកឈ្មោះអ្វី ?

២. តើឪពុកម្ដាយនាងនាំនាងទៅឯណា ?

៣. តើគ្រូពេទ្យជួយនាងដោយវិធីណា ?

៤. តើប្រដាប់ជំនួយត្រចៀក មានប្រយោជន៍ដូចម្ដេច ?

## លំហាត់

ចូរបង្ហាញប្រធានបទរបស់អត្ថបទខាងលើ ដោយជ្រើសរើសចម្លើយមួយត្រឹមត្រូវ ។

☐ ១. កុមារីអង់ជេឡា

☐ ២. ប្រដាប់ជំនួយត្រចៀក

☐ ៣. មនុស្សធ្ងន់ត្រចៀក ។

# ការផ្ដល់ការណែនាំផ្ទាល់មាត់

ថ្ងៃមួយ រដ្ឋាបានឃើញឪពុកនាងកំពុងបាញ់ថ្នាំសម្លាប់សត្វល្អិតដែលផ្សំពីធម្មជាតិ ។ នាងបានសួរគាត់អំពីរបៀបផលិត និងប្រើប្រាស់ថ្នាំនោះ ។ ចូរអានការសន្ទនារវាងនាង និងឪពុកនាង ។

រដ្ឋា : ពុក ! តើពុកអាចបង្រៀនកូនបានទេ អំពីរបៀបផលិត និងប្រើប្រាស់ថ្នាំបំពុលសត្វល្អិតផ្សំពីរុក្ខជាតិនេះ ? កូនចង់ដឹងណាស់ ព្រោះវាមិនប៉ះពាល់សុខភាព ។

ឪពុក : មានអីកូន ! ចាំពុកប្រាប់ ៖ ដំបូង ត្រូវរកវត្ថុធាតុដើមមួយចំនួនដូចជា ម្ទេសទុំ០.៥ គីឡូក្រាម ម្សៅសាប៊ូ រំដេង ២គីឡូក្រាម ផ្លែនិងត្រួយល្ហុងខ្ចី ២ គីឡូក្រាម វល្លិពេជ្រ ២គីឡូក្រាម ផ្លែស្លាក់ ៣គីឡូក្រាម ស្លឹកគ្រៃមួយបាច់ និងទឹកនោម ១០លីត្រ ។

រដ្ឋា : បន្ទាប់មក តើយើងត្រូវធ្វើដូចម្ដេចទៀតពុក ?

ឪពុក : យើងយកវត្ថុធាតុដើមទាំងនោះមកចិញ្ច្រាំឱ្យម៉ដ្ឋ បន្ទាប់មកបុកបញ្ចូលគ្នា រួចច្របាច់ច្រោះយកទឹក ។ បន្ទាប់មកទៀត យកទឹកថ្នាំនោះមកលាយជាមួយនឹងទឹកនោមជាការស្រេច ។

រដ្ឋា : តើ ! គេប្រើប្រាស់វាដូចម្ដេចទៅពុក ?

ឪពុក : ដំបូង យកទឹកថ្នាំ ១លីត្រ ទៅ ២ លីត្រ លាយជាមួយទឹក ១៧ លីត្រ រួចកូរលាយជាមួយម្សៅសាប៊ូមួយស្លាបព្រាបាយ ។ បន្ទាប់មក យកល្បាយនោះទៅបាញ់លើដំណាំតែម្ដង ។

រដ្ឋា : អរគុណពុក ! កូនចេះប្រើវាហើយ ។

## សំណួរ

១. តើការណែនាំខាងលើនិយាយអំពីអ្វី ?

២. តើការណែនាំនេះមានប៉ុន្មានដំណាក់ ឬប៉ុន្មានជំហាន ?

៣. តើជំហានទី ១ និយាយអំពីអ្វី ? ជំហានទី ២ ?...

## លំហាត់

អ្នកបានដឹងច្បាស់ អំពីការផ្ដល់ការណែនាំផ្ទាល់មាត់ក្នុងការផលិតថ្នាំពុលផ្សិតពីរុក្ខជាតិ ។ ចូរអ្នករៀបចំការណែនាំផ្ទាល់មាត់មួយ ទាក់ទងនឹងសកម្មភាពបត់ក្រដាសធ្វើអ្វីមួយ ។

បន្ទាប់មក ធ្វើការជាដៃគូដោយប្ដូរវេនគ្នា ម្នាក់និយាយណែនាំ ម្នាក់ទៀតជាអ្នកធ្វើតាមការណែនាំនោះ ។

## ការណែនាំច្រើនជំហាន

នៅផ្នែកនិយាយ អ្នកបានដឹងរួចមកហើយពីរបៀបផ្ដល់ការណែ អំពីការផលិតថ្នាំពុលផ្សិតពីរុក្ខជាតិ ។ ពេលនេះ ចូរអ្នកសរសេរការណែនាំ អំពីរបៀបធ្វើអ្វីមួយ ឬប្រើប្រាស់អ្វីមួយ តាមការចូលចិត្តរបស់អ្នក ។

អ្នកអាចយកប្រធានបទណាមួយខាងក្រោមនេះក៏បាន ៖

- ការដាំបាយ ឬធ្វើនំអ្វីមួយ
- ការជិះកង់
- ការបើកវិទ្យុ ម៉ាញេ ឬទូរទស្សន៍

ដើម្បីសរសេរការណែនាំអ្នកត្រូវ ៖

១. ប្រើល្បះបញ្ជាឱ្យបានត្រឹមត្រូវ (មើលគំរូក្នុងបំណិន ការនិយាយ អំណាន)

២. ប្រើពាក្យបញ្ជាក់លំដាប់ឱ្យបានត្រឹមត្រូវ (ដំបូង បន្ទាប់មក ...)

៣. ប្រាប់ឈ្មោះ ឬចំណងជើងការណែនាំ (ឧ. ការណែនាំអំពីការផលិតថ្នាំពុលផ្សិតពីរុក្ខជាតិ)

៤. ផ្ដល់ការណែនាំងាយៗ ឆាប់យល់ដោយប្រើពាក្យងាយៗ ខ្លីៗ ។

៥. សរសេរចប់ត្រូវកែលម្អឡើងវិញ ។

# ៧ តែសអំណាន

ចូរអានអត្ថបទ រួចឆ្លើយនឹងសំណួរខាងក្រោម ។

## ដើមកំណើតនៃបាយ

កាលពីយូរលង់ណាស់មកហើយ ដូនតារបស់យើងរស់នៅជាក្រុមៗ ហើយផ្លាស់ប្តូរទីកន្លែងរស់នៅជារឿយៗ ។ ពួកគាត់ចិញ្ចឹមជីវិតដោយការបរបាញ់សត្វ និងបេះផ្លែឈើធ្វើជាអាហារ ។

ជារៀងរាល់ថ្ងៃ ពួកប្រុសៗខ្លះចេញទៅបរបាញ់ ខ្លះទៀតទៅចាប់ត្រីនៅក្នុងទន្លេ បឹង និងអូរ ។ ស្រីៗ និងកុមារធំៗ ទៅបេះផ្លែឈើ និងបន្លែនៅក្នុងព្រៃ ។ ស្រីចាស់ៗ នៅមើលថែក្មេងតូចៗ ។ ពេលត្រឡប់មកវិញ ពួកគេយកសត្វ ផ្លែឈើ មើមឈើ បន្លែដែលរកបានមកចែកគ្នាស្មើ ។ ពួកគាត់រស់នៅរបៀបនេះ យ៉ាងសប្បាយជារៀងរហូតមក ។

ថ្ងៃមួយ ក្រុមអ្នកបរបាញ់បានធ្វើដំណើរទៅភ្នំមួយ ក៏បានជួបនឹងជ្រូកព្រៃមួយ ។ ពួកគេនាំគ្នាដេញតាមជ្រូកនោះ រហូតដល់អស់កម្លាំង ក៏នាំគ្នាសម្រាកក្រោមដើមឈើធំមួយ ។ ពេលនោះ ពួកគាត់បានឃើញមនុស្សចម្លែកមួយក្រុម ដើរមករកគាត់ ។ ពួកគាត់មិនបានស្គាល់ទេពធីតា និងទេវតាទេ ។ ពួកគាត់បាននាំគ្នាក្រោកឈរគោរព ដោយឱនលំទោន ។ ទេវតាសប្បាយចិត្ត ព្រោះឃើញពួកគាត់ចេះគួរសម ក៏អញ្ជើញគាត់ទៅចូលរួមពិធីជប់លៀង ។

អ្នកបម្រើរបស់ទេវតា បានយកអាហារជាច្រើនមកជូនគាត់ ដែលមានសាច់អាំង បន្លែឆ្អិន ផ្លែឈើ ស្រា ព្រមទាំងបាយ ។ ពេលគាត់ឃើញបាយជាលើកដំបូង គាត់ស្ទាក់ស្ទើរមិនហ៊ានហូបឡើយ ។ ពេលនោះមេក្រុមប្រកែក ៖ "យើងមិនហូបដង្កូវសនេះទេ" ។ ទេវតាសើចហើយនិយាយ ៖ "គ្រាប់សៗនេះមិនមែនជាដង្កូវទេ ។ វាជាបាយ ។ យើងបានពីរុក្ខជាតិម្យ៉ាងដែលយើងបានដាំ ។ ហូបទៅ! ប្រសិនបើអ្នកឈឺក្រោយពេលហូបវាសូមអ្នកសម្លាប់ខ្ញុំចុះ" ។

ពួទេវតានិយាយដូច្នេះ អ្នកបរបាញ់លែងប្រកែក ។ ពួកគាត់នាំគ្នាហូបអ្វីៗដែលមាននៅពេលនោះ រួមទាំងបាយផងដែរ ។ ពួកគាត់ហាក់ដូចជាមានកម្លាំងប្លែក បន្ទាប់ពីហូបបាយ ។ គាត់និយាយទៅកាន់ទេវតា ៖ “បាយធ្វើឱ្យយើងមានកម្លាំងណាស់ ។ នេះជាអាហារពិសេស ។ តើយើងអាចរកវានៅឯណា ?” ។

ទេវតាប្រាប់ ៖ “ យើងនឹងឱ្យគ្រាប់វាខ្លះ ។ អ្នកត្រូវភ្ជួររាស់ដី ហើយដាំវានៅរដូវភ្លៀង ។ បី បួនខែក្រោយមក អ្នកអាចច្រូតកាត់វាបាន ។ ចូរអ្នកបង្រៀនអ្នកឯទៀតឱ្យចេះដាំស្រូវ អ្នកនឹងទទួលបាននូវសុខភាពល្អមិនខាន ហើយវានឹងបញ្ឈប់ការចល័តកន្លែងរបស់អ្នក” ។

អ្នកបរបាញ់អរគុណទេវតា រួចត្រឡប់មកទីជម្រកវិញ ។ គាត់ធ្វើតាមការណែនាំរបស់ទេវតា ។ មិនយូរប៉ុន្មានពួកគាត់សាកល្បងដាំស្រូវ និងផ្សព្វផ្សាយពីការហូបបាយទៅភូមិផ្សេងទៀត ។ ពួកគាត់ឈប់ប្តូរទីកន្លែង ហើយចាប់ផ្តើមសង់ផ្ទះនៅ ។ តាំងពីពេលនោះមក បាយបានក្លាយជាអាហារសំខាន់របស់យើង ។

**ចូរអ្នកគូសសញ្ញា ✓ ក្នុងប្រអប់ពីមុខចម្លើយមួយត្រឹមត្រូវ ។**

១. ហេតុអ្វីបានជាដូនតាយើង តែងតែផ្លាស់ប្តូរទីកន្លែងរស់នៅ ?

- ☐ ក. ពីព្រោះកន្លែងចាស់ ពិបាករស់នៅ ។
- ☐ ខ. ពីព្រោះគាត់ធុញទ្រាន់នឹងកន្លែងចាស់ ។
- ☐ គ. ពីព្រោះគាត់ចង់ឃើញទេសភាពប្លែកៗ ។
- ☐ ឃ. ពីព្រោះកន្លែងចាស់គាត់រកអាហារលែងបាន ។

២. តើពួកគាត់ធ្វើដូចម្តេច នៅពេលរកអាហារបាន ?

- ☐ ក. ពួកគាត់សន្សំទុករៀងៗខ្លួន ។
- ☐ ខ. ពួកគាត់ហូបរៀងៗខ្លួន ។
- ☐ គ. ពួកគាត់ចែកគ្នាស្មើ ។
- ☐ ឃ. ពួកគាត់លក់ដូរទៅវិញទៅមក ។

៣. ហេតុអ្វីបានជាទេវតាមានការគួរសមចំពោះគាត់ ?

- ☐ ក. ពីព្រោះទេវតាឃើញគាត់ចេះគួរសម ។
- ☐ ខ. ពីព្រោះទេវតាមានអាហារច្រើន ។
- ☐ គ. ពីព្រោះទេវតាចង់បានគាត់ជាមិត្ត ។
- ☐ ឃ. ពីព្រោះទេវតាចង់ហូបអាហារជាមួយគាត់ ។

៤. ហេតុអ្វីបានជាអ្នកបរបាញ់ស្ទាក់ស្ទើរមិនហ៊ានហូបបាយ ?

- ☐ ក. ពីព្រោះអ្នកបរបាញ់មិនចូលចិត្តហូបបាយ ។
- ☐ ខ. ពីព្រោះអ្នកបរបាញ់មិនធ្លាប់ស្គាល់បាយ ។
- ☐ គ. ពីព្រោះអ្នកបរបាញ់ខ្លាចបាយធ្វើឱ្យគាត់ពុល ។
- ☐ ឃ. ពីព្រោះអ្នកបរបាញ់ចង់ហូបសាច់ឱ្យបានច្រើន ។

៥. តើអ្នកបរបាញ់មានអារម្មណ៍ដូចម្តេច ក្រោយពេលហូបបាយ ?

- ☐ ក. អ្នកបរបាញ់មានការស្រេកឃ្លាន ។
- ☐ ខ. អ្នកបរបាញ់មានការឈឺចាប់ ។
- ☐ គ. អ្នកបរបាញ់មានកម្លាំង ។
- ☐ ឃ. អ្នកបរបាញ់អស់កម្លាំង ។

៦. ហេតុអ្វីបានជាដូនតាយើងឈប់ប្តូរទីកន្លែង ?

- ☐ ក. ពីព្រោះគាត់ពិបាកធ្វើដំណើរឆ្ងាយ ។
- ☐ ខ. ពីព្រោះគាត់មានអាហារគ្រប់គ្រាន់ ។
- ☐ គ. ពីព្រោះគាត់រកអាហារលែងបាន ។
- ☐ ឃ. ពីព្រោះគាត់ខ្លាចជួបទេវតា ។

៧. តើព្រឹត្តិការណ៍ណាមួយជាព្រឹត្តិការណ៍ប្រឌិត ?

- ☐ ក. ពីយូរណាស់មកហើយ ដូនតាយើងរស់នៅជាក្រុមតូចៗ ។
- ☐ ខ. ពួកគាត់ចិញ្ចឹមជីវិតដោយការបរបាញ់ បេះបន្លែ ផ្លែឈើ ។
- ☐ គ. ពួកគាត់ជួបនឹងទេវតា ទេពធីតានៅក្បែរភ្នំ ។
- ☐ ឃ. ក្រោយពេលរកបានអាហារគាត់យកមកចែកគ្នាហូប ។

# បទានុក្រម

## ក

កន្ទ្រើង ( កន់ -ទ្រើង) គុ. សំពោងមិនរាបទាប : សក់កន្ទ្រើង ។

កម្មសិទ្ធិ (កាំ -មៈ -សិត) ន. ទ្រព្យសម្បត្តិដែលត្រូវសម្រេចមកលើខ្លួន ។

កម្សាន្ត (កំ- សាន)កិ. សម្រាកចិត្ត លំហើយចិត្ត ។

កវី (កៈ -វី ) ន. អ្នកតែងកំណាព្យ ។

កល្យាណមិត្ត (កល់ -យ៉ាន -ណៈ មិត)ន. មិត្តល្អ មិត្តត្រឹមត្រូវដែលបុគ្គលគួរសេពគប់ គួររាប់រកជាគ្នា ។

កាន់វស្សា (កាន់ -វ័ស -សា) ន. នៅរក្សាអរុណក្នុងរដូវភ្លៀង ក្នុងទីមានកំណត់របស់អ្នកបួស ខាងពុទ្ធសាសនា ។

កសិដ្ឋាន (កៈ -សិ -ឋាន) ន. កន្លែងធ្វើស្រែចម្ការ កន្លែងចិញ្ចឹមសត្វ ។

កាលៈទេសៈ ន. សម័យកាលរបស់ស្រុកទេស ។

កេរ (កេ)ន. ដំណែល ជាសម្បាច់របស់ដូនតា ឬមាតាបិតាជាដើម ។

កេណ្ឌ (កែន) កិ. ប្រមូលហៅរកដោយអាជ្ញា : កែនពល ។

កេរមរតក (កេ -មៈ -រៈ -ដក់) ន. ទ្រព្យដំណែលរបស់អ្នកដែលបានស្លាប់ទៅហើយ ។

ក្រោធ (ក្រោត) កិ. ខឹង ។

## គ

គណៈកម្មាធិការ (គៈ -ណៈ -កាំ -ម៉ា -ធិ -កា) ន. សមាជិកក្រុមដែលតាំងឡើងដោយរាជការ ។

គណៈប្រតិភូ (គៈ-ណៈ-ប្រៈ-តិ-ភូ)ន. ជនមួយក្រុមដែលចាត់ជាតំណាងប្រទេស ឬក្រសួងណាមួយ ។

គុណភាព (គុណៈ -ភាប) ន. ភាពល្អ ភាពប្រសើរ របស់ដែលមានអានុភាពសក្តិសិទ្ធិ ។

គម្ពីរ (គំ -ពី)ន. សាស្ត្រា ច្បាប់ ធម្មវិន័យ ក្បួន ។

គោលជំហរ (គោល -ជំ -ហ៊ ) ន. ឥរិយាបថ ចិត្តគំនិត ការប្រកាន់យកគំនិតណាមួយ ។

គ្រងរាជ្យ (គ្រង -រាច) កិ. សោយរាជ្យ ។

គ្រឿងឧបភោគ (គ្រឿង -អ៊ុ បៈ -ភោក) ន. គ្រឿងសម្រាប់ប្រើប្រាស់ជិតខ្លួន ។

គ្រោះមហន្តរាយ (គ្រោះ -មៈ -ហាន់ -តៈ -រ៉ា យ) ន. គ្រោះថ្នាក់ធំ ។

## ឃ

ឃាតកៈ (ឃា -តៈ -កៈ) ន. អ្នកសម្លាប់ ។

## ង

ងារ (ងា) ន. មុខការ ទីតំណែងរាជការ តាមបណ្តាស័ក្តិឋានន្តរ ។

## ច

ចម្លាក់ (ចំ -ល៉ាក់ ) ន. រូប ឬ ក្បាច់ដែលគេឆ្លាក់ (ការរចនា) ។

ចម្រូង	(ចំ -រ៉ូង) ន. ឈើ ឬ ឫស្សី ដែក ដែលស្រួចបោះនៅដី ។
ចរិយាសម្បត្តិ	(ចៈ -រិ -យ៉ា -សំ -ប័ត) ន.ការបរិបូណ៌ដោយការប្រព្រឹត្តិល្អ ។
ចារ	(ចា) កិ.សរសេរ ។

## ឆ

ឆស័ក	(ឆ -សាក់) ន. ស័កទី៦ ក្នុងចំនួនស័កដប់ឆ្នាំ ។

## ជ

ជយតុ	(ជៈ-យៈ-តុៈ)ន. ពាក្យសម្រាប់ឱ្យពរជ័យថា សូមឱ្យមានជ័យជម្នះ ។
ជាតិសាសន៍	(ជាត -សាស់) ន. កំណើតមនុស្ស : មនុស្សមានជាតិសាសន៍ត្រូវគ្នា ខុសគ្នា ។
ជីវភាព	(ជី វៈ ភាប) ន. ភាពនៃការរស់នៅ ការចិញ្ចឹមជីវិត ។

## ឈ

ឈ្នានីស	(ឈ្នា -និះ) ន. ច្រណែន ឬស្បា បង្ខាត កាត់លាភ កាត់ប្រយោជន៍គេ ។

## ញ

ញាណ	(ញាន) ន. សេចក្ដីដឹង ប្រាជ្ញា ។
ញាតិ	(ញាត) ន. អ្នកដែលរួមខ្សែលោហិតជាមួយគ្នាខាងម្ដាយ ឬខាងឪពុក ។
ញោម	ន. ពាក្យសម្រាប់បព្វជិតហៅឪពុកម្ដាយ ។

## ឋ

ឋានៈ	(ឋា -នៈ) ន. ងារ មុខងារ យសស័ក្តិ ។

## ណ

ណែងណង	ន. ពាក្យចួនជាប់គ្នាធ្វើឱ្យកំណាព្យ ឬឃ្លាល្បះកាន់តែពីរោះថែមទៀត ។

## ត

តថភាព	(តៈ -ថៈ -ភាព) ន. ភាពនៃការពិត ។
តន្ត្រី	(ដន់ -ត្រី) ន. ភ្លេង ។
តំបន់ទេសចរណ៍	(តំ-បន់-ទេសៈ-ច)ន.ទីកន្លែងសម្រាប់ដើរលំហែកម្សាន្ត ។
តាំងពិព័រណ៍	(តាំង -ពិ -ព័រ) កិ. ដាក់តាំងផលិតផល របស់ផ្សេងៗបង្ហាញឱ្យមហាជនមើល ។

## ថ

ថវិកា	(ថៈ -វិ -កា)ន.ប្រាក់ លុយ ។

## ទ

ទ័ព (ទាប់)ន. ទាហាន សេនា ពល សម្រាប់ធ្វើចម្បាំង ។

ទស្សនៈ (ទ័ស-សៈ-នៈ)ន. ការឃើញ ការយល់ឃើញ ។

ទស្សនកិច្ច (ទ័ស - សៈ - ន៌ៈ កិច) ន. ចក្ខុដែលមានការឃើញជានិច្ច ឬជាមុខការ ។

ទស្សនា (ទ័ស - សៈ - ន៉ា) កិ. មើល សម្លឹងមើល ។

ទស្សនាវដ្ដី (ទ័ស-សៈ-ន៉ា-វ៉ាត់-ដី)ន. សៀវភៅចុះអត្ថបទច្រើនផ្នែកផ្សាយចេញប្រចាំសប្ដាហ៍ ឬ ប្រចាំខែ ។

ទារុណកម្ម (ទា - រុ - ណៈ - ក័ម) ន. អំពើកាច អំពើអាក្រក់ អំពើសាហាវយង់ឃ្នង ។

ទិដ្ឋភាព (ទិត - ថៈ - ភាប) ន.ភាពនៃអ្វីៗដែលគេបានឃើញ បានជួបប្រទះ ។

ទិវង្គត (ទិ - វង់ - គត់) កិ. ស្លាប់ ។

ទិវា ន. ក្នុងវេលាថ្ងៃ នៅពេលថ្ងៃ ។

ទិសអាគ្នេយ៍ (ទិស - អា - គ្នេ) ន. ទិសតូចស្ថិតនៅចន្លោះទិសខាងកើតនិងខាងត្បូង ។

ទូន្មាន (ទូន - មាន).កិ. អប់រំ ប្រៀនប្រដៅ ណែនាំ ។

## ធ

ធនធាន (ធន់ - ធាន) ន. សម្បត្តិទ្រព្យរបស់ផ្សេងៗដែលគង់នៅ ។

ធម្មជាតិ (ធ័ម - មៈ - ជាត)ន. សភាវៈ សភាពកើតឯង មានទឹកដី ព្រៃព្រឹក្សា សត្វ ភ្នំ... ។

## ន

ន័យ (នៃ)ន. សេចក្ដីពន្យល់ហេតុ ទំនង លំនាំ... ។

និយមន័យ (និ - យំ - នៃ) កិ.កំណត់ អនុលោមតាម ចូលចិត្ត ។

និស្ស័យ (និស - សៃ) ន. ដំណើរ ឬគុណសម្បត្តិដែលមានពីកំណើតស្រាប់ ។

នាវា ន. កប៉ាល់ ។

និទ្ទេស (និ - ទេស) ន. ការសម្ដែងចែកញែកសេចក្ដី ។

និទ្រា ន. ដំណើរដេកលក់ ។

និន្ទា (និន - ទា) ន. ដំណើរតិះដៀល ការរិះគន់ ។

និពន្ធ (និ - ពន់) កិ. តាក់តែង ចងក្រង រៀបរៀង ។

និមន្ត (និ - មន់) កិ. អញ្ជើញ សូមឱ្យទៅ សូមឱ្យមក ។

និរន្តរ៍ (និ - រ៉ន់) កិ.វិ .ជានិច្ច ដែលឥតមានចន្លោះ ។

និស្សិត (និស - សិត) ន. អ្នករៀនក្នុងគ្រឹស្ថានឧត្ដមសិក្សា ។

នេសាទុបករណ៍ (នេ - សា - ទុប - ប៉ - ក) ន. ប្រដាប់នេសាទមាន មង អញ្ចង ទ្រូ លប ជាដើម ។

# ប

**បច្ចុប្បន្ន** (ប៉ុច - ចុ - បន់) ន. ពេលឥឡូវនេះ ពេលដែលកំពុងតែមាននៅចំពោះមុខ ។

**បទពិសោធ** (បត់-ពិ-សោត)ន. ដំណើរទំនងនៃការសាកល្បង ។

**បច្ចេកទេស** (ប៉ុច - ចេកៈ - ទេស) ន. ចំណែកមួយផ្សេងដែលលើកយកមកនិយាយផ្សេង ដោយឡែកខាងមុខវិជ្ជាណាមួយយ៉ាងស្ទាត់ជំនាញ ។

**បង្ការ** (បង់ - កា) កិ. រារាំង ប្រុងប្រយ័ត្ន ។

**បណ្ឌិត** (បន់ - ឌិត)ន. ជនអ្នកប្រព្រឹត្តល្អ គឺអ្នកកាន់សុចរិត១០ប្រការ ,ឬជាពិស្តារ ,ឬកាន់សុចរិត ៤០ប្រការដោយខ្ជាប់ខ្ជួន អ្នកប្រាជ្ញខាងផ្លូវសុចរិតយុត្តិធម៌ ។

**ប័ណ្ណ** (ប័ន) ន. ក្រដាស ឬសៀវភៅដែលគេសរសេរឈ្មោះ ឬកត់ត្រាអ្វីផ្សេងៗ ។

**ប័ណ្ណឃោសនា** (ប័ន- ឃោ - ស្នា) ន. សំបុត្រផ្សព្វផ្សាយដំណឹងដោយអន្ទង ឬបញ្ចុះបញ្ចូលសាធារណជន ឱ្យចូលចិត្តលើ វត្ថុណាមួយ ឬ មានជំនឿលើសកម្មភាពអ្វីមួយ ។

**បរទេស** (ប - រ៉ៈ - ទេស) ន. ប្រទេសដទៃ ឬអ្នកប្រទេសក្រៅ ។

**បរិបូណ៌** (ប- រ៉ិ - បូ ឬប- បូ) គុ. ដែលមានច្រើនដែលគ្រប់គ្រាន់ ដែលសម្បូរ ឆ្អែត ។

**បិតា** (បិ - ដា)ន. ឪពុក ។

**បុគ្គលិក** (បុក - គៈ - លិក)ន. ភ្នាក់ងាររាជការ ឬនិយោជិតតាមស្ថាប័នផ្សេងៗ ។

**បុព្វ** (បុប - ពៈ) គុ. មុន ខាងដើម ។

**បុព្វបុរស** (បុប - ពៈ - បុ - រ៉ស់) ន.បុរសជាខាងដើមវង្ស ។

**បូជា** កិ. ថ្វាយ ជូន ដុត ។

**ប៉ូលិស** ន. ភ្នាក់ងាររក្សាការពារនូវរបៀបរៀបរយសា ធារណៈ ។

**បរិវេណ** (ប - រ៉ិ - វេន) ន.ទីធ្លា ទីកន្លែងជុំវិញ ។

**បរិស្ថាន** (ប៉ៈ - រ៉ិ - ឋាន) ន. កន្លែងដែលនៅជុំវិញយើងរស់នៅ ។

**បាគូ** ន. អាចារ្យសាសនាព្រាហ្មណ៍រស់នៅក្នុងព្រះបរមរាជវាំងជាអ្នកផ្លុំស័ង្ខពេលមានពិធីទ្វារ ទសមាស ។

**បេតិកភណ្ឌ** (ប៉េ - តិ - កៈ - ភាន់) ន.ទ្រព្យសម្បត្តិ ឬកេរមរតកដែលមានជាប់តមកពីខាងឪពុក ។

**បេតិកភណ្ឌពិភពលោក** (ប៉េ - តិ - កៈ - ភាន់ - ពិភប់ - លោក)ន. ទ្រព្យសម្បត្តិពិភពលោក ។

**បំភ្លៃ** កិ. បញ្ចូលបន្ថែម ថែមផ្សំ លស់រំលងខ្លះមិនរៀបរៀងតាមលំដាប់ ។

**ប្រការ** (ប្រ- កា)ន. វិធី បែប ប្រភេទ ។

**ប្រណីត** (ប្រ- ណិត)គុ. ដែលល្អឥតខ្ចោះ ដែលស្រស់ត្រចង់ ។

**ប្រទាន** កិ. ឱ្យ ប្រគល់ឱ្យ ។

**ប្រផ្នូល** ន. ការបូល ឬហេតុដែលឱ្យបានដឹងជាមុន ។

**ប្រល័យ** (ប្រ- ល៉ៃ)ន. សេចក្ដីវិនាស លោកវិនាស (ដំណើរវិនាសពិភពលោក) សេចក្ដីវិនាសជីវិត (មរណៈ) ។

**ប្រលោមលោក** (ប្រ - ល៉ោម - លោក)ន. រឿងប្រលោមចិត្តមនុស្សលោក ។

**ប្រវត្តិសាស្ត្រ** (ប្រ - វ៉ត - តិ - សាស) ន. រឿងរ៉ាវ ពង្សាវតារ ដំណឹង ការប្រព្រឹត្តិទៅ ឬការប្រព្រឹត្តិរៀងមក ។

**ប្រារព្ធ** (ប្រា - រប់)កិ. តាំងផ្ដើម ផ្ដួចផ្ដើម ផ្ដងជាមុន គិតដល់ ។

## ផ

**ផលិតផល** (ផល់ - លិ - តៈ - ផល) ន. ផលដែលកើតឡើងមកពីការប្រកបរបរផ្សេងៗមាន កសិកម្ម និង ឧស្សាហកម្ម ។

**ផ្សព្វផ្សាយ** (ផ្សប់- ផ្សាយ)កិ. ផ្សាយដោយការប៉ះពាល់ត្រូវ ផ្សាយសព្វជ្រួតជ្រាបសព្វអន្លើ ។

**ផាមួង** ន. ឈ្មោះសំពត់សូត្រមួយប្រភេទមានពណ៌លាតផ្សេងៗសម្រាប់ស្លៀកក្នុងពិធីប្រពៃណីផ្សេងៗ ។ វាមានកំណើតនៅកម្ពុជរដ្ឋ ។

## ព

**ព័ត៌មាន** (ព័រ- ដ៏- មាន) ន. ដំណឹងផ្សេងៗក្នុងបច្ចុប្បន្ន ព្រឹត្តិការណ៍ ។

**ពាណិជ្ជកម្ម** (ពា - និច - ជៈ - កាំ) ន. ការលក់ដូរ របរលក់ដូរ ។

**ពលិកម្ម** (ពៈ - លិ - កាំ) ន. ការលះបង់ ។

**ពាលា** គុ. កាច សាហាវ អាក្រក់ ។

**ពិសោធន៍** (ពិ - សោធ) ន. ការល្បងមើល ដំណើរពិនិត្យ ឬសាកមើលឱ្យឃើញពិត ។

**ពុទ្ធសករាជ** (ពុត - សៈ - កៈ - រ៉ាច)ន. ចំនួនថ្ងៃ ខែ ឆ្នាំ រាប់តាំងពីក្រោយថ្ងៃដែលព្រះពុទ្ធទ្រង់ចូលបរិនិព្វានទៅបានមួយថ្ងៃកន្លងមក ។

**ព្រឹត្តិការណ៍** (ព្រឹត- តិ- កា) ន. ហេតុ ឬដំណឹងដែលតែងកើតមានជាធម្មតាៈថ្ងៃនេះមានព្រឹត្តិការណ៍ប្លែកៗ ។

**ព្រេច** កិ. ពារនឹងក្បាល ជាន់នឹងជើង ចាក់នឹងភ្លុក ។

**ព្រះត្រៃបិដក** (ព្រះ- ត្រៃ - បី - ដក់)ន. ប្រជុំនៃព្រះធម្មវិន័យសាសនា ៣ ចំណែកគឺ វិន័យបិដក សុត្តន្តបិដក និងអភិធម្មបិដក ។

## ម

**មរតកអក្សរសិល្ប៍** (មៈ- រៈ - ដក់- អ័ក- ស- សិល)ន. ស្នាដៃអក្សរសិល្ប៍ដែលកវី ឬអ្នកនិពន្ធបន្សល់ទុកឱ្យ ។

**មធ្យោបាយ** (ម័ត - ធ្យោ - បាយ) ន. ឧបាយជាកណ្ដាល ដំណើរទំនងដ៏ល្មមគួរសមសម្រាប់ធ្វើកិច្ចការឱ្យបានសម្រេចតាមបំណង ។

**មាតា** (មា- ដា) ន. ម្ដាយ ម៉ែ ។

**មារយាទ** (មា- យាត) ន. ឫក របៀប សណ្ដាប់ធ្នាប់ ។

**មូលដ្ឋាន** (មូល - ល៉ាត់ - ឋាន) ទីដែលជាឫសគល់ ទីតាំងមាំ គោលការណ៍សំខាន់ ។

**មូលនិធិ** ន. កំណប់ទ្រព្យដើម (ប្រាក់ដែលបានចងការឱ្យគេ ប្រាក់ដែលមានចំណាយធ្វើការណាមួយ បម្រុងនឹងយកចំណេញទៅខាងមុខ ប្រាក់ដែលចំណាយធ្វើបុណ្យ) ។

**មោទនភាព** (មោ - ទ: - ន: - ភាប) ន. ភាពអំនួត ភាពក្រអឺត ក្រទម ភាពសប្បាយរីករាយ ។

## រ

**រចនា** (រ: - ច: - ន៉ា)កិ. ធ្វើឱ្យត្រូវតាមរបៀប ។

**រណ្ដំ** (រន់- ដំ)កិ. ដំគ្នារឿយៗ ប៉ះ ឬទង្គិចគ្នាដូចគេដំរឿយៗ ។

**រមណីយដ្ឋាន** (រ: - ម: - នី - យ៉ាត់ - ឋាន) ន. កន្លែងដែលជាទីរីករាយ ។

**រវើក** គុ. កិ. ដែលកម្រើក ឬបម្រះរើកៗ ។

**រសាយ** កិ. របូតកំនួច របូតចំណង ។

**រម្យទម** (រំ - ទំ)គុ. ដែលស្រគត់ស្រគំ ដែលសុភាពរាបសា ។

**រាត្រី** ន. យប់ ។

## ល

**ល័ក្ត ឬល័ខ** (លាក់)ន. វត្ថុរាវសម្រាប់លាប ជ្រលក់អំបោះ សូត្រយកពណ៌ ។

**លិខិត** ន. សំបុត្រ ។

**ល្មើស** កិ. ប្រព្រឹត្តលើសរំលងលើច្បាប់ ។

## វ

**វគ្គ** (វីក) ន. ពួក ក្រុម ប្រជុំ សង្កាត់ ។

**វង្សត្រកូល** (វង់ -ត្រកូល) ន. ពូជ ក្រសែតំណត្រកូល ។

**វចនានុក្រម** (វ: - ច: - ន៉ា នុ - ក្រំ) ន. ឈ្មោះសៀវភៅរៀបលំដាប់ពាក្យនិងពន្យល់ន័យពាក្យ ។

**វណ្ណយុត្តិ** (វីន- ណ: - យុត) ន. គ្រឿងសម្រាប់ផ្សំជាមួយនឹងអក្សរក្នុងភាសាខ្មែរ វណ្ណយុត្តិមាន១៨គឺ អស្តា ( ៏ ) ធ្មេញកណ្ដុរ ( ៉ )... ។

**វប្បធម៌** (វីប - ប៉: - ធម៌) ន. ការផ្សាំបណ្ដុះចំណេះវិជ្ជា និងស្មារតីឱ្យបានលូតលាស់ចម្រើន ដោយវិទ្យាសាស្ត្រ ឬដោយសិល្បៈផ្សេងៗ ។

**វ័យ** (វៃ)ន. អាយុ កំណត់អាយុ ។

**វិចិត្រ** (វិ - ចិត)គុ. ដែលល្អប្លែក ។

**វិញ្ញាណ** (វិញ - ញាណ)ន. ធម្មជាតិដឹងច្បាស់ដោយអារម្មណ៍ ។

**វិទ្យាសាស្ត្រ** (វិត - ទ្យា - សាស)ន. គម្ពីរ ក្បួនប្រាប់វិជ្ជាផ្សេង ៗ ។

**វិន័យ** (វិ - នៃ)ន. ច្បាប់ បែបបទ ដឹកនាំទៅរកផ្លូវល្អ ។

**វិស្វករ** (វិះ - ស្វ: - ក)ន. អ្នកបច្ចេកទេសខាងសំណង់ អគ្គិសនី អេឡិកត្រូនិចជាដើម ។

វិស្សមកាល (វិស-សៈ-មៈ-កាល)ន. ពេល ខែ ឬឱកាសដែលឈប់សម្រាកមិនធ្វើការ ឬមិនចូលសាលារៀន ។

វីរជន (វី-រ-ជន់)ន. ជនអង់អាចក្លាហាន ។

វីរបុរស (វី-រ-បុ-រស់)ន. បុរសអង់អាចក្លាហាន ។

វីរុស ន. មេរោគ ។

វុឌ្ឍី (វុត-ឈី)ន. សេចក្តីចម្រើន ការលូតលាស់ ។

វៀរ (វៀ)កិ. លើកលែង តម អត់មិនធ្វើ ។

## ស

សក្ខី (ស័ក-ខី) ន. សាក្សី ។

សក្តានុពល (ស័ក-ក្តា-នុ-ពល់) ន. ភាពដែលអាចធ្វើអ្វីៗមួយទៅបាន ។

សណ្ឋិត (សន់-ឋិត)គិ. ឋិតនៅស៊ប់ តាំងស៊ប់ ។

សតវត្សរ៍ (សៈ-តៈ-វ័ត) ន. ឆ្នាំមួយរយ កាលកំណត់មួយជុំរយឆ្នាំ ឬមួយខួបរយឆ្នាំ ។

សន្ទនា (សន់-ទៈ-នា) ន. ការនិយាយគ្នា។

សន្និសីទ (សន់-និ-សិត) ន. ការប្រជុំជជែកពិភាក្សាបញ្ហាផ្សេងៗដែលស្ថិតនៅក្នុងសកម្មភាពស្មុគស្មាញមិនទាន់ដាច់ស្រេច ដើម្បីរិះរកផ្លូវចេញ ឬដោះស្រាយឱ្យជ្រះស្រឡះ ការថ្លែងសេចក្តីពន្យល់ អំពីបញ្ហាផ្សេងៗដល់សាធារណជន ។

សន្យា (សន់-យ៉ា)កិ. ប្តេជ្ញា សន្មត ។

សមត្ថកិច្ច (សៈ-ម៉ុត-ថៈ-កិច) ន. ការដែលអាចធ្វើបាន ។

សមរភូមិ (សៈ-ម៉ៈ-រ៉ៈ-ភូម) ន. ទីបោះទ័ព ទីចម្បាំង ។

សមរម្យ (សំ-រំ) គុ ឬគុកិ. ដែលត្រូវបែបបទមិនទាស់ភ្នែក ។

សម្ផស្ស (ស័ម-ផ័ស) ន. ការប៉ះពាល់ព្រម ការប៉ះពាល់ត្រូវពេញ ភាពសម សម្រស់ ។

សម្ព័ន្ធមិត្ត (សំ-ព័ន-មិត) ន. ការចងគ្នាជាមិត្ត ។

សម្ពោធ (សំ-ពោត)កិ. ថ្លែងសេចក្តីរៀបរាប់ ឬរាយការណ៍ក្នុងទីប្រជុំធ្លង ឬឡើងមន្ទីរជាដើម ។

សហការ (សៈ-ហៈ-កា) ន. ការព្រមធ្វើជាមួយគ្នា ។

សហគមន៍ (សៈ-ហៈ- គំ)ន. ប្រជុំភូមិ ឬតំបន់អ្នកស្រុកប្រកបរបរចូលគ្នា ។

សាធារណជន (សា-ធា-រៈ-ណៈ-ជន់)ន. ជនទូទៅ ។

សារព័ត៌មាន (សា-រៈ-ព័រ-ដ៏-មាន)ន. កាសែត ទស្សនាវដ្តី ។

សារមន្ទីរ (សា-រៈ-មន់-ទី)ន. កន្លែងតម្កល់វត្ថុបុរាណ ។

សិក្ខាសាលា (សិក-ខា-សា-ល៉ា)ន. ការប្រជុំសិក្សារៀនសូត្រ ។

សិប្បកម្ម (សិប-ប៉ៈ-កាំ)ន. ការងារផ្សេងៗ ការផលិតសម្ភារៈផ្សេងៗសម្រាប់ប្រើប្រាស់ ។

សិប្បករ (សិប-ប៉ៈ-ក)ន. អ្នកធ្វើជាង ។

សិល្ប៍ (សិល)ន. ចំណេះវិជ្ជាផ្សេងៗ ។

សិស្សានុសិស្ស (សឹស - សា - នុ - សឹស)ន. សិស្សទាំងអស់ ។

សីលធម៌ (សិល -ធ័រ)ន ដំបូន្មានដែលនាំឱ្យវៀរចាកអំពើអាក្រក់ ហើយឱ្យប្រព្រឹត្តតែអំពើល្អ ។

សុចរិត (សុ -ចៈ -រិត)ន. ការប្រព្រឹត្តល្អ ។

សេដ្ឋកិច្ច (សេត -ថៈ -កិច)ន. មុខរបរដែលមានប្រយោជន៍ដ៏សំខាន់ក្នុងប្រទេសនីមួយៗ ។

សេនា (សេ -ន៉ា)ន. ពួកទាហាន កងទ័ព រេហ៍ពល ។

សេព (សែប)កិ. រាប់រកយកជាគ្នា ប្រព្រឹត្ត ប្រើប្រាស់ ។

ស្គុក (ជើង ដ)គុ. ដែលមានច្រើន មានទំហំធំ ។

ស្នាព្រះហស្ត (ស្នា -ព្រះ -ហ៊ាស់)ន. ស្នាដៃ ។

ស្រវាស្រទេញ (ស្រ -វ៉ា -ស្រ -ទេញ)កិ. ខំប្រឹងខ្លាំង សង្វាតខ្លាំង ។

## ហ

ហេតុការណ៍ (ហែត -កា) ន. ការ ឬដំណើរប្រព្រឹត្តទៅ ដំណើរ ឬរឿងដែលកើតឡើង ។

ហោរា (ហោ -រ៉ា)ន. គ្រូទាយ ។

ហ្មឿ ន. អ្នកទាក់ដំរី ឬអ្នករក្សាដំរី ។

## អ

អក្ខរា (អ័ក -ខៈ -រ៉ា) ន. អក្សរ ។

អក្សរសាស្ត្រ (អ័ក -ស -សាស) ន. ក្បួនខ្នាតរបស់អក្សរ ។

អគ្គិសនី (អ័ក -គិ -សៈ -នី) ន. ភ្លើងអេឡិចត្រិក ។

អង្គា (អង់ -គា) ន. រូបរាងកាយ ចំណែកនៃរាងកាយ ។

អតីត (អៈ -តី -តៈ ) គុ. ដែលកន្លងទៅហើយ ។ អតីតកាល គឺកាលដែលកន្លងទៅហើយ ។

អតិថិជន (អៈ -តិ -ថិ -ជន់) ន. មនុស្សជាភ្ញៀវ អ្នកមកទិញ អ្នកមករកពឹងពាក់ ។

អត្ថន័យ (អ័ត -ថៈ -នៃ)ន. ការពន្យល់ សេចក្ដី ការរៀបរាប់លក្ខណៈនៃវត្ថុផ្សេងៗ ។

អធិបតីភាព (អៈ -ធិ -ប៉ៈ -ដី ភាប) ន. ភាពជាធំ ជាប្រធាន ជាប្រមុខ ជាម្ចាស់ ។

អធិរាជ (អៈ -ធិ -រាច) ន. ស្ដេចដែលធំជាងស្ដេចទាំងឡាយក្នុងប្រទេសជិតខាង ។

អលង្ការ (អៈ -ល៉ុង -កា)ន. គ្រឿងប្រដាប់សម្រាប់តុបតែងខ្លួន មានចិញ្ចៀន ខ្សែកជាដើម ។

អនាគត (អៈ -ន៉ា -គត់)ន. កាល ឬសម័យខាងមុខ ។

អនាម័យ (អៈ -ន៉ា -ម៉ៃ)ន. ដំណើរមិនមានរោគ ឬឥតជំងឺ ។

អនុស្សាវរីយ៍ (អៈ -នុស -សា -វៈរី)ន. ការដែលគួរនឹករំឭកឃើញ វត្ថុជាអំណោយដែលទុក ជាទីនឹករំឭក ។

អបាយមុខ (អៈ -បាយ- មុខ)ន. ហេតុឬអំពើជាប្រធានឬផ្លូវនៃសេចក្ដីវិនាស ។

អភ័យទោស (អះ-ភៃ- ទោស)ន. ការលើកលែងទោស ។

អភិបាលខេត្ត (អះ-ភិ-បាល-ខែត)ន. អ្នកគ្រប់គ្រងខេត្ត ចៅហ្វាយខេត្ត ។

អភិវឌ្ឍ (អះ-ភិ-វ័ត)កិ. ធ្វើឱ្យរីកចម្រើន ។

អរិយធម៌ (អះ-រិយះ-ធម៌)ន ធម៌ដែលនាំឱ្យកើតសេចក្ដីសុខចម្រើន ។

អន្ទង (អន់-ទង)កិ. ដឹកនាំ ឬបញ្ចុះបញ្ចូលឱ្យព្រមតាម ។

អប្សរា (អ័ប-ប្សៈ-រ៉ា)ន. ស្ត្រីសួគ៌មានសម្បុរភ្លឺថ្លាផូរផង់ ។

អសោច (អះ-សោច)គុ. ស្អុយអាក្រក់គួរខ្ពើម ។

អស្ចារ្យ (អស់-ចា)គុ. ដែលគួរស្ញើចក្រៃលែង ដែលគួរស្ងែងក្រៃពេក ។

អាកប្បកិរិយា (អា-ក័ប-ប៉ះ-កិ-រ៉ិ-យ៉ា)ន. អាការនៃរាងកាយ ដំណើរ ឬលំនាំនៃរាងកាយ ឬឫកពា ។

អាការ (អា-កា-រះ)ន. រូបរាង ទ្រង់ទ្រាយ ភិនភាគ ឫកពា កិរិយា ។

អាជីព (អា-ជីប)ន. ដំណើរនៅមានជីវិត ការចិញ្ចឹមជីវិត ។

អាជីវករ (អា-ជី-វះ-ក)ន. អ្នកប្រកបមុខរបរចិញ្ចឹមជីវិត ។

អាជ្ញាធរ (អាច-ញ៉ា-ធ)ន. អ្នកកាន់អំណាច អ្នកទ្រទ្រង់អំណាច ។

អាណានិគមនិយម (អា-ណា-និ-គំ-និ-យំ)ន. លទ្ធិ ឬអធ្យាស្រ័យនៃជនខ្លះដែលចូលចិត្តតែខាងជ្រៀតជ្រែកវាយដណ្ដើមយកប្រទេសដទៃមកធ្វើជាស្រុកចំណុះខ្លួន ។

អាណាព្យាបាល ន. អ្នកគ្រប់គ្រងរក្សា ។

អាត្មា ន. ខ្លួន ចិត្ត ។

អារម្មណ៍ (អា-រំម់)ន. ការដឹង គ្រឿងតោងនៃចិត្ត គ្រឿងទាក់ទាញ ។

ឥស្សរជន (អ៊ិស-សះរ៉ះ-ជន់)ន. ជនជាអ្នកធំ ។

ឧតុនិយម (អ៊ុ-តុ-និ-យំ)ន. ដំណើរកំណត់រដូវ ការពិនិត្យធាតុភូតធម្មជាតិ ។

ឧត្តមសិក្សា (អ៊ុត-ដំ-សិក-សា)ន. ការរៀនសូត្រខ្ពង់ខ្ពស់ ។

ឧត្តរ (អ៊ុត-ដ)ន. ទិសខាងជើង ។

ឧបករណ៍ (អ៊ុ-ប៉ះ-ក)ន. គ្រឿងប្រកបផ្សំគ្នា គ្រឿងប្រុង គ្រឿងប្រដាប់សម្រាប់ធ្វើការ ។

ឧបាយកល (អ៊ុ-បាយ-កល់)ន. ល្បិច កិច្ចកល ផ្លូវគំនិត កលមាយា ។

## យើងបម្រើសេវាកម្ម ៖

- អភិវឌ្ឍសៀវភៅនិងសម្ភារឧបទេស
- បោះពុម្ព
- ចែកផ្សាយដល់សាលារៀន

## WE SERVE:

- book and teaching-aid development
- printing
- distribution to schools

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ( គ.ប.ច )
PUBLISHING AND DISTRIBUTION HOUSE ( PDH )

# បណ្ណាគារ គ.ប.ច
# PDH BOOKSHOP

១៤៨ មហាវិថីព្រះនរោត្តម ភ្នំពេញ ទូរស័ព្ទ: ០២៣ ៦៣ ៦៣ ០៣៣ 148, Norodom Boulevard, Phnom Penh, Tel: 023 63 63 033

## មានលក់ ៖

សៀវភៅសិក្សាគោលសម្រាប់សិស្ស សម្រាប់គ្រូ សៀវភៅហ្វឹកហាត់ សៀវភៅអំណានបន្ថែម និង សម្ភារឧបទេស ព្រមទាំងសម្ភារការិយាល័យគ្រប់មុខ !

## SELLING:

textbooks , teacher's manuals , workbooks , supplementary readers , teaching-aids and st

IBC INTERNATIONAL BOOK CENTER
$ 2.20

9789995001315